សាកលវិទ្យាល័យជាតិគ្រប់គ្រង
National University of Management

សៀវភៅសិក្សា

នីតិរដ្ឋធម្មនុញ្ញកម្ពុជា

តម្លៃធម្មនុញ្ញប្រពៃណី និងទំនើប



បណ្ឌិត ហោ ប៉ែន

រក្សាសិទ្ធិគ្រប់យ៉ាង

បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណក្ខាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ជាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា “មូលនិធិ ស.គ.ន.” និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា “RCI Fund”។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.0 (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការ**រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា

២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់

៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតែមាន់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំបរិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំបរិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សាជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

សេចក្តីបញ្ជាក់
នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តបរិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION, YOUTH AND SPORT
សាកលវិទ្យាល័យជាតិគ្រប់គ្រង
NATIONAL UNIVERSITY OF MANAGEMENT

លេខ: ០៧២ /២១ ស.ជ.ត.



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

លិខិតឧទ្ទេសនាម

មន្ត្រីរាជការ និងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគណៈកម្មការនិពន្ធ និងត្រួតពិនិត្យស្នាដៃរៀបរៀង និពន្ធ និងកែលម្អ សៀវភៅកម្រិតឧត្តមសិក្សា ដែលមានចំណងជើងថា "នីតិរដ្ឋធម្មនុញ្ញកម្ពុជា តម្លៃធម្មនុញ្ញប្រពៃណី និងទំនើប"៖

ក. គណៈកម្មការនិពន្ធ ឬអ្នកនិពន្ធ

១. ឯកឧត្តមបណ្ឌិត ហោ ម៉េង

ខ. គណៈកម្មការត្រួតពិនិត្យ៖

១. លោកបណ្ឌិត	សេង	ប៊ុនធឿន	ប្រធាន
២. លោកបណ្ឌិត	លី	សុខហោង	អនុប្រធាន
៣. លោកស្រី	ប៉ុក	ភារុន	សមាជិក

គ. ការអនុញ្ញាតឲ្យបោះពុម្ពផ្សាយ៖

ឯកឧត្តមបណ្ឌិត ហោ ម៉េង ជាសាកលវិទ្យាធិការ។

គណៈកម្មការ និងអ្នកនិពន្ធ ដូចមានរាយនាមខាងលើ មានភារកិច្ច និងអនុវត្តតាមលិខិតឧទ្ទេសនាមនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៨កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១

សាកលវិទ្យាធិការ

បណ្ឌិត ហោ ម៉េង

អាសយដ្ឋាន: ផ្លូវ៩៦គ្រីស្តូហ្វ័រហូវ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥-១២) ៦៧៥ ៧៦៧/ ៨៩៣ ១៣១/ ៨៨៩ ៤៩៥
Address: St. 96 Christopher Howes, Sangkat Wat Phnom, Khan Daun Penh, Phnom Penh / Tel: (855-12) 675 767 / 893 131 / 889 495 Email: sengbunthoeun@num.edu.kh.

សៀវភៅសិក្សា

នីតរដ្ឋធម្មនុញ្ញកម្ពុជា

តម្លៃធម្មនុញ្ញប្រពៃណី និងទំនើប

បណ្ឌិត ហោ ប៉ែង

មហាវិទ្យាល័យនីតិសាស្ត្រ
សាកលវិទ្យាល័យជាតិគ្រប់គ្រង
NUM Research Series 2021

រក្សាសិទ្ធិ

មាតិការ

សៀវភៅសិក្សា..... I

មាតិការ..... II

អារម្ភកថា..... III

សេចក្តីផ្តើម 1

ជំពូក១ កំណើតរដ្ឋខ្មែរ ការបង្កើត ការវិវត្ត និងការផ្លាស់ប្តូរ 3

ជំពូក២ ជំណើរការរៀបចំរដ្ឋធម្មនុញ្ញនិតិរដ្ឋ 6

ជំពូក៣ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ប្រកាសរក្សាឡើងវិញូវមានមកវិញនូវរបបរាជានិយមប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស 9

- ១ តម្លៃធម្មនុញ្ញប្រពៃណី រាជានិយមពុទ្ធសាសនា 9
- ២ តម្លៃធម្មនុញ្ញទំនើប លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស 10
- ៣ ដើមកំណើតលទ្ធិប្រជាធិបតេយ្យសេរី 11
- ៤ ទស្សនសិទ្ធិមនុស្ស 12
- ៥ គោលការណ៍បែងចែកអំណាច 13
- ៦ គោលការណ៍នីតិរដ្ឋ 13
- ៧ របបសេដ្ឋកិច្ចទីផ្សារ 14

ជំពូក៤ វឌ្ឍនភាពនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សកម្ពុជា 16

ជំពូក៥ កម្ពុជាក្នុងបរិបទទំនើបូបនីយកម្ម 21

ឯកសារយោង 23

ឧបសម្ព័ន្ធ១ 25

ឧបសម្ព័ន្ធ ២ 169

ឧបសម្ព័ន្ធ ៣ 194

អារម្ភកថា

ខ្ញុំរៀបរៀងនិពន្ធសៀវភៅនេះ នៅថ្ងៃទី១៥ មេសា ឆ្នាំ២០២១ ចំថ្ងៃចូលឆ្នាំប្រពៃណីខ្មែរ និងចំថ្ងៃបិទខ្ទប់ទីក្រុងភ្នំពេញ ទប់ស្កាត់ការរីករាលដាលឆ្លងជំងឺកូវីដ១៩ ដែលកំពុងធ្វើឲ្យពិភពលោកទាំងមូលមានការភ័យខ្លាច និងបានបញ្ចប់ជាស្ថាពរ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ។

សៀវភៅសិក្សាស្តីពី **ឥតរដ្ឋធម្មនុញ្ញកម្ពុជា តម្លៃធម្មនុញ្ញប្រពៃណី និងទំនើប** ជាអត្ថបទសិក្សាសង្ខេប ចេញពីការពង្រីកបំពេញបន្ថែមពីអត្ថបទដើមរបស់ខ្ញុំស្តីពី **ដំណើរការខុសគ្នានៃ រដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ន** ដោយមានគោលដៅចូលរួមចំណែកក្នុងកិច្ចការស្រាវជ្រាវអំពីនីតិ រដ្ឋធម្មនុញ្ញកម្ពុជាដែលជាការសិក្សាដំណើរការការវិវត្តនៃវឌ្ឍនភាពតម្លៃធម្មនុញ្ញប្រពៃណី និងទំនើប។

សូមអរគុណ ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានបង្កើតនូវមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ “មូលនិធិ ស.គ.ន” រួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ ឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។

សូមអរគុណ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញបានផ្តល់ជូននូវអត្ថបទរដ្ឋធម្មនុញ្ញបោះផ្សព្វផ្សាយឆ្នាំ២០២០ (updated profile) ជាឧបសម្ព័ន្ធក្នុងសៀវភៅ។ សូមអរគុណ ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ បានផ្តល់ជូននូវកម្រងច្បាប់ស្តីពីគណបក្សនយោបាយដែលរៀបចំដោយក្រសួងមហាផ្ទៃដាក់ជាឧបសម្ព័ន្ធ។ សូមអរគុណចំពោះមជ្ឈមណ្ឌលឧត្តមភាព ដើម្បីកិច្ចការស្រាវជ្រាវ និងនវានុវត្តន៍ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ដែលបានជួយសម្របសម្រួលពេលវេលា បច្ចេកទេស ប្រកបដោយភាពរលូន។ សូមអរគុណចំពោះគណកម្មការត្រួតពិនិត្យ និងក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃសាកលវិទ្យាជាតិគ្រប់ ដែលបានផ្តល់នូវអនុសាសន៍បំពេញបន្ថែមប្រកបដោយស្មារតីភាពតរភាព។

សូមអរគុណដល់ឧត្តមភរិយា ប៉ុក ចាន់រ៉ែត កូនស្រី ប៉ែង ម៉ាលីដា និងកូនប្រុស ប៉ែង ម៉ាលីនែវ ដែលបានជួយជាស្មារតីជំនួយការគ្រប់យ៉ាងក្នុងដំណើរការរៀបរៀងនិពន្ធសៀវភៅសិក្សានេះឡើង។

សេចក្តីផ្តើម

"សម្រាប់ប្រទេសកម្ពុជា ពាក្យថា សេរីភាព បានន័យថា ឯករាជ្យពេញលេញបរិបូរណ៍"[1]
"មន្ត្រីជាអ្នកបំរើរាស្ត្រដ៏ស្មោះត្រង់ មិនមែនជាចៅហ្វាយនាយទេ"[2]

បច្ចុប្បន្ន កម្ពុជា ជារដ្ឋស៊ីវិល័យមួយនៅអាស៊ីអគ្នេយ៍។ ឆ្លងកាត់រយៈពេលជិត៣០ឆ្នាំចុងក្រោយនេះ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នាំមកនូវសន្តិភាព ស្ថិរភាព និងការផ្លាស់ប្តូរ ប្រែក្លាយកម្ពុជា ដែលជារដ្ឋធ្លាប់រាំរ៉ៃដោយសង្គ្រាមស៊ីវិល និងអស្ថិរភាព មកជារដ្ឋប្រតិបត្តិតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សេដ្ឋកិច្ចទីផ្សារ គោរពសិទ្ធិសេរីភាព ទោះបីជានៅមានការលើក ឡើងថាកម្ពុជានៅមានការប្រឈមចំពោះមុខជាច្រើនទៀតក៏ដោយ។ ថ្នាក់ដឹកនាំនយោបាយខ្មែរកំពូលពីរូប ដែលដើរតួនាទី សំខាន់បំផុតក្នុងដំណើរការបញ្ចប់សង្គ្រាម ធ្វើឲ្យមានសន្តិភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍរីកចម្រើនឡើងវិញ គឺសម្តេច ព្រះនរោត្តម សីហនុ និងសម្តេចតេជោ ហ៊ុន សែន។[3] រដ្ឋស៊ីវិល័យ ជានីតិរដ្ឋតម្កល់រដ្ឋធម្មនុញ្ញជាច្បាប់កំពូល សិទ្ធិសេរីភាព ប្រជាធិបតេយ្យ និងយុត្តិធម៌ ត្រូវបានគោរព ធានាការពារ និងលើកកម្ពស់ ក្នុងក្របខណ្ឌនៃច្បាប់រដ្ឋ។

រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ប្រកាសរក្សាឡើងវិញឲ្យមានមកវិញរបបរាជានិយមប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងលទ្ធិ ប្រជាធិបតេយ្យសេរីពហុបក្ស។[4] សណ្តាប់ធ្នាប់ធម្មនុញ្ញថ្មីនេះ ជាធម្មនុញ្ញទំនើបមានលក្ខណៈប្រជាធិបតេយ្យទូលំទូលាយ ដោយបានផ្សំបន្សុីតម្លៃប្រពៃណី និងតម្លៃទំនើបតាមលំនាំរដ្ឋបស្ចឹមប្រទេសដែលអ្នកស្ថាបនិកខ្មែរ[5] បានមើលឃើញថាជា ជំរើសត្រឹមត្រូវបំផុត ដើម្បីរក្សាឲ្យមានឡើងវិញនូវការបង្រួមបង្រួមជាតិ ឯកភាពជាតិ សន្តិភាព ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ។[6]

កម្ពុជាជារដ្ឋឯករាជ្យ និងអធិបតេយ្យ ប្រតិបត្តិតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។ ព្រះមហាក្សត្រគ្រងរាជសម្បត្តិ ប៉ុន្តែមិនកាន់អំណាចឡើយ។ ពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់

---

[1] ដកស្រង់ពីព្រះរាជនិពន្ធរបស់សម្តេចព្រះវរៈក្សត្រ ព្រះនរោត្តម សីហនុ ស្តីពីរាជសកម្មភាពដើម្បីឯករាជ្យបរិបូណ៌នៃកម្ពុជា (ទសវត្សន៍ ១៩៤០-១៩៥០) ពីឯករាជ្យពេញបរិបូណ៌មកសង្គមរាស្ត្រនិយម (រឿងរ៉ាវជាច្រើនដែលអ្នកប្រវត្តិសាស្ត្រទាំងឡាយ ពុំបានសរសេរ) ជាឯកសារបកប្រែដោយទស្សនាវដ្តី ឥន្ទ្រទេវី បោះពុម្ពលើកទី២, នៅក្នុងឆ្នាំ២០០៥, ទំព័រ ១១៦។

[2] ប្រសាសន៍របស់សម្តេចអគ្គមហាសេនាតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (ថ្លែងក្នុងពិធីប្រគល់ សញ្ញាបត្រនៃវគ្គបណ្តោះបណ្តាលមន្ត្រីជាន់ខ្ពស់, សាលាជាតិរដ្ឋបាល នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧)។

[3] បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ប្រវត្តិសាស្ត្រប្រទេសកម្ពុជាក្នុងបរិបទសកលលោក (ស៊ីប៉ា ២០១៩, ទំព័រ ២៣៧-២៩២) និង Hor Peng, The Development of the Constitution of the Kingdom of Cambodia *in* Hor Peng, Kong Phallack & Soth Sang Boon, Perspectives on Cambodian Constitutional Law (NUM Research Series 2020, p.15-25)។

[4] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា១។ រដ្ឋធម្មនុញ្ញនេះ ត្រូវបានប្រកាសដាក់ឲ្យប្រើថ្ងៃទី២៤ខែកញ្ញាឆ្នាំ១៩៩៣ រហូតដល់សព្វថ្ងៃ។

[5] បទអន្តរាគមន៍របស់ឯកឧត្តម ចែម ស្ងួន អនុប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៅក្នុងសម័យ ប្រជុំពេញអង្គលើកទី២នៃសភាធម្មនុញ្ញរាយការណ៍ជូនសភាធម្មនុញ្ញ ពីដំណើរការរៀបរៀង និងពិគ្រោះសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ជំបូង (កំណត់ហេតុពិស្តារប្រជុំពេញអង្គលើកទី២នៃសភាធម្មនុញ្ញ, អគ្គលេខាធិការរដ្ឋសភា ថ្ងៃទី១៥ កញ្ញា ឆ្នាំ១៩៩៣)។

[6] សូមអានបុព្វកថារដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ក្នុងបុព្វកថាបានប្រកាសទទួលយកទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើបតាមលំនាំរដ្ឋបស្ចឹម។

វាសនានៃប្រទេសជាតិរបស់ខ្លួន អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈ រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាដំរះក្តី។ អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ប្រព័ន្ធរាជរដ្ឋាភិបាលអាស្រ័យរដ្ឋសភា និងសមាជិករដ្ឋសភាត្រូវជ្រើសតាំង៥ឆ្នាំម្តងតាមការបោះឆ្នោតសកល។ អំណាចតុលាការជាអំណាចឯករាជ្យ។ ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ច ការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ និងដោះស្រាយវិវាទបោះឆ្នោត។

អត្ថបទសិក្សាស្រាវជ្រាវនេះ បានសិក្សាអំពីគុណតម្លៃធម្មនុញ្ញកម្ពុជា ដែលកំពុងប្រតិបត្តិនៅក្នុងរដ្ឋធម្មនុញសព្វថ្ងៃ ពិសេសពិនិត្យវឌ្ឍនភាព នៃគុណតម្លៃធម្មនុញ្ញប្រពៃណី និងទំនើប។ ការសិក្សាយកចិត្តទុកដាក់ពីដំណើរការវិវត្តនៃវឌ្ឍនភាពថ្មីៗ ដើម្បីជាមូលដ្ឋានពង្រឹងនូវស្ថិរភាពធម្មនុញ្ញនាពេលអនាគត ។ មេរៀនប្រវត្តិសាស្ត្រ ការប្រឈមក្នុងបច្ចុប្បន្នភាព និងដំណោះស្រាយ ជាប្រភពមូលដ្ឋានសំខាន់មួយដែលអាចផ្តល់នូវពុទ្ធិ អំពីដំណើរការនៃការផ្លាស់ប្តូរពេលអនាគត ក៏អាចថាបាន។

ជំពូក១ កំណើតរដ្ឋខ្មែរ ការបង្កើត ការខិតក្ត ឆិងការផ្លាស់ប្តូរ

"ព្រះរាជាខ្មែរនាអតីតកាល មានឋានៈស្មើនឹងព្រះអាទិទេព...
ហើយលើសពីនេះ ព្រះអង្គគឺជាព្រះអាទិទេពផ្ទាល់ក្នុងសង្គមមនុស្ស"[7]

លទ្ធិធម្មនុញ្ញនៃប្រទេសកម្ពុជាបានប្រសូត្រចេញពីកំណើតនៃរដ្ឋខ្មែរ។ អ្នកប្រវត្តិសាស្ត្រខ្មែរ និងបរទេសបានយល់ស្របគ្នាថា ស្រុកខ្មែរបានបង្កើតឲ្យមានជារដ្ឋដំបូងនៅសតវត្សទី១ ឈ្មោះដើមជាអាណាចក្រភ្នំ (ហ្វូណន) កាន់ប្រពន្ធ័នយោបាយរាជាធិបតេយ្យឥណ្ឌាតូបនីយកម្មតាមព្រហ្មញ្ញសាសនា។[8] តាមរាជពង្សាវតារ ព្រះរាជាខ្មែរ ព្រះបាទ ហ៊ុន ទៀន (កៅណ្ឌិន្យ/ព្រះថោង) និង ព្រះនាង លីវ យី (សោមា/នាងនាគ) ជាបុព្វវីរៈក្សត្រនៃអាណាចក្រភ្នំ រៀបចំរចនាសម្ព័ន្ធកសាង ការពារទឹកដី សាសនា និងពលរដ្ឋខ្មែរ បន្តរាជពង្សាវតារ គង់វង្សរីកចំរើន និងឆ្លងកាត់ការផ្លាស់ប្តូរជាច្រើនសម័យកាល។ ព្រះអង្គជានិមត្តិរូបនិរន្តរភាពជាតិ និងសាសនា និងជាអ្នកមានបុណ្យបារមីរបស់អ្នកម្ចាស់ស្រុកដើម។

លទ្ធិធម្មនុញ្ញបុរាណខ្មែរដោទំនៀមទំលាប់ប្រពៃណីរបស់ព្រះរាជា (ការស្នងរាជ រាជកិច្ច និងការចូលទីវង្គត) ដែលបានវិវត្តចេញមកពីជំនឿគោរពព្រហ្មញ្ញសាសនា និងពុទ្ធសាសនា។ ក្នុងព្រហ្មញ្ញ សាសនា ប្រជាពលរដ្ឋមានជំនឿគោរពតួអង្គព្រះអវតារ (ទេវតា ព្រះឥន្ទ ព្រះព្រហ្ម) និងក្នុងពុទ្ធសាសនា ប្រជាពលរដ្ឋមានជំនឿគោរពព្រះរតនត្រៃយ៍ (ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ) ដែលកំណត់យកអាស្រម និងវត្តអារាម ធ្វើជាទីសក្ការៈគោរពបូជា និងអប់រំបណ្តុះបណ្តាល។ អង្គព្រះមហាក្សត្រជាម្ចាស់ព្រះនគរ មានព្រះរាជកិច្ចកសាង និងការពារ សេចក្តីសុខសាន្តជូនប្រជាពលរដ្ឋ ក្នុងព្រះនាមជាតួអង្គព្រះ និងមានបុព្វជិតសាសនា ឧកញ្ញា សេនាបតីមន្ត្រី និងកងទ័ពជាអ្នកបំរើដ៏ស្មោះត្រង់របស់ទ្រង់។

សាសនាទាំងពីរ បានចូលមកប្រទេសកម្ពុជា តាមរយៈបុព្វជិតផ្សព្វផ្សាយសាសនា និងពាណិជ្ជករជោតិឥណ្ឌា និងក្លាយជាជំនឿនិងការគោរពរបស់អ្នកស្រុកតាំងពីមុនគ្រឹៈសករាជមកម្លេះ។[9] ព្រហ្មញ្ញសាសនា បានក្លាយជាសាសនារដ្ឋស្របគ្នានឹងការបង្កើតរដ្ឋដោយស្នាព្រះហស្ត ព្រះបាទ ហ៊ុន ទៀន ជាមេទ័ពបំបែកខ្លួនមកពីប្រទេសឥណ្ឌា ដែលឈ្នះការវាយ

---

[7] ដកស្រង់ពី បណ្ឌិត មីសែល ត្រាណេ ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ការបង្កើតរដ្ឋខ្មែរ (២០០២, ទំព័រ ១៩)

[8] ខ្ញុំបានពិនិត្យស្នាដៃស្រាវជ្រាវសម័យមុនៗមកដល់បច្ចុប្បន្នមាន ក្នុងនោះរួមមាន លោក ឈឹម សុទ ពង្សាវតារនៃប្រទេសកម្ពុជា (១៩៥២), ព្រះភិក្ខុ ប៉ាង ខាត់ ប្រវត្តិសាស្ត្រខ្មែរ (១៩៧២), បណ្ឌិត មីសែល ត្រាណេ ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ការបង្កើតរដ្ឋខ្មែរ (២០០២), លោក David Chandler, A History of Cambodia (4th Edits, 2008), លោក ថាច់ ត្វាន់ ប្រវត្តិសាស្ត្រប្រជាជាតិខ្មែរ (២០១០) បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន, ប្រវត្តិសាស្ត្រកម្ពុជាក្នុងបរិបទសកលលោក (២០១៩)។ល។ ពួកគាត់បានយល់ស្របដូចគ្នាថា រដ្ឋខ្មែរបង្កើតឡើងដំបូងនាសតវត្សទី១ ដោយសំអាងលើសិសាចារឹកនៅវ៉ូកាញ់ កំណត់ហេតុអ្នកការទូតចិននាសតវត្សទី៣ និងកំណាយផុសសុីលនៅកំពង់ផែបូរាណអូកែវជាដើម។ ប្រវត្តិសាស្ត្រខ្មែរបានរៀបរាប់ជារឿងព្រេងបែបទេវកថា ពីការកកើតនៃរដ្ឋខ្មែរតាមការរៀបចំអភិសេកស្វាមីការិយារវាងស្ត្រីខ្មែរម្ចាស់ស្រុក និងបុរសជនជាតិឥណ្ឌា។

[9] ភិក្ខុ បាំង ខាត់ ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ (១៩៦១)។ បើតាមព្រះភិក្ខុ បានលើកឡើងថា ព្រហ្មញ្ញក្តី និងពុទ្ធសាសនាក្តីបានចូលកមកម្ពុជានៅមុនគ្រិស្តសករាជ៣០៩ឆ្នាំ ព្រោះដែនដីកម្ពុជានេះតាំងនៅមណ្ឌលសុវណ្ណភូមិ(ទំព័រ១-៣៥)។ ប្រទេសកម្ពុជាបានទទួលអរិយអធ៌ឥណ្ឌាទុកជាមត៌មតាំងពីបូរាណកាល, សាសនាព្រាហ្មណ៍ក្តី ពុទ្ធសាសនាក្តី ដែលបានមកប្រតិស្ឋាននៅលើផែនដីខ្មែរហើយ ក៏កើតបានទៅជាអរិយធម៌សម្រាប់ប្រទេស ប្រជាជនខ្មែរ បានរក្សាអរិយធម៌នោះទុកជាប្រពៃណីដោយប្រពៃ តពូជពង្សរៀងដរាបរហូតមលដល់បច្ចុប្បន្នកាលនេះ។

ប្រយុទ្ធគ្នាជាមួយម្ចាស់ស្រុកដើម ព្រះនាង លីវ យី និងបានបង្រួបបង្រួមជានាគ្នា តាមការរៀបចំអភិសេកជាមួយព្រះនាងម្ចាស់ស្រុក ឡើងគ្រងរាជសម្បត្តិ បង្កើតជាអាណាចក្របន្តរាជវង្ស តាមប្រពន្ធ័នយោបាយរាជាធិបតេយ្យឥណ្ឌានីយកម្ម។

ការគោរពតាមព្រហ្មញ្ញសាសនា និងអរិយធម៌បុរាណឥណ្ឌា ត្រូវបានរៀបចំគោរពប្រតិបត្តិ និងកែសម្រួលស្របតាមទំលាប់ប្រពៃណី និងសណ្ឋាប់ធ្នាប់សង្គម។ បើតាមប្រវត្តិវិទូខ្មែរ មនុស្សខ្មែរជាន់ដើមមានជំនឿសាសនាដោយឡែករបស់ខ្លួនមុនសាសនាពីក្រៅចូលមកដោយបានរក្សាបន្ត និងសម្របខ្លួនជាមួយសាសនាមកពីក្រៅ (ព្រហ្មមញ្ញសាសនា និងពុទ្ធសាសនា)ដល់សព្វថ្ងៃ ដោយបានរក្សាជំនឿគោរព មេបា ទឹកដី និងអ្នកតា។[10] អ្នកខ្លាំងពូកែល្បីល្បាញ (មេទ័ព) មានការគោរពកោតខ្លាចពីអ្នកស្រុក ដល់ពេលស្លាប់ទៅគាត់អាចនឹងក្លាយជាអ្នកតា (ឬលោកយាយ) ជាព្រលឹងវេទមួយនៅបន្តជួយថែរក្សាអ្នកស្រុក។ មនុស្សខ្មែរដើមជឿថា មនុស្សស្លាប់ទៅមិនសូន្យទេ គឺមានព្រលឹងទៅចាប់ជាតិជាថ្មីទៀត។ ទស្សនៈនេះព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ក៏មានជំនឿដូចគ្នា (ព្រលឹង កម្មពៀរ និងការសេរជាតិ)។

លទ្ធិធម្មនុញ្ញភាពប្រតិបត្តិតាមប្រពន្ធ័រាជាធិតេយ្យអាស្រ័យសាសនា បានឡើងដល់កំរឹតកំពូលនាសម័យអង្គរ ប៉ុន្តែបានធ្លាក់ចុះមកវិញ ចមចយរហូតមកដល់សតវត្សទី១៤ ទើបប្រទេសកម្ពុជាបានប្តូរ មកកាន់ធម្មនុញ្ញភាពរាជាធិបតេយ្យអាស្រ័យពុទ្ធសាសនាតរៀងមក។ ប្រជាពលរដ្ឋខ្មែរបានប្តូរជំជឿពីការគោរពព្រហ្មញ្ញសាសនា ដែលកំណត់ថា ដោគវាសនាអាស្រ័យលើព្រះអវតារ មកគោរពពុទ្ធសាសនាវិញ ដែលកំណត់ថា វាសនារបស់បុគ្គលម្នាក់ៗ ផ្អែកលើកម្មផល ធ្វើបុណ្យបានកុសល្យ និងប្រព្រឹត្តបាបបានកម្មពៀរ។ ទ្រឹស្តីនេះបាននាំមកនូវការផ្លាស់ប្តូរមួយនៅក្នុងផ្នត់គំនិតរបស់ពលរដ្ឋខ្មែរលើមូលដ្ឋានជំនឿលើហេតុផលដែលជាសញ្ញាណនៃការប្រសូត្រឡើងនៃសង្គមពុទ្ធិ។ និន្នាការនេះ ស្របគ្នាជាមួយអឺរ៉ុបនាសម័យកាល Renaissance និង Enlightenment ដែលជាសម័យប្រសូត្រឡើងនូវសង្គមចំណេះដឹង វិវត្តជាដំហានៗចេញមកពីទស្សនសង្គមគ្រិស្តសាសនា នាសតវត្សទី១៤ ។[11]

ស្របគ្នានៃការផ្លាស់ប្តូរនិន្នាការនេះ ពួកបេសកជនបុព្វជិតសាសនាគ្រិស្ត និងពាណិជ្ជករបានចូលមកអាស៊ីអាគ្នេយ៍ជាបណ្តើរៗ ដំបូងផ្សព្វផ្សាយសាសនា និងដោះដូរពាណិជ្ជកម្ម ប៉ុន្តែក្រោយមករដ្ឋនៅអ៊ឺរ៉ុបបានប្រជែងគ្នាចូលមកពង្រីកដែនអាណានិគមត្រួតត្រារបស់ខ្លួនជាបន្តបន្ទាប់ ក្នុងនោះកម្ពុជាក៏បានក្លាយជារដ្ឋអាណាព្យាបាល និងរដ្ឋអាណានិគមរបស់ប្រទេសបារាំង ជិត១សតវត្ស (១៨៦៣ ដល់ ១៩៥៣)។[12] ទស្សនទានសង្គមទំនើប វប្បធម៌បស្ចឹមប្រទេស សាសនា

---

[10] ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ (១៩៧៣ ទំព័រ៣០) និង ថាច់ ត្វាន់ ប្រវត្តិសាស្ត្រប្រជាជាតិខ្មែរ (២០១០ ទំព័រ៨៣-៩៤)។


[11] នៅប្រទេសអ៊ឺរ៉ុប សាសនាគ្រិស្តមានតួនាទីសំខាន់ក្នុងសម័យ Renaissance/Enlightenment (សតវត្សទី១៤-១៨) ដោយបង្កើតចេញនូវទស្សនសិទ្ធិមនុស្ស និងបដិវត្តបង្កើតរដ្ឋទំនើប និងបដិវត្តសេដ្ឋកិច្ចឧស្សាហកម្ម និងបច្ចេកវិជ្ជាវិទ្យាសាស្ត្រ។ល។

[12] បើតាមលោក David Chandler នៅសតវត្សទី១៨-១៩ ប្រទេសកម្ពុជាបានធ្លាក់ចុះដុនដាបបាត់មុខបាត់មាត់ពីពិភពលោកដោយសារសង្គ្រាមឈ្លានពានវាទីជាបន្តបន្ទាប់ដែលបានបង្កដោយប្រទេសជិតខាងសៀមនិងវៀតណាម។ ព្រះមហាក្សត្រកម្ពុជាស្តេច អង្គ ឌួង និងបន្តក្រោយមក ស្តេច នរោត្តម មានការព្រួយបារម្ភជាខ្លាំង អំពីអាណាគតប្រទេសរបស់ទ្រង់ ដោយទ្រង់យល់ថាកម្ពុជាអាចនឹងបាត់បង់ទឹកដីដោយសារនយោបាយវាតទីរបស់ប្រទេសជិតខាង។ ដើម្បីរក្សាកម្ពុជាបានគង់វង្សទៅអាណាគតទ្រង់បានស្នើសុំប្រទេសបារាំងមកជួយការពារជាអាណាព្យាបាលតាមរយៈសទ្ធិសញ្ញាឆ្នាំ១៨៦៣ ប៉ុន្តែក្រោយមកបារាំងបានបង្ខំកម្ពុជាចុះសន្ធិសញ្ញាបន្តែមឆ្នាំ១៨៨៤ ដោយដាក់កម្ពុជាជាអាណានិគន៍និយមរបស់បារាំងវិញ និងបានបង្កការធើបប៉ះបោរពីអ្នកស្រុក។ ម្យ៉ាងទៀតបើតាមលោក វ៉ាន់ឌី កាអុន (សុបិន និងការពិត, ភាគ១ ឆ្នាំ២០១២, ទំព័រ៩) បញ្ជាក់ថាមុនពេលបារាំងចូលមកធ្វើអាណាព្យាបាល ស្រុកខ្មែរបានបាក់បែករចនាសម្ព័ន្ធសង្គមខ្ទេចខ្ទាំអស់ ហើយពេលនោះប្រជាពលរដ្ឋខ្មែរមានត្រឹម១លាន ៥សែនប៉ុណ្ណោះ បារាំងដែលមកធ្វើទំនើបកម្មនៅស្រុកខ្មែរ បានធ្វើឲ្យប៉ះពាល់ជាទម្ងន់ដល់អធិបតេយ្យ និងទំនៀមទំលាប់ខ្មែរ។

សេដ្ឋកិច្ចពាណិជ្ជកម្ម និងគំនិតនយោបាយ បានហូរចូលមកកម្ពុជាជាបណ្តើរៗ តាមរយៈអាណានិគមបារាំង និងបញ្ញាវន្តខ្មែរដែលទៅសិក្សានៅប្រទេសបារាំង និងបានធ្វើការងារជាមួយមន្ត្រីរដ្ឋការអាណានិគមបារាំង។

កំណត់សំគាល់ជារួម កម្ពុជាសម័យបុរាណមានរដ្ឋធម្មនុញ្ញជាតម្លៃប្រពៃណី។ ធម្មនុញ្ញប្រពៃណីនេះបានចងភ្ជាប់ទំនាក់ទំនងរវាង ទឹកដី ប្រជាពលរដ្ឋ សាសនា រាជាធិបតេយ្យ និងវប្បធម៌ប្រពៃណី ដោយរក្សានិងបន្តនិរន្តរភាពដល់សព្វថ្ងៃ ក្លាយជាបាវចនាជាតិ (ជាតិ សាសនា ព្រះមហាក្សត្រ)។ ទស្សទានអំពីជាតិមានភាពទូលំទូលាយ មានន័យជារដ្ឋ ឬជាប្រទេស ក្នុងនោះរួមមានទឹកដី ប្រជាពលរដ្ឋ រាជាធិបតេយ្យ វប្បធម៌ ប្រពៃណី និងទំនាក់ទំនងការទូត។ សាសនាជាជំនឿក្នុងផ្លូវជីវិតរបស់អ្នកស្រុក និងព្រះរាជាដែលគោរពដើរតាមព្រហ្មញ្ញសាសនា និងពុទ្ធសាសនា បង្កើតបាននូវនិយាមសង្គម វប្បធម៌ ប្រពៃណី សីលធម៌ និងគុណធម៌ រឹងមាំ ជាកាតព្វកិច្ចរបស់សាសនិកគ្រប់រូប ប្រើប្រាស់ក្នុងការទំនាក់ទំនង។ សីលធម៌ជាក្រមសង្គមដែលពាក់ព័ន្ធនឹងឥរិយាបទនិងសំដីសំដៅនៅក្នុងកិច្ចទំនាក់ទំនង។ គុណធម៌ ជាទឹកចិត្តសប្បុរស សណ្តោសប្រណី ជួយគ្នាទៅវិញទៅមក។ អង្គព្រះមហាក្សត្រជាទីគោរពសក្ការៈរបស់អ្នកស្រុក ជាប្រមុខដឹកនាំជាតិ និងសាសនា កសាង និងការពារទឹកដី និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋ ក្នុងព្រះនាមជាតួអង្គព្រះ មានបុព្វជិត ឧកញ៉ា សេនាបតី មន្ត្រី និងកងទ័ពជាអ្នកបំរើដ៏ស្មោះត្រង់របស់ទ្រង់។

រចនាសម្ព័ន្ធសង្គមនិងសាសនាខ្មែរសម័យបុរាណ



ជំពូក២ ដំណើរការរៀបចំរដ្ឋធម្មនុញ្ញទំនើប

"យើង ប្រជារាស្ត្រខ្មែរ... ក្នុងឆន្ទៈមោះមុត សរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ..."
"យើង ព្រះរាជាណាចក្រកម្ពុជាធិបតី ទ្រង់យល់... និងត្រាស់បង្គាប់..."[13]

ក្រោយសង្គ្រាមលោកលើកទី២ កម្ពុជាចាប់ផ្តើមរៀបចំទំនើបូបនីយកម្មប្រទេស យកលំនាំតាមរដ្ឋ បស្ចឹមប្រទេសដោយបានអនុម័តឲ្យមានរដ្ឋធម្មនុញ្ញទំនើប (១៩៤៧) កំណត់អំណាចរដ្ឋនៅក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញ (របបនីតិរដ្ឋ) ប្រតិបត្តិតាមរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ (រាជានិយមទំនើប) ដោយមានរាជរដ្ឋាភិបាលប្រជាធិបតេយ្យសភាតាមទម្រង់លំនាំរដ្ឋសភាសាធារណរដ្ឋបារាំងទី៤ និងរដ្ឋសភាអង់គ្លេសមួយផ្នែក ដោយរៀបចំបែងចែកអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ និងកំណត់លំហសិទ្ធិសេរីភាព និងករណីកិច្ចរបស់ពលរដ្ឋខ្មែរគ្រប់រូប។ នៅក្នុងដំណើរការរៀបចំទំនើបនីយកម្មរដ្ឋតាមលំនាំរដ្ឋបស្ចឹមប្រទេសនេះ បានប្រសូត្រចេញពីការសំរុះសំរួលមួយរវាងព្រះមហាក្សត្រ និន្នាការរាជានិយម ជាមួយ អ្នកនយោបាយនិន្នាការប្រជាធិបតេយ្យនៅក្នុងស្រុក។

បើតាមលោកសាស្ត្រាចារ្យ ឃឹម អ៊ី[14] រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ជាការសំរុះសំរួលរវាងព្រះមហាក្សត្រ និងសភាធម្មនុញ្ញ។ ក្រោយចប់សង្គ្រាមលោកលើកទី២ ឆ្នាំ១៩៤៥ បារាំងបានបន្តការត្រួតត្រាកម្ពុជាឡើងវិញ ប៉ុន្តែបានយល់ព្រមរៀបចំការកែសំរួលឲ្យកម្ពុជាមានស្វ័យភាពផ្ទៃក្នុងឡើងវិញ និងបានស្នើសុំឲ្យព្រះមហាក្សត្ររៀបចំរដ្ឋធម្មនុញ្ញទំនើបមួយ។ គណៈកម្មការចំរុះកម្ពុជាបារាំងត្រូវបានបង្កើតរៀបចំសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ដែលក្នុងនោះព្រះមហាក្សត្របានកំណត់នូវគោលការណ៍មូលដ្ឋានមួយចំនួន ទី១ រដ្ឋធម្មនុញ្ញត្រូវផ្សំលក្ខណៈប្រពៃណី និងលក្ខណៈទំនើបរបស់បស្ចឹមប្រទេស, ទី២ អត្ថបទព្រាងរដ្ឋធម្មនុញ្ញត្រូវដាក់ជូនពិគ្រោះយោបល់ក្នុងសភាតំណាងរាស្ត្រ ដើម្បីធានាឲ្យស្របតាមស្មារតីប្រជាធិបតេយ្យ។

សភាតំណាងរាស្ត្រខ្មែរ ដែលបានកើតពីការបោះឆ្នោតប្រជាធិបតេយ្យលើកដំបូងនាថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៤៦ មានអាសនៈសរុបចំនួន៦៧ ក្នុងនោះរួមមានសមាជិកគណប្រជាធិបតេយ្យ៥០កៅអី គណបក្សសេរីភាព១៤កៅអី និងគណបក្សជឿនលឿន៣កៅអី បានបើកសម័យប្រជុំពេញអង្គរបស់ខ្លួនលើកដំបូងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៤៦ ដោយបានប្រកាសជំហរបស់ខ្លួនជាសភាធម្មនុញ្ញ។ សមាជិកសភាធម្មនុញ្ញមួយចំនួន ដែលជាបញ្ញាវន្តបានទៅសិក្សានៅប្រទេសបារាំងមានទស្សនៈជឿនលឿន ចង់រៀបចំប្រទេសយកលំនាំតាមរដ្ឋបស្ចឹមប្រទេស ជារដ្ឋឯករាជ្យ អធិបតេយ្យ និងប្រជាធិបតេយ្យ។

ប៉ុន្តែរបបរាជានិយមអាស្រ័យតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ពុំទទួលបានស្ថិរភាពជាប់លាប់ទេ។ ប្រទេសជាតិនៅមានលក្ខណៈពាក់កណ្តាលទំនើប ពាក់កណ្តាលសក្តិភូមិ។[15] ប្រជាធិបតេយ្យសភាពុំមានស្ថិរភាពនយោបាយជាប់លាប់ ប្រព័ន្ធពហុបក្សបានដួលរលំ និងត្រូវបានជំនួសមកវិញ ដោយចលនាសង្គមរាស្ត្រនិយម តាមបែបប្រជាធិបតេយ្យប្រមូលផ្តុំ (ទម្រង់

---

[13] ដកស្រង់ពីបុព្វកថានៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងបុព្វកថានៃព្រះរាជក្រម (សញ្ញាជាតិ)។

[14] ឃឹម អ៊ី កម្រងច្បាប់ខ្មែរ ច្បាប់រដ្ឋធម្មនុញ្ញខ្មែរ (១៩៤៧ - ១៩៩៣) បោះពុម្ពលើកទី១ ឆ្នាំសិក្សា ១៩៩៧ - ៩៨ ទំព័រ១-៦។ សៀវភៅនេះចងក្រងនូវអត្ថបទរដ្ឋធម្មនុញ្ញខ្មែរគ្រប់សម័យកាលនិងបានសង្ខេបប្រវត្តិខ្លីៗជាមូលដ្ឋានដល់អ្នកសិក្សានីតិសាស្ត្រ។

[15] សូមអាន Jean-Claude Pomonti et Srege Thion អ្នកហៅហមស្តេចក្លាយជាអ្នកតស៊ូ វិបត្តិស្រុកខ្មែរ (១៩៧០) ទំព័រ ១-២០។ សៀវភៅនេះ បកប្រែពីភាសាបារាំងមកជាភាសាខ្មែរដោយកិក្ខុ លឹម វាសនា, កែសំរួលដោយកិក្ខុ គឹម សំបូរ (២០០៤)។

ប្រជាធិបតេយ្យពុទ្ធសាសនា) តែត្រូវបានបញ្ចប់ដោយព្រឹត្តិការណ៍រដ្ឋប្រហារឆ្នាំ១៩៧០។ មេដឹកនាំរដ្ឋប្រហារបានប្រកាសធ្វើបដិវត្តន៍លប់បំបាត់រាជានិយម បង្កើតរបបសាធារណៈខ្មែរតាមលំនាំប្រធានាធិបតីនៃសាធារណរដ្ឋបារាំងទី៥/អាមេរិក។

រដ្ឋប្រហារយោធាឆ្នាំ១៩៧០ នាំមកនូវការបែកបាក់ជាតិជា៣ក្រុម (រាជានិយម សាធារណរដ្ឋនិយម និងសង្គមនិយម) និងកម្ពុជាបានធ្លាក់ក្នុងសង្គ្រាមស៊ីវិល ក្រោមឥទ្ធិពលសង្គ្រាមត្រជាក់ រវាងប្លុកសេរី និងប្លុកកុម្មុយនីស្ត។ របបសាធារណៈខ្មែរត្រូវបានវាយរំលំនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយកងទ័ពបដិវត្តកម្ពុជា (ក្រុមខ្មែរក្រហម) និងកម្ពុជាបានបន្តធ្លាក់ទៅក្នុងរបបប្រល័យពូជសាសន៍។ មេដឹកនាំខ្មែរក្រហម ប៉ុលពត បានអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦ ប្រកាសធ្វើបដិវត្តន៍លប់បំបាត់សក្តិភូមិ និងរបបសេរី ដោយបង្កើតរដ្ឋកុម្មុយនីស្ត (កម្ពុជាប្រជាធិបតេយ្យ) លំនាំសាធារណរដ្ឋប្រជាមានិតចិន។

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបប្រល័យពូជសាសន៍ខ្មែរក្រហមដឹកនាំដោយ ប៉ុល ពត ត្រូវបានវាយរំលំដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដោយបានការជួយអន្តរាគមន៍ពីកងទ័ពប្រទេសវៀតណាម ប្រជាពលរដ្ឋកម្ពុជាត្រូវបានរំដោះជាស្ថាពរ រចនាសម្ព័ន្ធប្រពៃណីសង្គម ត្រូវបានរក្សាឲ្យមានមកវិញ តាមទំលាប់ជីវភាពគ្រួសារ ក្រុមសាមគ្គី មានផ្សារ វត្តអារាម សាលារៀន មន្ទីរពេទ្យ និងរដ្ឋអំណាចបដិវត្តប្រជាជនកម្ពុជា។ កម្ពុជាបានអនុម័តរដ្ឋធម្មនុញ្ញថ្មីឆ្នាំ១៩៨១ ប្រកាសបង្កើតរបបនយោបាយថ្មី សាធារណរដ្ឋប្រជាមានិតកម្ពុជា លំនាំបដិវត្តន៍នៅបណ្តារដ្ឋសង្គមនិយម (វៀតណាម/ សូវៀត)។ ប៉ុន្តែសង្គ្រាមនៅតែបន្ត កម្ពុជាត្រូវបានបែងចែកជាតំបន់ត្រួតត្រា៤ ផ្សេងដោយឡែកពីគ្នា និងសង្គ្រាមស៊ីវិលនៅតែបន្ត។

សង្គ្រាមត្រជាក់ពិភពលោកបានបញ្ចប់នៅកំឡុងឆ្នាំ១៩៨៩ ក្រោយពីការដួលរលំនៃសហភាពសូវៀត (ប្រទេសរុស្ស៊ី) កម្ពុជាបានកែសម្រួលអនុម័តរដ្ឋធម្មនុញ្ញថ្មីឆ្នាំ១៩៨៩ កែទម្រង់បើកផ្លូវសេដ្ឋកិច្ចទីផ្សារ និងលទ្ធិប្រជាធិបតេយ្យ ស្របគ្នានឹងដំណើរការស្វែងរកសន្តិភាព និងការបង្រួបបង្រួមជាតិឡើងវិញរវាងភាគីជម្លោះខ្មែរទាំង៤ សម្រេចបាននូវដំណោះស្រាយកិច្ចព្រមព្រៀងសន្តិភាពតាមស្មារតីសន្ធិសញ្ញាទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បើកផ្លូវសម្រាប់ការបោះឆ្នោត។

សន្ធិសញ្ញាសន្តិភាពទីក្រុងបារីសឆ្នាំ១៩៩១ ជាដំណោះស្រាយនយោបាយបញ្ចប់ជម្លោះប្រដាប់អាវុធនៅកម្ពុជាដោយសន្តិវិធី ដោយតម្រូវឲ្យបង្កើតឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា (SNC) តំណាងអធិបតេយ្យជាតិ និងរៀបចំការបោះឆ្នោតសកលក្រោមការចាត់ចែងផ្ទាល់ ពីអាជ្ញាធរអង្គការសហប្រជាជាតិ (UNTAC)។ សន្ធិសញ្ញាតម្រូវរៀបចំមាតុភូមិនិវត្តន៍ជនភៀសខ្លួន រៀបចំជំនួយអន្តរជាតិស្តារហេដ្ឋារចនាសម្ពន្ធ៍ប្រទេសជាតិឡើងវិញនិងកំណត់គោលការណ៍មូលដ្ឋានគ្រឹះមួយចំនួន ដើម្បីរៀបចំរដ្ឋធម្មនុញ្ញប្រជាធិបតេយ្យទូលំទូលាយមួយ ក្រោយពីការបោះឆ្នោតជ្រើសតាំងសភាធម្មនុញ្ញ។

ការរៀបចំការបោះឆ្នោតដោយអ៊ុនតាក់បានប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ ដោយមានគណបក្សនយោបាយ២០ចូលរួម ប៉ុន្តែភាគីខ្មែរក្រហមបានដកខ្លួនចេញពីការអនុវត្តសន្ធិសញ្ញា។

លទ្ធផលនៃការបោះឆ្នោត មានគណបក្សនយោបាយ៤ ត្រូវបានប្រជាពលរដ្ឋខ្មែរជ្រើសតាំងជាសមាជិកសភាធម្មនុញ្ញដែលមានចំនួនអាសនៈសរុប ១២០ កៅអី ក្នុងនោះគណបក្សហ៊ុន ស៊ិនប៊ិចទទួលបាន៥៨កៅអី គណបក្សប្រជាជនកម្ពុជាទទួលបាន៥១កៅអី គណបក្សប្រជាធិបតេយ្យសេរីពុទ្ធសាសនាបាន១០កៅអី និងគណបក្សម៉ូលីណាការបាន ១កៅអី។

សភាធម្មនុញ្ញដែលបានកើតចេញពីការបោះឆ្នោត បានបើកសម័យប្រជុំពេញអង្គរបស់ខ្លួនលើកទី១ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ បានប្រកាសផ្តល់នីតិសម្បទាឡើងវិញ ថ្វាយសម្តេចព្រះនរោត្តម សីហនុ ដោយបានប្រកាសថា រដ្ឋប្រហារថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ ជាអំពើខុសច្បាប់ និងបានបង្កើតឡើងវិញនូវនិរន្តរភាពនៃភាពស្របច្បាប់របស់រដ្ឋកម្ពុជា ដោយ

បានថ្វាយសម្តេចព្រះ នរោត្តម សីហនុ វិញនូវព្រះតំណែងជាព្រះប្រមុខរដ្ឋនៃកម្ពុជាពេញលក្ខណៈច្បាប់រក្សាឲ្យមានឡើងវិញ ពេញលេញ។

នៅសម័យប្រជុំពេញអង្គលើកទី២ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៣ និងថ្ងៃបន្តបន្ទាប់ សភាធម្មនុញ្ញបានជជែកពិភាក្សាលើសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ដោយបានរក្សាមកវិញឲ្យមានឡើងវិញ នូវរបបរាជានិយមទំនើបប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងបានអនុម័តនៅថ្ងៃទី២១ កញ្ញា ឆ្នាំ១៩៩៣ និងប្រកាសដាក់ឲ្យប្រើជាផ្លូវការដោយព្រះមហាក្សត្រនៃកម្ពុជា នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលជាព្រឹត្តិប្រវត្តិសាស្ត្រដ៏សំខាន់មួយរបស់ជាតិ។

បើយើងគិតពីឆ្នាំ១៩៤៧ មកត្រឹមឆ្នាំ១៩៩៣ អស់រយៈពេលជិតកន្លះសតវត្សនេះ កម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូរ (បដិវត្តន៍) រដ្ឋធម្មនុញ្ញ៦លើក និងបានបង្ហាញឲ្យឃើញពីភាពមិនច្បាស់លាស់របស់អ្នកនយោបាយខ្មែរ ក្នុងការកំណត់យកនូវប្រព័ន្ធនយោបាយពីក្រៅ (វប្បធម៌នាំចូល) បែបណាដែលស៊ីជាមួយតម្លៃប្រពៃណីរបស់ខ្លួន (វប្បធម៌ក្នុងស្រុក) ដែលធានាបាននូវសុខសន្តិភាពស្ថិរភាពពេញលេញ ក្នុងនោះរវាងរាជានិយម និងសាធារណៈរដ្ឋនិយម និងរវាងប្រជាធិបតេយ្យ និងសង្គមនិយម។

បើតាមលោក David Chandler សង្គមខ្មែរបុរាណឲ្យតម្លៃលើសិទ្ធិសមូហភាពនៃសហគមន៍រួមមានគ្រួសារ ព្រះសង្ឃ មេភូមិ (គ្រួសារ សាសនា និងមេដឹកនាំ) បង្កើតក្រុមសាមគ្គីជួយគ្នាទៅវិញទៅមក ក្នុងកិច្ចការធ្វើស្រែចំការ កិច្ចការពារ និងកសាងអភិវឌ្ឍភូមិស្រុក ជាងការគោរពសិទ្ធិឯកជន ឬសិទ្ធិមនុស្ស។ ព្រះពុទ្ធសាសនាមានឥទ្ធិពលខ្លាំងក្នុងជីវិតរស់នៅរបស់អ្នកភូមិ។ វត្តអារាម និងព្រះសង្ឃ មិនត្រឹមតែជាទីគោរពបូជា ប៉ុន្តែជាគ្រូ ជាសាលាអប់រំ ជាមន្ទីរព្យាបាលជម្ងឺ និងជាទីកន្លែងដោះស្រាយបញ្ហានានារបស់អ្នកភូមិ។ នៅសម័យអានិគមបារាំង ឥទ្ធិពលព្រះមហាក្សត្របានធ្លាក់ចុះ ពាណិជ្ជករ គ្រូបង្រៀន មន្ត្រី និងបញ្ញាវន្ត មានគំនិតជាតិនិយម និងជឿនលឿន ចង់បានឯករាជ្យភាព អធិបតេយ្យ និងប្រជាធិបតេយ្យ។

នៅឆ្នាំ១៩៤៥ ចលនាជាតិនិយមដើម្បីឯករាជ្យ និងប្រជាធិតេយ្យបានរើបឡើងយ៉ាងផុសផុល។ ដំណើរការបង្កើតគណបក្សនយោបាយ និងការរៀបចំការបោះឆ្នោតជ្រើសតាំងសភាតំណាង ត្រូវបានអនុញ្ញាតជាលើកដំបូងក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ប៉ុន្តែដំណើរការប្រជាធិបតេយ្យសេរីពហុបក្ស (១៩៤៦-១៩៥២) និងការរៀបចំសេដ្ឋកិច្ចចំរុះជាមួយសហគ្រាសរដ្ឋនិងឯកជន(១៩៤៧-១៩៧០) បានរីកដុះដាលត្រឹមរយៈពេលខ្លី និងដួលរលំទៅវិញក្រោមឥទ្ធិពលសង្គ្រាមត្រជាក់។

ក្នុងបរិបទជាក់ស្តែងសម័យនោះ ប្រជាធិបតេយ្យកម្ពុជាមានភាពផុយស្រួយ (ពហុបក្ស) ពីព្រោះជាវប្បធម៌នយោបាយថ្មីម្យ៉ាង និងម្យ៉ាងទៀត ការផ្លាស់ប្តូរចនាសម្ព័ន្ធសង្គមខ្មែរយឺតយ៉ាវពាក់កណ្តាលទំនើប និង៣ក់កណ្តាលសក្តិភូមិ។ ទោះជាយ៉ាងណាក៏ដោយ ការខិតខំប្រឹងប្រែងសម្របសម្រួលកែតម្រូវ ពីប្រជាធិបតេយ្យពហុបក្ស មកជាប្រជាធិបតេយ្យសង្គម (ប្រជាធិបតេយ្យពុទ្ធសាសនា) តាមការបង្កើតចលនានយោបាយសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) ជាចលនាបង្រួបបង្រួមជាតិដើម្បីជានាងឯកភាពជាតិមួយក្រោមម្លប់ ព្រះមហាក្សត្រ ពុទ្ធសាសនា និងរាជរដ្ឋាភិបាល។ ស្មារតីនេះបានបង្កើតនូវគោលការណ៍អព្យាក្រឹតភាព មិនចូលបក្សសម្ព័ន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ដល់សព្វថ្ងៃ។

ជំពូក៣ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

ប្រកាសរក្សាឱ្យជាច្បាប់មានមកច្បាស់នូវរបបរាជានិយម ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស

"ខ្ញុំតាំងសច្ចាថានឹងប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយ
នៃព្រះរាជាណាចក្រ ហើយនឹងតាំងចិត្តធ្វើផលប្រយោជន៍ដល់រដ្ឋ និងប្រជារាស្ត្រ"[16]

រដ្ឋធម្មនុញ្ញបច្ចុប្បន្ន គិតមកដល់ឆ្នាំនេះ (២០២១) មានអាយុជិត ៣០ឆ្នាំ និងត្រូវបានធ្វើវិសោធនកម្មចំនួន៩លើក និងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យបកស្រាយជាច្រើនករណីពាក់ព័ន្ធខ្លឹមសារ និង ធម្មនុញ្ញភាពនៃច្បាប់។ បើប្រៀបធៀបជាមួយរដ្ឋធម្មនុញ្ញមុនៗ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជារដ្ឋធម្មនុញ្ញអាយុវែងជាងគេក្នុងប្រវត្តិសាស្ត្រទំនើបកម្ពុជា មានភាពទន់ភ្លន់ រស់រវើក និងនាំមកនូវសុខសន្តិភាព និងការផ្លាស់ប្តូរ និងការអភិវឌ្ឍរីកចម្រើនពេញលេញ។ នៅក្នុងដំណើរការតាក់តែងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ អ្នកស្ថាបនិកកម្ពុជា មានគំនិតប្រជាធិបតេយ្យទូលំទូលាយ ជាមួយមេរៀនពីប្រវត្តិសាស្ត្រ របស់ខ្លួន បានបំពេញនូវភាពពេញលេញនៃការផ្សំផ្គុំតម្លៃធម្មនុញ្ញប្រពៃណី និងតម្លៃធម្មនុញ្ញទំនើប។

១ តម្លៃធម្មនុញ្ញប្រពៃណី រាជានិយមពុទ្ធសាសនា

លទ្ធិរាជាធិបតេយ្យអាស្រ័យសាសនា ដែលមានព្រះមហាក្សត្រជាតួអង្គគោរពសក្ការៈ នៅក្នុងដំណើរការរបស់រដ្ឋ ជាគុណតម្លៃធម្មនុញ្ញប្រពៃណីនាសម័យបុរាណ ក្រោយមកក្នុងការខិតខំធ្វើទំនើបនីយកម្មនៃរដ្ឋនាឆ្នាំ១៩៤៧ កម្ពុជាបានប្តូរមកកាន់របបរាជានិយមអាស្រ័យតាមរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ការផ្លាស់ប្តូរនេះ ដើម្បីសម្របសម្រួលតាមនិន្នាការនយោបាយជឿនលឿនក្នុងស្រុកផង និងនិន្នាការរីកចម្រើននៃលទ្ធិប្រជាធិបតេយ្យពិភពលោក។

ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ដំបូងឡើយគណៈកម្មការតាក់តែងរដ្ឋធម្មនុញ្ញ រៀបចំសេចក្តីព្រាងរដ្ឋធម្មនុញ្ញមួយដែលមិនមែនរបបសាធារណរដ្ឋហើយក៏មិនមែនរបបរាជានិយម ប៉ុន្តែជាសេចក្តីព្រាងដែលមានលក្ខណៈប្រជាធិបតេយ្យទូលំទូលាយ។ ប៉ុន្តែដោយប្រជាពលរដ្ឋខ្មែរភាពច្រើនចង់ឲ្យមានការវិលត្រឡប់មកវិញនៃរបបរាជានិយម និងថ្នាក់ដឹកនាំរបស់គណបក្សនយោបាយធំៗទាំង ៣ (គណបក្សហ៊ុនស៊ិនប៊ិច គណបក្សប្រជាជន និងគណបក្សប្រជាធិបតេយ្យសេរីពុទ្ធសាសនា) ដែលជាតំណាងប្រជាពលរដ្ឋខ្មែរនៅក្នុងសភាធម្មនុញ្ញ បានមូលមតិនាំគ្នា ទៅចូលគាល់សម្តេចព្រះប្រមុខរដ្ឋ សម្តេចព្រះនរោត្តម សីហនុ ដើម្បីនឹងសុំថ្វាយព្រះអង្គនូវការរក្សាឡើងវិញឲ្យមានមកវិញនូវរបបរាជានិយមដោយទាំងអស់គ្នាបានសំឡឹងមើលឃើញមានតែរបបនេះទេដែលអាចធានានៅក្នុងកាលៈទេសៈ បច្ចុប្បន្ននូវការបង្រួបបង្រួមជាតិ និងការឯកភាពជាតិ។ ដោយសំណូមពរជាការរសម្តែងនូវឆន្ទៈជាតិ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់មិនបានដំទាស់អ្វីទេ ទ្រង់យល់ព្រមទទួលឲ្យមានការរៀបចំតាក់តែងរដ្ឋធម្មនុញ្ញតាមរបបរាជានិយមទំនើបឡើងវិញ ប៉ុន្តែព្រះអង្គចង់ឲ្យមានលទ្ធិប្រជាធិបតេយ្យនេះជឿនលឿនបំផុតដោយទ្រង់សុំឲ្យកាត់ចេញ (ដកចេញ) នូវសិទ្ធអំណាចពីទ្រង់ទាំងអស់ និងត្រូវកំណត់ព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

---

[16] ដកស្រង់ចេញពីសច្ចាប្រណិធានៃព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាក្នុងឧបសម្ព័ន្ធទី៤នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។

ព្រះមហាក្សត្រគ្រងរាជសម្បត្តិប៉ុន្តែមិនកាន់អំណាចឡើយ។ ស្មារតីនេះមិនត្រូវកែប្រែទេ។ ព្រះអង្គជានិមិត្តរូបនៃឯកភាពជាតិនិងនិរន្តរភាពជាតិ។ ទ្រង់ជាអ្នកការពារឯករាជ្យជាតិ អធិបតេយ្យ បូរណភាព ទឹកដី និងសិទ្ធិមនុស្ស។ ពុទ្ធសាសនាជាសាសនារបស់រដ្ឋ ប៉ុន្តែប្រជាពលរដ្ឋខ្មែរមានសិទ្ធិពេញទីលើការគោរពជំនឿ។ សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។

២ តម្លៃធម្មនុញ្ញទំនើប លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស

"ដោយយល់ឃើញថា ការបន្តសង្គ្រាមមានតែធ្វើឲ្យប្រជាជនរងទុក្ខវេទនាតែប៉ុណ្ណោះ និងក្នុងគោលបំណងស្វែងរកសន្តិភាព និងការបង្រួមបង្រួមជាតិ ខ្ញុំព្រះករុណាខ្ញុំ ក៏ដូចជាគណបក្សប្រជាជនកម្ពុជា និងរដ្ឋាភិបាលនាសម័យនោះបានប្រឹងប្រែងយ៉ាងខ្លាំងដើម្បីស្វែងរកនូវដំណោះស្រាយនយោបាយមួយ... តាមការចរចារ"[17]

សន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ជាសមិទ្ធផលសំខាន់នៃដំណោះស្រាយនយោបាយរួម របស់ភាគីជម្លោះខ្មែរដោយមានការចូលរួមជួយគាំពារ និងធានាពីសហគមន៍អន្តរជាតិ។ ក្នុងកិច្ចដំណើរការចរចារស្វែងរកសន្តិភាពបានចាប់ផ្តើមនៅឆ្នាំ១៩៨៧ រវាងអ្នកដឹកនាំនយោបាយស្ថាបនិកសំខាន់ពីររូប សម្តេច សីហនុ និងសម្តេច ហ៊ុន សែន ធ្វើនៅទីក្រុង Fere Entardenois ប្រទេសបារាំង និងបានបើកផ្លូវដល់ការចូលរួមពីគ្រប់ភាគីខ្មែរក្នុងជម្លោះ និងសហគមន៍អន្តរជាតិ ដោយបានឯកភាពគ្នាកំណត់យកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសទ្ធិមនុស្ស និងគោលការណ៍នីតិរដ្ឋ ជាស្មារតីគោលការណ៍មូលដ្ឋាននៃរដ្ឋធម្មនុញ្ញទំនើបរបស់ខ្លួន។ នៅក្នុងឧបសម័ន្ធទី៥ នៃសន្ធិសញ្ញាសន្តិភាពទីក្រុងបារីស១៩៩១ បានកំណត់នូវលក្ខន្តិក:មូលដ្ឋាន៦ចំនុច ដើម្បីរៀបចំរចនាសម្ព័ន្ធនយោបាយថ្មីសម្រាប់កម្ពុជា៖

១ កម្ពុជាត្រូវអនុម័តរដ្ឋធម្មនុញ្ញប្រកាសដាក់ជាច្បាប់កំពូលរបស់ប្រទេស។ ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងតាមអំណាចរដ្ឋសភា ឬតាមការធ្វើប្រជាមតិ ឬតាមនីតិវិធីទាំង២។
២ ដោយមានមេរៀនប្រវត្តិសាស្ត្រ រដ្ឋធម្មនុញ្ញ ត្រូវប្រកាសធានានូវការគោរពសទ្ធិមនុស្សពេញលេញ។
៣ រដ្ឋធម្មនុញ្ញត្រូវប្រកាសកម្ពុជា ជារដ្ឋអធិបតេយ្យ ឯករាជ្យ អព្យាក្រឹត្យ និងឯកភាពជាតិ។
៤ រដ្ឋធម្មនុញ្ញត្រូវប្រកាសកម្ពុជា ជារដ្ឋប្រតិបត្តិតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។
៥ កម្ពុជាត្រូវបង្កើតឲ្យមានតុលាការឯករាជ្យ ដើម្បីការពារសិទ្ធិសេរីភាពពលរដ្ឋធានាដោយរដ្ឋធម្មនុញ្ញ។
៦ រដ្ឋធម្មនុញ្ញត្រូវអនុម័តដោយសំឡេង២/៣នៃចំនួនសមាជិកទាំងមូលនៃសភាធម្មនុញ្ញ។

លក្ខន្តិក:មូលដ្ឋានទាំង៦ចំនុចនេះ ជាធាតុចូល និងជាគោលការណ៍ធម្មនុញ្ញដ៏សំខាន់ នៅក្នុងដំណើរការរៀបចំបង្កើតគុណតម្លៃធម្មនុញ្ញទំនើប (ប្រជាធិបតេយ្យ សិទ្ធមនុស្ស និងនីតិរដ្ឋ) ដែលជាគោលការណ៍មូលដ្ឋានគ្រឹះនៃរដ្ឋធម្មនុញ្ញទំនើបជឿនលឿនតាមលំនាំរដ្ឋបស្ចឹមប្រទេស។

---

[17] ដកស្រង់ចេញពីប្រសាសន៍សម្តេចតេជោ ហ៊ុន សែន រំលឹកក្នុង ហ្វេសប៊ុក ពីដំណើរការចរចាររហូតសម្រេចបានជាកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស (២៣/១៨/១៩៩២ - ២៣/១០/២០១៥) ។ ឯកសារនេះបានបន្តផ្សព្វផ្សាយនៅក្នុងវេបសាយកម្ពុជាទសន្សរ:ថ្មី (Cambodian New Vision) ដែលរៀបចំឡើងដោយខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកសភាមណ្ឌលកណ្តាល។

៣ ដើមកំណើតលទ្ធិប្រជាធិបតេយ្យសេរី

លទ្ធិប្រជាធិបតេយ្យសេរី មានកំណើតចេញពីរដ្ឋបស្ចឹមប្រទេស (western modern nations) ដោយផ្តើមចេញពីប្រទេសអង់គ្លេសជារដ្ឋស្ថាបនិក និងបានចូលមកប្រទេសអាមេរិក ប្រទេសបារាំង និងបន្តរីករាលដាលជុំវិញពិភពលោក ជាប្រព័ន្ធនយោបាយទំនើប ដឹកនាំដោយរដ្ឋាភិបាលប្រជាធិបតេយ្យជ្រើសតាំងតាមការបោះឆ្នោតបំរើអភិបាលកិច្ចល្អ និងលើកតម្កើងលំហសិទ្ធិសេរីភាពប្រជាពលរដ្ឋ។ នៅសតវត្សទី១៧ (ចន្លោះឆ្នាំ១៦២៨ ដល់ឆ្នាំ១៦៨៨) ប្រទេសអង់គ្លេសបានឆ្លងកាត់ការធ្វើបដិវត្តន៍២ដង រៀបចំសណ្តាប់ធ្នាប់នយោបាយថ្មី ប្រែក្លាយរបបរាជាធិបតេយ្យ ជារាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងប្រតិបត្តិតាមលទ្ធិប្រជាធិបតេយ្យសេរី ដោយបានទទួលស្គាល់ និងគោរពសិទ្ធិសេរីភាពស៊ីវិល (Bill of Rights) និងកំណត់ការបែងចែកអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ (separation of powers) ។ បច្ចុប្បន្ននេះ ព្រះមហាក្សត្រីយានីអង់គ្លេស ទ្រង់គ្រងរាជសម្បត្តិ តំណាងនិមិត្តរូបជាតិ និងនិរន្តរភាពជាតិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ហើយនិងព្រះញាតិវង្សានុវង្សរបស់ព្រះមហាក្សត្រី បានបំពេញតែកិច្ចការមនុស្សធម៌ និងសង្គមជាតិ។

ទស្សនវិទូលោក ចន ឡុក (John Locke), នៅក្នុងស្នាដៃសៀវភៅរបស់គាត់ស្តីពី Two Treaties on Civil Government (1691), ជាអ្នកស្ថាបនិកនៃទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប (លក្ខន្តិក:សង្គម) ឈរលើមូលដ្ឋានគ្រឹះនៃសិទ្ធិសេរីភាព (សិទ្ធិមនុស្ស) ការបែងចែកអំណាចរដ្ឋ ប្រជាធិបតេយ្យ និងនីតិរដ្ឋដែលជាតម្លៃធម្មនុញ្ញទំនើបនៃលទ្ធិប្រជាធិបតេយ្យសេរីនិយម។ ទស្សនទានលោក John Locke មានឥទ្ធិពលខ្លាំងទៅលើបដិវត្តន៍នៅប្រទេសអាមេរិក និងប្រទេសបារាំង។ ក្រោយបដិវត្តន៍ឯករាជ្យរបស់អាមេរិកពីប្រទេសអង់គ្លេស(១៧៧៦) ប្រទេសអាមេរិក បានរៀបចំអនុម័តរដ្ឋធម្មនុញ្ញទំនើប ប្រកាសបង្កើតរបបសាធារណរដ្ឋប្រធានាធិបតីនិយម (១៧៨៨) កាន់លទ្ធិប្រជាធិបតេយ្យសេរី។ ស្របគ្នានេះដែរ បដិវត្តន៍ប្រទេសបារាំងឆ្នាំ១៧៨៩ បានចេញសេចក្តីប្រកាសមួយស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋស៊ីវិល(Declaration of the Rights of Man and of the Citizen) និងបានរៀបចំអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ ១៧៩១ បង្កើតរបបសាធារណរដ្ឋបារាំងទី១ ប៉ុន្តែក្រោយមកបានកែប្រែវិលចុះវិលឡើងរហូតមកដល់រដ្ឋធម្មនុញ្ញសាធារណរដ្ឋទី៥ (១៩៥៨) ទើបមានស្ថិរភាពជាប់លាប់ និងជាស្ថាពរមកដល់សព្វថ្ងៃ ជាសាធារណរដ្ឋ បែបម៉ូដែលបារាំង មានប្រធានាធិបតីផង និងនាយករដ្ឋមន្ត្រីផង។

នៅក្នុងបណ្តាប្រទេសអាស៊ី ជប៉ុនជាប្រទេសទី១ ដែលបានរៀបចំទំនើបបនីយកម្មប្រទេសតាមលំនាំរដ្ឋបស្ចឹមប្រទេស ដោយបានរៀបចំអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៨៨៩ យកលំនាំតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសអាឡឺម៉ង់ (Prussian Constitution) ដោយរដ្ឋធម្មនុញ្ញអាឡឺម៉ង់កាលនោះមានភាពស្រដៀងគ្នាជាមួយវប្បធម៌នយោបាយរបស់ជប៉ុន ដែលអធិរាជជប៉ុននៅមានអំណាចសកម្មនៅក្នុងនយោបាយ (កាន់អំណាច) មិនដូចប្រទេសអង់គ្លេសដែលរដ្ឋសភា មានអំណាចធំធេង ជាអំណាចអធិបតេយ្យ (parliamentary sovereignty) ទាំងផ្លូវច្បាប់ ផ្លូវនយោបាយ និងព្រះមហាក្សត្រ ជានិមិត្តរូប ទ្រង់មិនកាន់អំណាចទេ ចំណែកម៉ូដែលប្រទេសអាមេរិកវិញ មានភាពសេរីខ្លាំងពេក មិនស៊ីគ្នាជាមួយទម្លាប់វប្បធម៌នយោបាយក្នុងប្រទេសជប៉ុននាសម័យនោះ។ ប៉ុន្តែក្រោយចប់សង្គ្រាមលោកលើកទី២ ប្រទេសជប៉ុនបានបង្ខំចិត្តអនុមត័រដ្ឋធម្មនុញ្ញថ្មី ក្រោមសម្ពាតអាមេរិក ដោយទទួលយករដ្ឋធម្មនុញ្ញទំនើប តាមលំនាំអង់គ្លេស និងអាមេរិក ជារបបរាជានិយមទំនើប ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិ ប្រជាធិបតេយ្យសេរី ដោយមានរដ្ឋាភិបាលអាស្រ័យប្រជាធិបតេយ្យសភា។ បើគិតមកដល់ពេលនេះ មានរយៈពេល៧៣ឆ្នាំ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ របស់ប្រទេសជប៉ុន ពុំដែលបានកែប្រែ និងពុំធ្លាប់បានធ្វើវិសោធនកម្មម្តងណាទេ ប៉ុន្តែតម្លៃប្រជាធិបតេយ្យសេរីរបស់ជប៉ុន បានវិត្តពេញលេញ និងជាស្ថាពរ។

លទ្ធិប្រជាធិបតេយ្យជាប្រព័ន្ធនយោបាយទំនើបជឿនលឿនមួយ ដែលបានកំណត់ថាប្រជាជនជាម្ចាស់ មានអំណាចអធិបតេយ្យ ក្នុងដំណើរការរៀបចំរដ្ឋអំណាចប្រទេស។ រដ្ឋាភិបាលកើតចេញពីប្រជាពលរដ្ឋតាមអាណត្តិបោះឆ្នោត ដើម្បីបម្រើ និងការពារអាយុជីវិត សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋនិងសហគមន៍។ លទ្ធិប្រជាធិបតេយ្យសេរីនេះ

អាចសម្របខ្លួននៅក្នុងគ្រប់ទម្រង់នៃប្រព័ន្ធនយោបាយចាស់ថ្មី (រាជានិយម/សាធារណរដ្ឋនិយម)។ រដ្ឋបុរាណដែលកាន់របបរាជាធិបតេយ្យអាស្រ័យសាសនា ដើមឡើយពុំអាចសំរុះសំរួលជាមួយលទ្ធិប្រជាធិបតេយ្យបានទេពីព្រោះមានទស្សនវិជ្ជាខុសគ្នាខ្លាំងពេក អំពីសិទ្ធិអំណាច និងភាពជាម្ចាស់។ នៅក្នុងរាជាធិបតេយ្យសក្តិភូមិ ព្រះមហាក្សត្យតំណាងឲ្យព្រះអាទិទេព (រដ្ឋសាសនា) សិទ្ធិអំណាចទាំងអស់ជារបស់ទ្រង់ និងប្រជាពលរដ្ឋជ្រកក្រោមម្លប់ដើម្បីសេចក្តីសុខសាន្ត។ ដោយឡែកលទ្ធិប្រជាធិបតេយ្យកំណត់ថាប្រជាពលរដ្ឋជាម្ចាស់វាសនានៃប្រទេសជាតិ មានសិទ្ធិបង្កើតរដ្ឋាភិបាលជ្រើសតាំង ដើម្បីបម្រើអភិបាលកិច្ចល្អជូនប្រជាជន។ ទស្សនទានថ្មីនេះ បានជម្រុញឲ្យមានការងើបឡើងនៃចលនាបដិវត្តន៍ក្នុងស្រុកទាមទារលទ្ធិប្រជាធិបតេយ្យ និងបានបង្ខំឲ្យប្រទេសរាជានិយមមួយចំនួន រៀបចំការសម្របសម្រួល ប្តូរមកជារបបរាជានិយមទំនើបអាស្រ័យតាមរដ្ឋធម្មនុញ្ញវិញ ចំណែកប្រទេសមួយចំនួន បានធ្វើបដិវត្តន៍ផ្តួលរំលំរបបរាជានិយម បង្កើតសាធារណរដ្ឋ ដែលប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ត្រូវបានជ្រើសតាំងតាមរបបបោះឆ្នោតជំនួសមកវិញ។

៤ ទស្សនសិទ្ធិមនុស្ស

សិទ្ធិមនុស្សជាសិទ្ធិបុគ្គលម្នាក់ៗ ដើម្បីទទួលនូវសេចក្តីថ្លៃថ្នូរជាមនុស្ស (human dignity)។ រដ្ឋបុរាណអត់មានសិទ្ធិមនុស្សទេ។ រដ្ឋបុរាណអាស្រ័យតាមច្បាប់សាសនា និងច្បាប់ធម្មជាតិ។ មកដល់សតវត្សទី១៥ ទស្សនសិទ្ធិមនុស្ស បានទាក់ទាញការចាប់អារម្មណ៍នៅបណ្តាប្រទេសអ៊ឺរ៉ុប ជាពិសេសក្នុងខណៈកើតមានវិវាទសាសនារវាង Catholic និង Protestant ដែលបង្កឡើងពីការកែទម្រង់របស់លោក Martin Luther ទស្សនវិទូសាសនាអាឡឺម៉ង់។ កាលនោះប្រជាពលរដ្ឋត្រូវបានបង្ខំឲ្យរក្សាជំនឿតាមសាសនាកាតូលីក (គ្រិស្ត) ឬត្រូវបណ្តេញចេញពីស្រុកភូមិ បើពួកគេមានជំនឿតាមប្រូតេស្តង់។ នៅសម័យនោះ សេរីភាពចំពោះសាសនា (Freedom of Religion) ត្រូវបានអ្នកសិក្សាលើកយកមកជជែកវែកញែកទូលំទូលាយ និងបានរួមចំណែកសំខាន់ ផ្តល់នូវការទទួលស្គាល់ទស្សនសិទ្ធិមនុស្ស និងសិទ្ធិបុគ្គលពេញលេញ និងបានបំបែកខ្លួនចេញដាច់ពីគ្នាជាប៉ូល៣ សិទ្ធិមនុស្ស សាសនា និងរដ្ឋ ដោយប៉ូលនីមួយៗ បានវិវត្តឈានឡើងនូវស្វ័យភាព និងឯករាជ្យភាពដោយឡែកពីគ្នា។

សេរីភាពចំពោះជំនឿសាសនារបស់បុគ្គល ត្រូវបានទទួលស្គាល់ជាបណ្តើរៗ តាមទស្សនទានមូលដ្ឋាននៃសិទ្ធិមនុស្សដោយមានការបំភ្លឺថា ព្រះជាម្ចាស់បានបង្កើតផែនដី និងមនុស្សតាមបំណងរបស់ទ្រង់ ទ្រង់បង្កើតមនុស្សមានសិទ្ធិស្មើគ្នា ព្រះរាជាមិនអាចនៅពីលើមនុស្សបានទេ ប៉ុន្តែទ្រង់ត្រូវស្ថិតនៅពីក្រោមព្រះ និងច្បាប់។ល។ នៅសតវត្សទី១៧ ទស្សនវិទូ John Locke ដោយបានសិក្សានិងដកបទពិសោធន៍ពីបដិវត្តន៍នៅប្រទេសអង់គ្លេស បានរៀបចំបង្កើតទ្រឹស្តីរដ្ឋទំនើបឈរលើទស្សនមូលដ្ឋានសិទ្ធិមនុស្ស ឬសិទ្ធិសេរីភាពស៊ីវិល នៅក្នុងសៀវភៅសិក្សារបស់លោក Two Treaties of Civil Government (1691) ដែលបានកំណត់មូលដ្ឋានទ្រឹស្តីថ្មីនៃទំនាក់ទំនងរវាងសិទ្ធិពលរដ្ឋស៊ីវិល និងរដ្ឋអំណាច។

ទ្រឹស្តីរបស់គាត់បានបំភ្លឺថា មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសិទ្ធិដូចគ្នាពីកំណើត (men are born free and equal in rights)។ ធម្មជាតិបានកំណត់ឲ្យមនុស្សម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត មានសិទ្ធិសេរីភាព និងសិទ្ធិលើទ្រព្យសម្បត្តិ (life, freedom, property)។ ប៉ុន្តែដើម្បីមានសុវត្ថិភាព និងសុខុមាលភាព (security and prosperity) បុគ្គលគ្រប់រូបត្រូវរួបរួមគ្នាជាសហគមន៍ដោយត្រូវបង្កើតនូវរដ្ឋាភិបាលជ្រើសតាំងមួយ ដើម្បីបំពេញនិងបំរើជូននូវអភិបាលកិច្ច ដើម្បីកិច្ចការពារជីវិត សេរីភាព និងទ្រព្យឲ្យបានល្អប្រសើរ។ បើរដ្ឋាភិបាលជ្រើសតាំងនេះ ខកខាន ឬពុំបានបំពេញអភិបាលកិច្ចល្អរបស់ខ្លួន នោះប្រជាពលរដ្ឋមានសិទ្ធិរៀបចំធ្វើបដិវត្តន៍។ ទ្រឹស្តីនេះបាននាំមកនូវសណ្តាប់ធ្នាប់នយោបាយថ្មីមួយនៃពិភពលោក ជាស្មារតីនៃរដ្ឋស៊ីវិល័យ គោរពសិទ្ធិសេរីភាព ប្រជាធិបតេយ្យ និងនីតិរដ្ឋ។

៥ គោលការណ៍បែងចែកអំណាច

ទ្រឹស្តីបែងចែកអំណាចជាគោលការណ៍មូលដ្ឋានមួយនៅក្នុងទ្រឹស្តីរដ្ឋទំនើប។ ទស្សនទាននេះ មានតាំងពីនៅសម័យអារីស្តូតមកម្លេះ។ សម្រាប់លោក អារីស្តូត ការគ្រប់គ្រងរដ្ឋល្អ ត្រូវមានស្ថាប័ន៣, អ្នកប្រឹក្សាពិភាក្សា, អ្នកអនុវត្តជារដ្ឋការ និងអ្នកកាត់ក្តីជាចៅក្រម។[18] ក្រោយមកនៅសតវត្សទី១៧ ដោយ សារមានការប្រឈមរវាងរដ្ឋសភា និងព្រះមហាក្សត្រ បាននាំមកនូវបដិវត្តន៍ធម្មនុញ្ញថ្មី អំណាចរដ្ឋត្រូវបានបែងចែកដាច់ពីគ្នា ជា អំណាចធ្វើច្បាប់ អំណាចអនុវត្តច្បាប់ និងអំណាចកាត់ដំរះក្តី ។

នៅក្នុងធម្មនុញ្ញប្រពៃណីអង់គ្លេស ព្រះមហាក្សត្រជាតំណាងអាទិទេព និងពុំអាចទទួលខុសត្រូវចំពោះមុខរដ្ឋសភាបាន រដ្ឋសភាបានសម្របសម្រួលកំណត់ឲ្យមាននាយករដ្ឋមន្ត្រីជាអ្នកទទួលខុសត្រូវចំពោះរដ្ឋសភា។ ក្រោយមក ទម្រង់របបរាជរដ្ឋាភិបាលអាស្រ័យរដ្ឋសភា (ប្រជាធិបតេយ្យសភា) ត្រូវបានវិវត្តពេញលេញជាស្តាពរ។

លោក John Locke និង លោក Montesquieu បានសិក្សារៀបចំកំណត់ជាម៉ូដែលទូទៅមួយនៃគោលការណ៍បែងចែកអំណាច ស្របគ្នាជាមួយគោលការណ៍ការត្រួតពិនិត្យគ្នាទៅវិញទៅមក (the principle of separation of powers within the principle of check and balance) និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយដល់សព្វថ្ងៃនេះ។ គោលដៅសំខាន់គឺបង្ការកុំឲ្យមានអំណាចផ្តាច់ការ។

៦ គោលការណ៍នីតិរដ្ឋ

"ប្រទេសដែលអត់មានការអនុវត្តច្បាប់ ប្រទេសនោះអត់មានរដ្ឋធម្មនុញ្ញទេ"[19]

នីតិរដ្ឋជាគោលការណ៍មូលដ្ឋានសំខាន់មួយនៃរដ្ឋទំនើប និងត្រូវបានទទួលស្គាល់ទូលំទូលាយ។ នីតិរដ្ឋជារដ្ឋដែលកំណត់យកច្បាប់ជាធំនៅក្នុងយន្តការ និងនីតិវិធីរបស់រដ្ឋ ជានានូវអំណាចរដ្ឋក្នុងក្របខណ្ឌច្បាប់ និងជានានូវកិច្ចការពារជាមូលដ្ឋានមួយដល់សិទ្ធិមនុស្ស សេរីភាព និងសិទ្ធិបុគ្គល។

គោលការណ៍នីតិរដ្ឋកំណត់ថាមនុស្សគ្រប់រូបដោយមិនគិតពីតួនាទីបុណ្យសក្តិ ឋានៈនៅក្នុងសង្គម ឬពណ៌សម្បុរ ត្រូវស្ថិតនៅពីក្រោមអំណាចច្បាប់ និងអំណាចយុត្តាធិការដូចគ្នា។ អំណាចរដ្ឋត្រូវបានកម្រិតនៅក្នុងក្របខណ្ឌច្បាប់ ប៉ុន្តែសិទ្ធិបុគ្គលត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់។ សម្រាប់ប្រជាពលរដ្ឋ នីតិរដ្ឋបានជួយជាវិភាគទានផ្តល់ជូននូវកិច្ចការពារ និងការបំភ្លឺពន្យល់តាមផ្លូវច្បាប់ក្នុងការអនុវត្តសិទ្ធិ និងករណីកិច្ចរបស់ខ្លួន។ គោលដៅសំខាន់នៃនីតិរដ្ឋ គឺការពារសិទ្ធិមនុស្ស និងសិទ្ធិស៊ីវិល។

លោក Albert Venn Dicey ទស្សនវិទូអង់គ្លេស ក្នុងសៀវភៅរបស់គាត់ស្តីពី Introduction to the Study of the Constitution (1885) បានផ្តុំគោលការណ៍មូលដ្ឋានសំខាន់ៗនៃនីតិរដ្ឋរបស់រដ្ឋបស្ចឹមប្រទេសដែលមានគោលការណ៍យ៉ាងតិច៣ប្រតិបត្តិនៅក្នុងប្រព័ន្ធនីតិ៖ ទី១ គោលការណ៍គ្មានអនាគតិ គ្មានប្រតិសកម្ម (no arbitrariness and retrospectivity) សំដៅនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋការ។ គោលការណ៍នេះព្យាយាមកាត់បន្ថយ

---

[18] Hilare Barnett, Constitutional & Administrative Law (5th Edition, 2004, p.97-98)។

[19] Ancient Idea of Aristotle, "where law do not rule, there is no constitution" ដកស្រង់ពី Hilaire Barnett, Constitutional & Administrative Law (Fifth Edition, 2004, 69)។ The Politics, Bk iv, para 1292a31.

អំណាច និងបុព្វសិទ្ធិរបស់រដ្ឋការ ប៉ុន្តែបានផ្តល់នូវកិច្ចការពារផ្លូវច្បាប់មួយដល់សិទ្ធិបុគ្គល។ គោលការណ៍នេះវិវត្តពីទ្រឹស្តីរដ្ឋទំនើប (លក្ខន្តិក:សង្គម)។

ទី២ គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ (equality before the law) បានកំណត់ថាបុគ្គលគ្រប់រូបមានភាពស្មើគ្នានៅចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋាន:សង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ទី៣ គោលការណ៍ការពារសិទ្ធិតាមផ្លូវតុលាការ (protection of rights under due process) បានកំណត់បុគ្គលគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ អំណាចតុលាការជាអំណាចឯករាជ្យ ជានារក្សាអនាគតិ និងការពារសិទ្ធិ។

គោលការណ៍នីតិរដ្ឋជាលក្ខខណ្ឌចាំបាច់របស់រដ្ឋប្រជាធិបតេយ្យសេរី ប៉ុន្តែរដ្ឋសង្គមនិយមមិនឲ្យតម្លៃទេ។ លោក Karl Max ទស្សនវិទូអាឡឺម៉ង់ បិតាស្ថាបនិកលទ្ធិសង្គមនិយម ដែលកន្លងទៅប្រទេសរុស្សី និង បណ្តាប្រទេសអឺរ៉ុបខាងកើតមួយចំនួនបានយកមកអនុវត្តតាមនាសម័យសង្គ្រាមត្រជាក់ បានរិះគន់ទ្រឹស្តីនីតិរដ្ឋថា សង្គមមូលធននិយម ច្បាប់គ្រាន់តែជាឧបករណ៍នយោបាយ សម្រាប់ការពារវណ្ណៈ កាន់អំណាច និងវណ្ណៈមូលធនតែប៉ុណ្ណោះ។ វាមិនបានធានាការពារសិទ្ធិ និងយុត្តិធម៌ដល់ប្រជាពលរដ្ឋទូទៅនោះទេ ជាពិសេសសិទ្ធិកម្មករ និងកសិករ។ នីតិរដ្ឋរបស់រដ្ឋមូលធននិយម ពុំបានធានានូវសមភាពពិតប្រាកដ ជាពិសេសសមភាពនៃការបែងចែកផលប្រយោជន៍ទ្រព្យធននៅក្នុងសង្គម។

សតវត្សទី២០ គោលការណ៍នីតិរដ្ឋត្រូវបានរៀបចំកែសម្រួលឡើងវិញ ដើម្បីដោះស្រាយបញ្ហាអសមភាពសេដ្ឋកិច្ច និងសង្គមក្នុងចំណោមប្រជាពលរដ្ឋរបស់ខ្លួន សំដៅផ្តល់កិច្ចលើកស្ទួយសមភាព និងយុត្តិធម៌សង្គម (equality and justice under the rule of law) ជាពិសេសសម្រាប់ស្រទាប់អ្នកទន់ខ្សោយ ដូចជា កុមារ ស្ត្រី ជនពិការ ចាស់ជរា ដែលត្រូវទទួលបាននូវកិច្ចគាំពារពិសេសផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមកិច្ចពីរដ្ឋ ដើម្បីលើកស្ទួយសេចក្តីថ្លៃថ្នូរ និងសមភាពនៅក្នុងសង្គមសេរីភាពឡើងវិញ។

៧ របបសេដ្ឋកច្ចទីផ្សារ

នៅដើមសតវត្សទី២០ ពិភពលោកមានប្រព័ន្ធសេដ្ឋកិច្ច២ សេដ្ឋកិច្ចទីផ្សារ និងសេដ្ឋកិច្ចផែនការ។ ប្រព័ន្ធសេដ្ឋកិច្ចទាំងពីរនេះ មានទស្សនវិជ្ជា និងមនោគមនយោបាយខុសគ្នា។ រដ្ឋប្រជាធិបតេយ្យកាន់របបសេដ្ឋកិច្ចទីផ្សារ (ទ្រឹស្តីរបស់លោក Adam Smith) ដោយឡែក រដ្ឋសង្គមនិយមកាន់របបសេដ្ឋកិច្ចផែនការ (ទ្រឹស្តីរបស់លោក Karl Max)។ ប្រទេសអាឡឺម៉ង់ព្យាយាមសម្របសម្រួលបង្កើតចេញនូវម៉ូដែលទី៣ ជាប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសង្គម (social market economy) ជាផ្លូវសេដ្ឋកិច្ចកណ្តាលមួយ។

លោក Adam Smith[20] មើលឃើញ និងជឿថា ទីផ្សារសេរីជាប្រព័ន្ធសេដ្ឋកិច្ចដែលបានបំពេញបំរើឲ្យតម្រូវការ និងការផ្តត់ផ្តង់នៅក្នុងសង្គមដោយស្វ័យប្រវត្តិ និងដោយគ្មានការអន្តរាគមន៍ពីរដ្ឋ (laissez faire)។ ប្រព័ន្ធនេះផ្តល់ផលចំណេញធំធេងដោយស្វ័យប្រវត្តិទៅដល់សង្គមទាំងមូល។ ការអន្តរាគមន៍របស់រដ្ឋកាន់តែតិចកាន់តែល្អ។ ម៉្យាងមនុស្សតែងគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន (self-interests) និងដើម្បីបានផលចំណេញ បុគ្គលម្នាក់ៗ នឹងវិនិយោគពលកម្មជំនាញ និងទ្រព្យធនគេលើអ្វីដែលគេចង់។

[20] លោក អាដាម ស្មីត សេដ្ឋកិច្ចវិទូអង់គ្លេសនាសតវត្សទី១៨ ជាអ្នកបង្កើតទ្រឹស្តីសេដ្ឋកិច្ចទីផ្សារ អនុវត្តនៅអង់គ្លេស/អាមេរិក។

ប៉ុន្តែលោក Karl Max[21] មិនយល់ស្របទេ។ គាត់បានមើលឃើញថា ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ (លទ្ធិមូលធន) បានផ្តល់ផលចំណេញឲ្យទៅមនុស្សតិចតួចតែប៉ុណ្ណោះ ជាវណ្ណៈអ្នកមានមួយក្តាប់តូច។ ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ពួកនិយោជកកាន់តែមានឡើង ដោយសារការកេងប្រវាញ់កំលាំងពលកម្មពីក្រុមកម្មករ។ ដូច្នេះ ការអន្តរាគមន៍របស់រដ្ឋគឺជាការត្រឹមត្រូវ និងចាំបាច់បំផុត។ គាត់បន្តអះអាងថា ការធ្វើសេចក្តីសម្រេចចិត្តលើទីផ្សារ មិនគួរធ្វើឡើងដោយអ្នកទិញ និងអ្នកផលិតប៉ុណ្ណោះទេ ប៉ុន្តែគួរត្រូវរៀបចំ ឡើងដោយរដ្ឋដើម្បីធានាថា មនុស្សម្នាក់ៗ នៅក្នុងសង្គម ទទួលបានផលចំណេញទាំងអស់គ្នា។

បដិវត្តន៍ប៉ុលស៊ីវិចនៅប្រទេសរុស្សីឆ្នាំ ១៩១៧ បានបង្កើតឡើងនូវរដ្ឋសង្គមនិយមអនុវត្តសេដ្ឋកិច្ចផែនការតាមទស្សនវិទូលោក Karl Max មុនគេ។ បណ្តារដ្ឋមួយចំនួនទៀតនៅអឺរ៉ុបខាងកើត អាស៊ី និងអាហ្វ្រិក បានធ្វើបដិវត្តន៍តាមលំនាំរុស្សីសម័យសង្គ្រាមត្រជាក់។ ដោយឡែកនៅក្នុងប្រទេសអាឡឺម៉ង់ ក្រោយសង្គ្រាមលោកលើកទី២ បានបែងចែកជា២ ប្រទេសអាឡឺម៉ង់ខាងលិចកាន់លទ្ធិប្រជាធិបតេយ្យ និងអាឡឺម៉ង់ខាងកើតកាន់លទ្ធិសង្គមនិយម។ ឆ្នាំ១៩៤៨ រដ្ឋាភិបាលអាឡឺម៉ង់ខាងលិច[22] បានរៀបចំ កែសម្រួល (Adjustment) ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារឡើងវិញ ដើម្បីធានាថា រដ្ឋអាឡឺម៉ង់ខាងលិច ជាសង្គមសេរី និងជាសង្គមយុត្តិធម៌ តាមគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចថ្មីរបស់លោកអធិការបតី។

ការរៀបចំកែទម្រង់សេដ្ឋកិច្ចទីផ្សារនេះ បានបើកឲ្យរដ្ឋធ្វើអន្តរាគមន៍ចូលទីផ្សារ (Positive State) ក្នុងហេតុផលការពារ និងលើកស្ទួយយុត្តិធម៌សង្គម ស្របតាមវិធានការចំបាច់២យ៉ាង ទី១ បង្កើតនូវគោលនយោបាយសេដ្ឋកិច្ចដើម្បីជួយគាំពារសង្គម (សាងសង់ផ្លូវ ស្ពាន់ សាលារៀន មន្ទីរពេទ្យ និងគាំពារអ្នកក្រីក្រ) និងទី២ រដ្ឋរៀបចំបទដ្ឋានច្បាប់ធានានូវការប្រកួតប្រជែងស្មើភាពនិងដោយយុត្តិធម៌ (ការពារកម្មសិទ្ធបញ្ញា/បំបាត់ភាពផ្តាច់មុខ)។ គោលការណ៍ថ្មីនេះ តាមទស្សនសេដ្ឋវិទូរបស់អាឡឺម៉ង់ ជាប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសង្គម (social market economy) ជាប្រព័ន្ធសេដ្ឋកិច្ចទី៣ និងជាប្រព័ន្ធសេដ្ឋកិច្ចទីផ្សារផ្លូវកណ្តាលមួយ ធានាបាននូវការប្រកួតប្រជែងស្មើភាព និងយុត្តិធម៌សង្គម។[23]

---

[21] លោក កាល់ ម៉ាក្ស ជាសង្គមវិទូសេដ្ឋវិទូអាឡឺម៉ង់ដ៏ល្បីល្បាញនាសតវត្សទី១៩។ លោកជាអ្នកបង្កើតទ្រឹស្តីរដ្ឋសង្គមនិយម និងទ្រឹស្តីសេដ្ឋកិច្ចផែនការ។ ទ្រឹស្តីរបស់លោកទទួលបានការទាក់ទាញខ្លាំងក្នុងចំណោមកម្មករនាសតវត្សទី២០។

[22] លោកអធិការបតី Konrad Adenauer បានដឹកនាំរដ្ឋាភិបាលទី១នៃទេសអាឡឺម៉ង់ខាងលិច ដែលបានផ្តួចផ្តើម និងដាក់ចេញនូវគោលនយោបាយកែទម្រង់នេះ ដើម្បីរៀបចំស្ថាបនាសេដ្ឋកិច្ចអាឡឺម៉ង់ជាថ្មីឡើងវិញក្រោយសង្គ្រាម។ ទម្រង់សេដ្ឋកិច្ចទីផ្សារសង្គមនេះ ជាម៉ូដែលរបស់អាឡឺម៉ង់ និងមានប្រទេសប្រជាធិបតេយ្យជឿនលឿនមួយចំនួន (ជប៉ុន...) បានយកលំនាំតាម។

[23] សូមអាន Christian Watrin the Principles of the Social Market Economy – its Origins and Early History (The Social Market Economy: A German Experience.

ជំពូក៤ ទស្សនភាពនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សកម្ពុជា

"រដ្ឋឯករាជ្យ និងអធិបតេយ្យ គឺជារដ្ឋដែលត្រូវអនុវត្តច្បាប់ដោយខ្លួនឯងបាន "[24]

កន្លងទៅមានការជជែកវែកញែកខ្លះៗ អំពីដំណើរការវិវត្តតម្លៃប្រជាធិបតេយ្យកម្ពុជា និងមានការវាយតម្លៃខុសៗគ្នាទៅតាមនិន្នាការរបស់បុគ្គលនិងក្រុម។ នេះមកពីការយល់ដឹងរបស់ពួកគាត់ពីប្រជាធិបតេយ្យកម្ពុជាមិនដូចគ្នា។ ម៉្យាងទៀត យើងត្រូវដឹងថា នៅក្នុងការអនុវត្តជាក់ស្តែង ប្រជាធិបតេយ្យមានគោលការណ៍ នីតិវិធី និងគុណតម្លៃមិនដូចគ្នាទេតាមប្រទេសនីមួយៗ និងបានវិវត្តប្រែប្រួលតាមសម័យកាល។ ចំពោះអ្នកសិក្សាមកដល់ពេលនេះ ក៏មិនទាន់មានការឯកភាពជាក់លាក់ណាមួយនៅឡើយទេសម្រាប់ការកំណត់តម្លៃប្រជាធិបតេយ្យជារួម ដោយវិវត្តទៅតាមសម័យកាល តាមប្រទេសនីមួយៗ។

ក្នុងសម័យកាលដំបូង (classic democracy,សតវត្សទី១៨ និង១៩) តម្លៃប្រជាធិបតេយ្យសំដៅលើដំណើរការរៀបចំពង្រឹងស្ថាប័នប្រជាធិបតេយ្យ និងការប្រកួតប្រជែងការបោះឆ្នោត (កម្រិតប្រសិទ្ធភាពស្ថាប័ន)។ ការរៀបចំគោលការណ៍ នីតិវិធី និងយន្តការស្ថាប័នដើម្បីជានានូវរដ្ឋាភិបាលមួយរបស់ប្រជាជន ដោយប្រជាជន និងដើម្បីប្រជាជន (a government of the people, for the people and by the people) ដោយកំណត់ការបែងចែកអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ស្របគ្នានឹងការរៀបចំសណ្តាប់ធ្នាប់ប្រកួតប្រជែងការបោះឆ្នោត ដើម្បីជានាឲ្យអ្នកនយោបាយ ជាបេក្ខជនឈរឈ្មោះ សំដែងមតិដោយសេរី ដោយគ្មានការភ័យខ្លាច និងដោយការទទួលខុសត្រូវ។

ក្នុងសម័យកាលទំនើប (modern democracy, សតវត្សទី២០/២១) តម្លៃប្រជាធិបតេយ្យត្រូវបានពង្រីកទូលំទូលាយ កម្រិតលំហសេរីភាពពលរដ្ឋស៊ីវិល និងគណបក្សនយោបាយ។ ប្រជាពលរដ្ឋមានសិទ្ធិសេរីភាពពេញលេញ ក្នុងការចូលរួមគ្រប់សកម្មភាពនយោបាយ សេដ្ឋកិច្ច និងសង្គម តាមការសំដែងមតិដោយសេរីចំពោះបញ្ហានានា ដែលកើតមានក្នុងសហគមន៍របស់ពួកគាត់ ស្របគ្នាជាមួយការធ្វើឲ្យប្រសើរឡើងនៃសមត្ថភាពស្ថាប័នប្រជាធិបតេយ្យ ក្នុងការឆ្លើយតបនឹងសេវាតម្រូវការនិងសេវាសំណូមពររបស់ពលរដ្ឋ។ គណបក្សនយោបាយបានងើបឡើងជាតួអង្គប្រតិបត្តិសំខាន់។ ប្រព័ន្ធបក្សនិងគណបក្សមានតួនាទីសំខាន់ក្នុងការផ្តល់នូវដំរើសនយោបាយ និងភាពជាអ្នកដឹកនាំរបស់រដ្ឋ។

ក្នុងការប្រតិបត្តិជាក់ស្តែង ប្រជាធិបតេយ្យសេរីពហុបក្សកម្ពុជា បានដំណើរការរៀបចំឡើងក្នុងដំណាក់កាលទាំង២ព្រមគ្នាក្នុងពេលតែមួយដូចគ្នាពីការបង្កើត ការពង្រឹង និងការពង្រីកប្រសិទ្ធភាពនៃស្ថាប័នស្របគ្នាជាមួយលំហូរសេរីភាពចម្រុះពណ៌ និងវត្តមាននៃគណបក្សនយោបាយជាច្រើន ដោយមានអន្តរជាតិចូលរួមចំណែកជួយក្នុងដំណើរការកែទម្រង់នយោបាយ សេដ្ឋកិច្ច និងច្បាប់។

ក្នុងបរិបទចម្រុះបែបនេះ ប្រជាធិបតេយ្យសេរីពហុបក្ស ស្ថិតនៅក្នុងកម្រិតប្រឈមបើប្រជាពលរដ្ឋ និងអ្នកនយោបាយកម្ពុជា ខ្វះការយល់ដឹងពីតម្លៃប្រជាធិបតេយ្យ និងតម្លៃសិទ្ធិសេរីភាព។

ប្រជាធិបតេយ្យកម្ពុជាប្រតិបត្តិតាមតំណាង រដ្ឋាភិបាលអាស្រ័យរដ្ឋសភា បោះឆ្នោតជ្រើសតាំង៥ឆ្នាំម្តង តាមប្រព័ន្ធបោះឆ្នោតសមាមាត្រខេត្តក្រុង។ ប្រព័ន្ធបោះឆ្នោតសមាមាត្រខេត្តក្រុងនេះ នៅក្នុងទ្រឹស្តីជួយបង្កវឌ្ឍនភាពពហុបក្សក្នុងរបប

[24] សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (ថ្លែងក្នុងសន្និសីទអន្តរជាតិលើកទី២៦ ស្តីពី អនាគតអាស៊ី នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១។

សភា។ គណបក្សនយោបាយមានតួនាទីសំខាន់។ ម្យ៉ាងទៀត ប្រជាធិបតេយ្យនីយកម្មកម្ពុជា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានវិវត្តពេញលេញ ក្នុងនោះរដ្ឋសភា និងក្រុមប្រឹក្សាឃុំសង្កាត់ ជាអង្គជ្រើសតាំងសំខាន់ ក្នុងដំណើរការប្រជាធិបតេយ្យសេរីពហុបក្ស។

គណបក្សឈ្នះឆ្នោតមានអាសនៈក្នុងរដ្ឋសភា បង្កើតនូវវប្បធម៌សន្ទានយោបាយ ដើម្បីដោះស្រាយបញ្ហាជាតិក្រោយការបោះឆ្នោត តាមយន្តការប្រជាធិបតេយ្យសភា បង្កើតបាននូវដំណោះស្រាយថ្មីៗ ស្របតាមស្មារតីជាតិ ក្នុងនោះជាអាទិ៍ ការកែសម្រួលច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង។ ក្នុងរយៈពេល៣០ឆ្នាំចុងក្រោយនេះ មានការរៀបចំកែសម្រួលសើរើរដ្ឋធម្មនុញ្ញ និងច្បាប់ក្នុងស្មារតីទទួលខុសត្រូវចំពោះតម្លៃប្រជាធិបតេយ្យ។

ទី១ ការសើរើកែសម្រួលប្រព័ន្ធសភាមកជាសហសភាតាមការបង្កើតព្រឹទ្ធសភាឆ្នាំ១៩៩៩ មាន សារៈសំខាន់ចំពោះតម្លៃប្រពៃណី និងតម្លៃប្រជាធិបតេយ្យ។ ទី១ ដើម្បីបង្រួបបង្រួមនយោបាយគណបក្ស ដែលមានអរិភាព។ ទី២ ដើម្បីពង្រឹកប្រជាធិបតេយ្យសភាដោយប្រព័ន្ធសហសភាមានតម្លៃប្រជាធិបតេយ្យ ប្រសើរជាងប្រព័ន្ធឯកសភា ពីព្រោះប្រព័ន្ធសហសភាបានពង្រឹកការចូលរួមបានទូលំទូលាយ និងជួយដល់ការពង្រឹងពិនិត្យឡើងវិញក្នុងដំណើរការធ្វើច្បាប់ (second reflection)។ ទី៣ ដើម្បីស្តារឡើងវិញនូវស្តេប៊ន់ប្រវត្តិសាស្ត្រជាតិដែលមានពីមុន។ ករណីនេះ ផ្តើមពីការសម្របសម្រួលនយោបាយរវាងគណបក្សប្រជាជន និងគណបក្សហ៊្វុនស៊ិនប៉ិច ក្រោមអធិបតីភាពរបស់ព្រះមហាក្សត្រ។ បច្ចុប្បន្ន រដ្ឋសភា និងព្រឹទ្ធសភា កាន់អំណាចនីតិប្បញ្ញត្តិ និងជាតំណាងប្រជាពលរដ្ឋខ្មែរទាំងមូល។

ទី២ ការអនុម័តរដ្ឋធម្មនុញ្ញបន្ថែមធានាដំណើរការប្រក្រតីភាពស្ថាប័នជាតិ (ឆ្នាំ២០០៤) ផ្តើមចេញពីស្មារតីសម្របសម្រួលនយោបាយរវាងគណបក្សឈ្នះឆ្នោតនៅក្នុងរដ្ឋសភា គណបក្សប្រជាជន និងគណបក្សហ៊្វុនស៊ិនប៉ិច។ ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៣ (២០០៣) ដំណើរការរៀបចំបង្កើតរាជរដ្ឋាភិបាល តាមនីតិវិធីកំណត់ដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ពុំអាចអនុវត្តបានដោយជាប់គាំងអស់រយៈពេលជិត១ឆ្នាំ។ បញ្ហានេះ ត្រូវបានដោះស្រាយតាមការអនុម័តរដ្ឋធម្មនុញ្ញបន្ថែមឆ្នាំ២០០៤ បង្កើតនូវនីតិវិធីថ្មីស្តីពីការបោះឆ្នោតជាកញ្ចប់ នៅក្នុងការជ្រើសតាំងក្បាលម៉ាស៊ីនរដ្ឋសភា និងការផ្តល់សេចក្តីទុកចិត្តចំពោះការបង្កើតរាជរដ្ឋាភិបាលថ្មី។ ច្បាប់ធម្មនុញ្ញបន្ថែមនេះបានបំពេញពង្រឹងបន្ថែមសណ្តាប់ធ្នាប់នយោបាយប្រជាធិបតេយ្យ រវាងអំណាចទាំង២ឲ្យដើរស្របតាមឆន្ទៈប្រជាពលរដ្ឋតាមលទ្ធផលនៃការបោះឆ្នោត ដើម្បីធានាបាននូវនិរន្តរភាពស្ថាប័នជាតិ និងតម្លៃប្រជា ធិបតេយ្យដោយផ្ទាល់។ ក្រុមប្រឹក្សាធម្មនុញ្ញបានបកស្រាយថា ច្បាប់ធម្មនុញ្ញបន្ថែមជារដ្ឋធម្មនុញ្ញ។

ទី៣ ការដាក់រាជសម្បត្តិ (២០០៤) ជាក្នុងករណីពិសេស។ រដ្ឋធម្មនុញ្ញពុំមានចែងករណីនេះទេ ប៉ុន្តែវាបានប្រព្រឹត្តិទៅតាមទម្លាប់ប្រពៃណី ដោយការអនុម័តច្បាប់បំពេញបន្ថែមពីអំណាចនីតិប្បញ្ញត្តិ។ នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៤ ព្រះមហាក្សត្របានផ្ញើព្រះរាជសារជូនរដ្ឋសភាពីការសម្រេចចិត្តដាក់រាជសម្បត្តិចូលនិវត្តន៍ជាស្ថាពរ ដោយមូលហេតុព្រះរាជសុខភាព និងទម្លាប់ប្រពៃណីនៅក្នុងរបបរាជានិយម។ រដ្ឋសភា និងព្រឹទ្ធសភា បានរៀបចំតាក់តែង និងអនុម័តច្បាប់ស្តីពីក្រុមប្រឹក្សារាជសម្បត្តិ និងបានប្រកាសដាក់ឲ្យប្រើភ្លាមដោយប្រមុខរដ្ឋស្តីទីនៅថ្ងៃទី១១ខែតុលា ឆ្នាំ២០០៤។

ច្បាប់ស្តីពីក្រុមប្រឹក្សារាជសម្បត្តិ ចែងបំពេញបន្ថែមលើចំនុចខ្វះខាតនៃរដ្ឋធម្មនុញ្ញថា ក្នុងរយៈពេលយ៉ាងយូរ៧ថ្ងៃក្រោយពីព្រះមហាក្សត្រទ្រង់ចូលទីវង្គត ឬចូលនិវត្តន៍ ឬដាក់រាជ្យ ក្រុមប្រឹក្សារាជសម្បត្តិត្រូវជ្រើសរើសព្រះមហាក្សត្រថ្មីតាមសំឡេងភាគច្រើនដាច់ខាត។ ព្រះមហាក្សត្រដែលទ្រង់បានយាងចូលនិវត្តន៍ ឬដាក់រាជ្យ និងព្រះមហេសី ត្រូវបានរក្សាបុព្វសិទ្ធិ អភ័យឯកសិទ្ធិពេញលេញ និងមិនអាចនរណារំលោភបំពានបានឡើយ។ ការវិវត្តថ្មីនេះ បានជួយពង្រឹងនិរន្តរភាពនៃស្ថានប័នព្រះមហាក្សត្រ។

ក្នុងគំនិតដើម ព្រះមហាក្សត្រកម្ពុជាទ្រង់ជានិមិត្តរូបឯកភាពជាតិ និងនិរន្តរភាពជាតិ។ ក្នុងបរិបទជាក់ស្តែង ទ្រង់ជានិមិត្តរូបប្រជាធិបតេយ្យផងដែរ។ ទី១ របបរាជានិយមកម្ពុជា ជារបបជ្រើសតាំងដោយក្រុមប្រឹក្សារាជសម្បត្តិមានសមាភាព៩រូបមកពី ប្រធាន អនុប្រធានព្រឹទ្ធសភា ប្រធាន អនុប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងសម្តេចព្រះសង្ឃរាជទាំង២គណៈនិកាយ។ នេះមានន័យថា ជាតិ និងសាសនា ជ្រើសតាំងព្រះមហាក្សត្រតាមរបបជ្រើសតាំង។ ក្នុងចំណោម៩រូប មាន៧រូបជាថ្នាក់ដឹកនាំនយោបាយកំពូល ដែលត្រូវបានជ្រើសតាំងតាមលទ្ធិប្រជាធិបតេយ្យ និងក៏ជាថ្នាក់ដឹកនាំគណបក្សធំៗមានអាសនៈក្នុងសភាជាតិ។ ទី២ ទ្រង់បានបំពេញព្រះរាជកិច្ចជាព្រះប្រមុខរដ្ឋ ឡាយព្រះហស្តលេខាលើព្រះរាជក្រម និងព្រះរាជក្រឹត្យតាមការស្នើសុំពីស្ថាប័នប្រជាធិបតេយ្យ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ ក្នុងការបំពេញព្រះរាជកិច្ចជាព្រះប្រមុខរដ្ឋ ព្រះមហាក្សត្រប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ទី៣ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ព្រះញាតិវង្សានុវង្ស បានសូប់ស្ងាត់ពីឆាកនយោបាយ។ និន្នាការនេះបានជួយលើកស្ទួយតម្លៃរាជានិយម។ បើសិនជាការវិវត្តចុងក្រោយនេះក្លាយជាការប្រតិបត្តិជាប់លាប់ នោះជាបាតុភូតអស្ចារ្យមួយរបស់ខ្មែរ និងជាបដិវត្តដែលមិនធ្លាប់មានពីមុនដោយលំនាំតាមការប្រតិបត្តិនៅប្រទេសអង់គ្លេស និងជប៉ុនដែលជានិមិត្តរូបជោគជ័យនៃរបបរាជានិយមទំនើបប្រតិបត្តិតាមលទ្ធិប្រជាធិបតេយ្យសេរីរបស់រដ្ឋបស្ចឹមប្រទេស។

ទី៤ ការកែសម្រួលរូបមន្តផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល (ពី២/៣ មកត្រឹម៥ 0% +១) និងការកែសម្រួលកូរ៉ុមប្រជុំរដ្ឋសភា (ពី ៣/៤ មក ២/៣ ឬ ៥0% +១) តាមច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ២00៦ ជាការវិវត្តមួយថ្មីទៀតនៃប្រសិទ្ធភាពប្រជាធិបតេយ្យកម្ពុជា ជាពិសេសពង្រឹងការប្រកួតប្រជែង និងការទទួលខុសត្រូវរបស់គណបក្សនយោបាយ។ ការវិវត្តនេះ ជាដំណោះស្រាយមួយពេញលេញ បាននាំមកនូវប្រសិទ្ធភាពប្រជាធិបតេយ្យសភា ដែលកន្លងទៅមានការពិបាកក្នុងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល នៅរាល់ដើមនីតិកានីមួយៗ និងក៏ជួយការព្យាបាលជំងឺខ្វះកូរ៉ុមប្រជុំរដ្ឋសភា។ ប្រជាធិបតេយ្យសភាកម្ពុជា សមាជិកតំណាងរាស្ត្ររដ្ឋសភា ត្រូវបានជ្រើសតាំងតាមបោះឆ្នោតយកតាមប្រព័ន្ធសមាមាត្រខេត្តក្រុង៥ឆ្នាំម្តង។ គណបក្សនយោបាយត្រូវចុះឈ្មោះចូលរួមប្រកួតប្រជែង តាមការរៀបចំចាត់ចែងដោយគណកម្មាធិការជាតិរៀបចំការបោះឆ្នោត។ គណបក្សឈ្នះឆ្នោតនឹងត្រូវរៀបចំរាជរដ្ឋាភិបាលនិងត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រីអមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីជាសមាជិក តែងតាំងដោយព្រះមហាក្សត្រ បន្ទាប់ពីការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដោយរដ្ឋសភាតាមសំឡេងភាគច្រើនដាច់ខាត (៥0%+១)។ នាយករដ្ឋមន្ត្រីត្រូវជាសមាជិករដ្ឋសភាមកពីគណបក្សឈ្នះឆ្នោត ជាគណបក្សដែលឈ្នះអាសនៈក្នុងរដ្ឋសភាច្រើនជាងគេ។

ទី៥ ការកែសម្រួលការរៀបចំការបោះឆ្នោតរដ្ឋសភាដើម្បីធានាដំណើរការបោះឆ្នោតឲ្យកាន់តែមានទំនុកចិត្ត (២0១៤) ជាការបន្តការខិតខំកែទម្រង់ស៊ីជម្រៅនៃប្រសិទ្ធិភាពការបោះឆ្នោត។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ២0១៣ បញ្ហាពុំព្រមទទួលស្គាល់លទ្ធផលបោះឆ្នោតពីគណបក្សចាញ់ឆ្នោតនៅតែមានបន្តតាមរូបភាពប្រមូលផ្តុំធ្វើបាតុកម្ម និងធ្វើពហិការពុំព្រមចូលប្រជុំរដ្ឋសភា និងបានប្រែក្លាយជាអំពើហឹង្សា និងបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់នយោបាយប្រជាធិបតេយ្យ និងសេចក្តីថ្លៃថ្នូររបស់ប្រទេសជាតិ។ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានព្រមព្រៀងគ្នារៀបចំការកែទម្រង់ការបោះឆ្នោត ដោយការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ប្រែក្លាយគណកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅជាស្ថាប័នធម្មនុញ្ញ (២0១៤)។ រៀបចំធ្វើច្បាប់វិសោធនកម្មច្បាប់បោះឆ្នោត កែសម្រួលប្រព័ន្ធចុះឈ្មោះការបោះឆ្នោតដើម្បីពង្រឹងសណ្តាប់ធ្នាប់ជាថ្មីមានចំនុចសំខាន់ៗ ជាច្រើនត្រូវបានដោះស្រាយដើម្បីធានានូវសណ្តាប់ធ្នាប់រៀបរយ សេចក្តីថ្លៃថ្នូរក្នុងការបោះឆ្នោត និងក្រោយការបោះឆ្នោតឲ្យកាន់តែរឹងមាំ ក្នុងនោះមានដំណោះស្រាយសំខាន់មួយបានកំណត់ថា គណបក្សណាដែលនៅតែបន្តមិនព្រមចូលរួមប្រជុំរដ្ឋសភាតាមការកោះហៅរបស់ព្រះមហាក្សត្រ ឬពុំព្រមចូលស្បថចូលកាន់តំណាង ត្រូវចាត់ទុកថាបានបោះបង់ចោលអាសនៈទាំងស្រុង ហើយគណកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបែងចែងអាសនៈជាថ្មីស្របតាមនីតិវិធីច្បាប់ជាធរមាន។ ការកែទម្រង់ការរៀបចំការបោះឆ្នោតនេះ ជាការវិវត្តមួយថ្មី ក្នុងការផ្តល់នូវការធានា

ការពារការប្រកួតប្រជែងរវាងគណបក្សត្រូវមានភាពស្មោះត្រង់ និងតម្លាភាព និងត្រូវគោរពចំពោះលទ្ធផលបោះឆ្នោតដែលជាឆន្ទៈរបស់ប្រជារាស្ត្រខ្មែរទាំងមូល។

ទី៦ ដំណើរការច្បាប់លើគណបក្សនយោបាយ (២០១៧) ដើម្បីធានាការគោរពរដ្ឋធម្មនុញ្ញនិងច្បាប់ស្តីពីគណបក្សនយោបាយ ជាដំណាក់កាលវិវត្តថ្មីចុងក្រោយបំផុត។ នៅក្នុងសង្គមប្រជាធិបតេយ្យ ការកំណត់វិធានការច្បាប់រំលាយគណបក្សនយោបាយដែលប្រឆាំងនឹងរដ្ឋ ឬប្រឆាំងនឹងដំណើរការប្រជាធិបតេយ្យ មានភាពខុសៗគ្នា អាស្រ័យទៅតាមវប្បធម៌នយោបាយរបស់ប្រទេសនីមួយៗ។ ជាក់ស្តែងនៅក្នុងប្រទេសអាឡឺម៉ង់ បារាំង អ៊ីតាលី អេស្បាញ់ ឬថៃឡង់ គេប្រកាន់យកជម្រើសរំលាយចោលតាមផ្លូវច្បាប់ដោយអំណាចតុលាការកំពូល ឬតុលាការធម្មនុញ្ញ ដើម្បីរំលាយគណបក្សនយោបាយ និង ហាមប្រាមអ្នកនយោបាយមិនឲ្យធ្វើនយោបាយមួយរយៈ ប្រសិនបើបានរកឃើញថា សកម្មភាពរបស់គណបក្សនយោបាយនោះ បានរំលោភលើរដ្ឋធម្មនុញ្ញ ច្បាប់ ឬលទ្ធិប្រជាធិបតេយ្យ។ ប៉ុន្តែដោយឡែកនៅប្រទេសមួយចំនួនទៀតគេប្រកាន់យកជម្រើសផ្សេង ដូចជាប្រទេសអង់គ្លេស អាមេរិក ឬជប៉ុនក្តីដោយអនុវត្តត្រឹមវិធានការច្បាប់ពិន័យលើបុគ្គល ឬអនុវត្តទោសព្រហ្មទណ្ឌលើបុគ្គល។ ទោះជាយ៉ាងណាក្តី រដ្ឋប្រជាធិបតេយ្យប្រកាន់ជម្រើសទៅតាមបរិបទវប្បធម៌នយោបាយរបស់ផងគេ។

ទី៧ ការកែសម្រួលសមាជិករាជរដ្ឋាភិបាល (ច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ២០១៨) ត្រូវបានកាត់បន្ថយមួយថ្នាក់(រដ្ឋលេខាធិការ) ដោយកំណត់យកត្រឹមរដ្ឋមន្ត្រីជាសមាជិក។ ការកែសម្រួលនេះ សំដៅពង្រឹងការទទួលខុសត្រូវរបស់ប្រធានស្ថាប័ន (រដ្ឋមន្ត្រី) និងពង្រឹងប្រសិទ្ធភាពប្រជាធិបតេយ្យ និងប្រសិទ្ធភាពអភិបាលកិច្ចល្អ នៅតាមក្រសួងស្ថាប័នរដ្ឋនានា។ អភិបាលកិច្ចល្អ ជាគោលនយោបាយស្នូលរបស់រាជរដ្ឋាភិបាលអាស្រ័យរដ្ឋសភា។

ទី៨ សមាជជាតិជាវេទិការប្រជាធិបតេយ្យមួយកំណត់ដោយរដ្ឋធម្មនុញ្ញ ប៉ុន្តែពុំទាន់បានរៀបចំអនុវត្ត នៅឡើយ។ ករណីនេះមានការជជែកក្នុងចំណោមអ្នកសិក្សានីតិរដ្ឋធម្មនុញ្ញ។ ទោះជាយ៉ាងណាក៏ដោយជាក់ស្តែង សមាជជាតិមិនមានភាពចាំបាច់នៅឡើយទេ នៅក្នុងសង្គមប្រជាធិបតេយ្យ ពហុបក្ស។ ម៉្យាងទៀត គេឃើញមានការរៀបចំដំណើរការវេទិការសាធារណៈមួយចំនួនជាបន្តបន្ទាប់នៅក្នុងអំណាចនីតិប្រតិបត្តិ (ចាប់ពីឆ្នាំ២០១៣)។ រាជរដ្ឋាភិបាលបានបង្កើតវេទិការសាធារណៈមានលក្ខណៈប្រជាធិបតេយ្យ ដោយផ្ទាល់ជាច្រើនយន្តការ ដើម្បីបំពេញបន្ថែមក្រៅពីដំណើរការប្រជាធិបតេយ្យសភាតំណាង (១) វេទិការសាធារណៈថ្នាក់មូលដ្ឋានឃុំសង្កាត់រៀបចំឡើង ដើម្បីពង្រឹងប្រសិទ្ធភាពការអនុវត្តគោលនយោបាយរាជរដ្ឋាភិបាលនិងការដោះស្រាយបញ្ហាថ្នាក់មូលដ្ឋាននៅហ្នឹងកន្លែង (២) វេទិការវាជរដ្ឋាភិបាល និងវិស័យឯកជនរៀបចំឡើងដើម្បីពង្រឹងប្រសិទ្ធិភាពអភិបាលកិច្ចល្អ និងប្រសិទ្ធិភាពនៃដំណើរការកែទម្រង់គោលនយោបាយថ្នាក់ជាតិ និង (៣) វេទិការឧត្តមក្រុមប្រឹក្សាពិគ្រោះយោបល់ដែលមានសមាសភាពមកពីគណបក្សក្រៅរដ្ឋសភា និងគណបក្សកាន់អំណាច រៀបចំបង្កើតឡើងដើម្បីពិគ្រោះយោបល់ដោះស្រាយបញ្ហាជាតិទូទៅនានានិង (៤) រដ្ឋាភិបាលឌីជីថលជាពិសេស Facebook Page របស់សម្តេចតេជោនាយករដ្ឋមន្ត្រីជាយន្តការផ្សព្វផ្សាយសកម្មភាព និងការទទួលស្តាប់មតិមហាជន។ នេះជាវឌ្ឍនភាពនៃសីល្បៈប្រជាធិបតេយ្យកម្ពុជា។ វេទិការសាធារណៈ និងបណ្តាញសង្គម (Digital Platform) ជាយន្តការសំខាន់ក្នុងការពង្រីកការចូលរួម និងការពង្រីកនូវលំហសេរីភាព។

ស្របគ្នានឹងវឌ្ឍនភាពនៃដំណើរការប្រជាធិបតេយ្យ ក៏មាននិន្នាការវិវត្តអវិជ្ជមានដែលធ្វើឲ្យមានឥទ្ធិពលប៉ះពាល់ដល់តម្លៃប្រជាធិបតេយ្យសេរីពហុបក្ស ដែលត្រូវពិនិត្យសិក្សាដោយការប្រុងប្រយ័ត្ន។ ក្រុមអ្នកនយោបាយមួយចំនួនកំពុងធ្វើនយោបាយក្រៅក្របខណ្ឌនៃច្បាប់ជាបុគ្គលក្តី ជាក្រុមក្តី ជាគណបក្សក្តី ធ្វើសកម្មភាពប្រឆាំងលើដំណើរការប្រជាធិបតេយ្យ និងឃោសនាប្រឆាំងបរិហារលើរាជរដ្ឋាភិបាលជាប់ឆ្នោតស្របច្បាប់និងគណបក្សកាន់អំណាចដោយការញុះញង់បង្កអរិភាព និងអស្ថិរភាពនៅតាមវេទិការបណ្តាញសង្គមជាហូរហែរ ប៉ះពាល់ដល់តម្លៃវប្បធម៌ប្រជាធិបតេយ្យដែលកំពុងវិវត្តជាវិជ្ជមាន។

តារាងនីតិកាលបោះឆ្នោតជ្រើសតាំងរដ្ឋសភា

នីតិកាលរដ្ឋសភា	គណបក្ស ឈរឈ្មោះ	ចំនួនអ្នកទៅ បោះឆ្នោត	គណបក្សឈ្នះ អាសនៈក្នុងរដ្ឋសភា	រាជរដ្ឋាភិបាល
ទី១ (១៩៩៣-១៩៩៨)	២៣	៨៦.៧៨%	៤ (ហ៊ុនស៊ីនប៉ិច)	រដ្ឋាភិបាលចំរុះ
ទី២ (១៩៩៨-២០០៣)	៣៩	៩៣.៧៤%	៣ (ប្រជាជន)	រដ្ឋាភិបាលចំរុះ
ទី៣ (២០០៣-២០០៨)	២៣	៨៣.២២%	៤ (ប្រជាជន)	រដ្ឋាភិបាលចំរុះ
ទី៤ (២០០៨-២០១៣)	១១	៧៥.២១%	៥ (ប្រជាជន)	រដ្ឋាភិបាលចំរុះ
ទី៥ (២០១៣-២០១៨)	០៨	៦៩.៦១%	២ (ប្រជាជន)	រដ្ឋាភិបាល
ទី៦ (២០១៨-២០២៣)	២០	៨៣.០២%	១ (ប្រជាជន)	រដ្ឋាភិបាល

ជំពូក៥ កម្ពុជាក្នុងបរិបទធំនៃប្រជាធិបតេយ្យសេរីពហុបក្ស

"កម្ពុជានៅតែបន្តក្នុងដំហានរបស់ខ្លួនក្នុងដំណើរការប្រជាធិបតេយ្យសេរីពហុបក្ស"[25]

(១) ពុទ្ធសាសនា ព្រះមហាក្សត្រ លទ្ធិប្រជាធិបតេយ្យ ជាព្រលឹងរួមរបស់ប្រជារាស្ត្រខ្មែរ។ ពុទ្ធសាសនា និងព្រះមហាក្សត្រ ជាតម្លៃធម្មនុញ្ញប្រពៃណី និមត្តិរូបគោរពសក្ការៈ និងមោទនជាតិខ្មែរ។ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ជាតម្លៃធម្មនុញ្ញទំនើបក្នុងដំណើរការនយោបាយ សេដ្ឋកិច្ច និងសង្គមជឿនលឿន។ តម្លៃទាំងពីរនេះមានសុខដុមនីយកម្ម គាំពារគ្នាទៅវិញទៅមក ជានិមត្តិរូបឯកភាពជាតិ។

(២) កម្ពុជាជារដ្ឋឯករាជ អធិបតេយ្យនិងប្រជាធិបតេយ្យ។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើប្រាស់អំណាចតាមការបោះឆ្នោត និងតាមរយៈស្ថាប័នតំណាងរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

(៣) គណបក្សនយោបាយ និងការរៀបចំបោះឆ្នោត ជាអង្គនីតិប្រតិបត្តិសំខាន់នៃការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពុហបក្សនៅកម្ពុជា។ បើគ្មានគណបក្សនយោបាយ បើគ្មានការរៀបចំការបោះឆ្នោតដោយសេរី យុត្តិធម៌ និងជាប់លាប់ នោះគ្មានលទ្ធិប្រជាធិបតេយ្យទេ។ ប្រព័ន្ធពហុបក្សផ្តល់នូវលំហសេរីភាពនិងជម្រើសនយោបាយ រីឯការបោះឆ្នោតជាប់លាប់គឺគោរពនូវអធិបតេយ្យភាពពលរដ្ឋ។ ប្រទេសកម្ពុជាអនុវត្តជាប់លាប់ស្របតាមស្មារតីនេះ និងបាននាំមកសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍរីកចំរើន។

(៤) គណបក្សនយោបាយកម្ពុជា ជាអង្គប្រតិបត្តិនៃលទ្ធិប្រជាធិបតេយ្យ ជាថ្នាលបណ្តុះទស្សនៈនយោបាយ ថ្នាលបណ្តុះវប្បធម៌ប្រជាធិបតេយ្យ ថ្នាលបណ្តុះវប្បធម៌សន្ទនា និងបណ្តុះវប្បធម៌ទទួលខុសត្រូវចំពោះជាតិមាតុភូមិ។ ច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញកំណត់ឲ្យគណបក្សនយោបាយត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះជាផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

(៥) ប្រជាធិបតេយ្យ និងសិទ្ធិសេរីភាព ត្រូវអនុវត្តតាមគោលការណ៍នីតិរដ្ឋ តម្កល់ច្បាប់ជាធំ។ ច្បាប់ជាសេចក្តីសំដែងឆន្ទៈជាតិ តាមរយៈអំណាចនីតិប្បញ្ញត្តិ។ អំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិមានលំនឹងស្ថិរភាពនៅគ្រប់នីតិកាល។ ភាពសុខដុមនីយកម្មរវាងរដ្ឋសភា និងរាជរដ្ឋាភិបាលជាគុណតម្លៃពិសេសនៃប្រជាធិបតេយ្យកម្ពុជា។ អំណាចត្រួតពិនិត្យគ្នាទៅវិញទៅមករវាងអំណាចទាំង៣ ពុំត្រូវអនុវត្តពេញលេញទេ ប៉ុន្តែជំនួសមកវិញសិទ្ធិស្ងួយភាពលើតួនាទី មុខងារ និងការទទួលខុសត្រូវ។

(៦) តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល មិនត្រឹមតែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌល និងតំណាងគណបក្សនយោបាយជាប់ឆ្នោត។ គណបក្សកាន់អំណាចជាគណបក្សឈ្នះឆ្នោតមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា គណបក្សជំទាស់ជាគណបក្សមានអាសនៈតិចនៅក្នុងរដ្ឋសភា ឬនៅក្រៅរដ្ឋសភា មានសិទ្ធិធ្វើសកម្មភាពនយោបាយស្របតាមច្បាប់។ គណបក្សជ្រុលនិយម (Extremist) ដែលធ្វើសកម្មភាពប្រឆាំងនឹងរដ្ឋ ឬប្រឆាំងនឹងដំណើរ

[25] សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (ក្នុង footnote 21)។

ការប្រជាធិបតេយ្យសេរីពហុបក្ស ត្រូវហាមប្រាមដោយច្បាប់ និងជាកម្មវត្ថុរំលាយចោលដោយអំណាចតុលាការ ជាអំណាចឯករាជ្យ។

(៧) អនាគតលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សកម្ពុជាអាស្រ័យលើប្រជាពលរដ្ឋខ្មែរ ពីព្រោះលោកជាម្ចាស់វាសនារបស់ប្រទេសជាតិ។ គណបក្សនយោបាយជាតួអង្គប្រតិបត្តិ។ ពហុបក្សជាលំហសេរីភាពដែលធានាដោយច្បាប់ ប៉ុន្តែការបោះឆ្នោតជាការប្រកួតប្រជែង។ គណបក្សនយោបាយជឿនលឿនដែលតម្កល់ផលប្រយោជន៍ជាតិជាធំ ចូលរួមបម្រើ ចូលរួមដោះស្រាយបញ្ហា ជូនប្រជាពលរដ្ឋជាប់លាប់ រួមសុខរួមទុក្ខជាមួយឃុំសង្កាត់ ឬស្រុកភូមិរបស់ពួកគាត់ ជាកត្តាកំណត់ភាពឈ្នះក្នុងការបោះឆ្នោត។

(៨) ប្រព័ន្ធបោះឆ្នោតកម្ពុជាយកតាមប្រព័ន្ធសមាមាត្រខេត្ត/ក្រុង ជាប្រព័ន្ធបោះឆ្នោតទំនើប និងជាជម្រើសត្រឹមត្រូវមួយ ពីព្រោះប្រព័ន្ធនេះ មានគុណតម្លៃបច្ចេកទេសរឹងមាំ ធានាបាននូវការស្របយក ឆន្ទៈរាស្ត្រចូលក្នុងអាសនៈរដ្ឋសភា មានប្រសិទ្ធភាពខ្ពស់ បើប្រៀបធៀបទៅនឹងប្រព័ន្ធផ្សេងទៀត។

(៩) សេរីភាពសំដែងមតិ (Freedom of Expression) ត្រូវបានកំណត់ក្នុងក្របខណ្ឌច្បាប់ដើម្បីធានាការគោរពសិទ្ធិស្មើភាព សេចក្តីថ្លៃថ្នូរ និងការទទួលខុសត្រូវ។ បណ្តាញសង្គមឌីជីថល (digital social medias) បាននិងកំពុងក្លាយជាវេទិការសំដែងមតិសំខាន់នៅក្នុងសង្គមសេរីភាពកម្ពុជា។

(១០) ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារកម្ពុជា វិវត្តតាមផ្លូវសេដ្ឋកិច្ចទីផ្សារសង្គម (social market economy) ជាសេដ្ឋកិច្ចផ្លូវកណ្តាលមួយ (laissez faire & intervention) រដ្ឋមិនគ្រាន់តែមានភារកិច្ចធានាការពារកម្មសិទ្ធិឯកជន និងការប្រកួតប្រជែងស្មើភាព ប៉ុន្តែធានាការពារយុត្តិធម៌សង្គម និងសេចក្តីថ្លៃថ្នូររបស់មនុស្ស តាមរយៈអនុវត្តក្របខណ្ឌគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់រដ្ឋ។

(១១) កម្ពុជាដើរជួរមុខនៅក្នុងតំបន់ ក្នុងការផ្តល់សច្ចាប័នលិខិតូបករណ៍ច្បាប់អន្តរជាតិ ពាក់ព័ន្ធសិទ្ធិមនុស្ស (Human Rights) ពង្រីកទូលំទូលាយ នូវកិច្ចការពារយុត្តិធម៌ផ្លូវច្បាប់ ក្រោមយុត្តាធិការតុលាការជាតិផង និងអន្តរជាតិផង ក្នុងករណីណាដែលជាបទល្មើសធ្ងន់ធ្ងរ។ ទស្សនសិទ្ធិមនុស្សកម្ពុជាសំដៅសំខាន់លើការគោរពឧត្តមប្រយោជន៍ជាតិ និងកិច្ចការពារលើកស្ទួយសិទ្ធិស្របច្បាប់បុគ្គល។

ឯកសារយោង

១ រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ (ការផ្សាយដោយក្រុមប្រឹក្សាធម្មនុញ្ញ, ២០២១)

២ កិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១ (ភាសាខ្មែរ/អង់គ្លេស/បារាំង, ១៩៩១)

៣ ច្បាប់ និងច្បាប់វិសោធនកម្ម ស្តីពីគណបក្សនយោបាយ (២០២០)

៤ ច្បាប់ និងច្បាប់វិសោធនកម្ម ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (២០១៧)

៥ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារាជសម្បត្តិ (២០០៤)

៦ ថាច់ ត្វាន់, ប្រវត្តិសាស្ត្រប្រជាជាតិខ្មែរ ២០១០ (បកប្រែពីច្បាប់ដើមជាភាសាបារាំង ២០០៩)

៧ ប៉ាង ខាត់, ប្រវត្តិពុទ្ធសាសនានៅខ្មែរ ១៩៦១ និង ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ១៩៧៣

៨ បណ្ឌិត មីសែល ត្រាណេ, ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ការបង្កើតរដ្ឋខ្មែរ (២០០២)

៩ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន, ប្រវត្តិសាស្ត្រកម្ពុជា ក្នុងបរិបទសកលលោក (ស៊ីប៉ា, ២០១៩)

១០ វ៉ាន់ឌី កាអុន ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាពីសម័យអាណានិគមបារាំងមកដល់បច្ចុប្បន្ន (ភាគ១)

១១ អាដេម៉ារ ឡឺក្លែរ, ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ២០០៥ (ប្រែពីច្បាប់ដើមជាភាសាបារាំង ១៩១៤)

១២ នរោត្តម សីហនុ, អនុស្សាវរីយ៍ផ្អែមល្អែម និងជូរចត់ (២០១៧ បកប្រែភាសាខ្មែរដោយន.រណអង្គ)

១៣ នរោត្តម សីហនុ, រាជសកម្មភាពដើម្បីឯករាជ្យបរិបូណ៌នៃកម្ពុជា ភាគ១ (១៩៤០-១៩៥០)

១៤ ហ្សង់ក្លូដ ប៉ូម៉ុងទី និង សែរ ចុង, អ្នកហែហមស្តេចក្លាយជាអ្នកតស៊ូ, វិបត្តិស្រុកខ្មែរ (ប្រែរៀបរៀង ដោយ ភិក្ខុ លឹម វាសនា និងកែសម្រួលដោយ ភិក្ខុ គឹម សំបូរ (បោះពុម្ពផ្សាយ ឆ្នាំ២០០៤)

១៥ ខៀវ សំផន, ប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ (២០០៧)

១៤ David Chandler, A History of Cambodia (4th Edition, 2008)

១៥ Hor Peng, Kong Phallack & Jorg Mensel, សៀវភៅទី១ ស្តីពី Introduction to Cambodian Law (2011), និង សៀវភៅទី២ ស្តីពី Cambodian Constitutional Law (2016)

១៦ Hor Peng, Kong Phallack, Soth Sang Bonn, Perspectives on Cambodian Constitutional Law (NUM Research Series, 2020)

១៧ Hilhelm Hofmeister / Karsten Grabow (Eds.) Political Parties: Functions and Organization in Democratic Societies (KAS 2011)។

១៨ Yigal Mersel, The Dissolution of Political Parties: The Problem of Internal Democracy (2006, Oxford University Press/New York University School of Law)។

១៩ Felix Olusanjo Olatuni, Democracy and the Challenge of the Rule of Law in Developing Democratic Society, (in Beytulhikme An International Journal of Philosophy, Volume 3 Issue 2 December 2013)។

២0 Tadashi Anno, National Identity and Democracy: Lessons from the Case of Japan (Special Forum, December 20, 2018)។

២១ Csaba Gergely Tamas, The Birth of the Parliamentary Democracy in Japan: An History Approach (international center for Japanese studies, Kyoto, Japan)។

២២ Harish C. Mehta, Julie B. Mehta, Strongman: The Extraordinary Life of Hun Sen: From Pagoda Boy to Prime Minister of Cambodia (1999)

២៣ Harish C. Mehta, Warrior Prince: Norodom Ranariddh, Son of King Sihanouk of Cambodia (2001).

២៤ John Locke, Two Treaties of Civil Government (1691)

๒๕ Miles Taylor, English Constitution: Walter Bagehot (2001, Oxford University Press)

๒๖ John Tully, France on the Mekong, A History of the Protectorate in Cambodia, 1863-1953 (University Press of America, 2002)

ឧបសម្ព័ន្ធ១


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ធម្មនុញ្ញ
ការផ្សាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
ព.ស.២៥៦៤ គ.ស.២០២១



ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ឥន្ទ្រទេព

រាជហរិវង្ស ខ្ចគគោសុជាត ទិសុទ្ធិពង្ស

អគ្គមហាបុរសរតន៍ និភរោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមចពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រាទី ១៣៥ និង ១៣៦ នៃ ជំពូក ១៤ ស្តីអំពីអន្តរប្បញ្ញត្តិ នៃ រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រ កម្ពុជា អនុម័តដោយសភាធម្មនុញ្ញ នៅថ្ងៃទី ២១ ខែកញ្ញា គ.ស. ១៩៩៣ ។

ក្រោសង្ហាប់

មាត្រាទី១: ប្រកាសឱ្យប្រើជាផ្លូវការភ្លាម នូវ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ដែលសភាធម្មនុញ្ញបានអនុម័ត នៅថ្ងៃទី ២១ ខែកញ្ញា គ.ស. ១៩៩៣ ។

មាត្រាទី២: សភាធម្មនុញ្ញ បានត្រឡប់ទៅជា រដ្ឋសភា នៃ កម្ពុជា ចាប់ពីពេលនេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣

ន. សីហនុ

នរោត្តម សីហនុ

បុព្វកថា

*****

យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភធំទូលាយ
ប៉ុំប្តើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ក្លីចែងចាំងដូចពេជ្រពណ្ណរាយ,

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ
ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយទ្រុឌទ្រោមឱនថយមហាសោកស្តាយ,

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ធន្ទៈមោះមុត ប្តូរផ្តាច់
រួបរួមគ្នា ពង្រឹងឯកភាពជាតិ រក្សាការពារ ទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា
និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឲ្យទៅជា «កោះសន្តិភាព»
ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្ស
គោរពច្បាប់, ទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិ ឱយបាន
ឈានឡើងរីកចំរើន លូតលាស់ សម្បូររុងរឿងជានិច្ចនិរន្តរ៍ ។

ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅ ៖

ជំពូកទី ១
អំពី អធិបតេយ្យ

មាត្រា ១.-

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនិងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ។

មាត្រា ២.-

បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទី ខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះ ឆ្នាំ ១៩៦៣ - ១៩៦៩ ។

មាត្រា ៣.-

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន ។

មាត្រា ៤.-

បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ : ជាតិ ,សាសនា ,ព្រះមហាក្សត្រ។

មាត្រា ៥.-

ភាសា និងអក្សរ ដែលប្រើជាផ្លូវការ គឺភាសា និងអក្សរខ្មែរ ។

មាត្រា ៦.-

ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

ទង់ជាតិ ភ្លេងជាតិ និងសញ្ញាជាតិ មានកំណត់នៅក្នុងឧបសម្ព័ន្ធ ១, ២ និង ៣ ។

ជំពូកទី ២

អំពី ព្រះមហាក្សត្រ

មាត្រា ៧.-

ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ ។

មាត្រា ៨.-

ព្រះមហាក្សត្រព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ។

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យនិងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ ។

មាត្រា ៩.-

ព្រះមហាក្សត្រទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឲ្យមានភាពទៀងទាត់ ។

មាត្រា ១០.-

របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។

ព្រះមហាក្សត្រទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទសម្រាប់គ្រងរាជសម្បត្តិឡើយ។

មាត្រា ១១.-ថ្មី

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជការៈជាព្រះប្រមុខរដ្ឋបានដូចធម្មតាដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភានិងនាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គក្នុងឋានៈជាព្រះរាជានុសិទ្ធិ ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ ។

តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិនេះ អាចនឹងដូរតស្សរជនផ្សេងទៀត ក្នុងករណីដូចដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ តាមឋានានុក្រមដូចតទៅ :

ក- អនុប្រធានទី ១ ព្រឹទ្ធសភា
ខ- អនុប្រធានទី ១ រដ្ឋសភា
គ- អនុប្រធានទី ២ ព្រឹទ្ធសភា
ឃ- អនុប្រធានទី ២ រដ្ឋសភា

មាត្រា ១២.-ថ្មី

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះអង្គចូលទីវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី ។

មាត្រា ១៣.-ថ្មី

ក្នុងរយៈវេលា ៧ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

-ប្រធានព្រឹទ្ធសភា

-ប្រធានរដ្ឋសភា

-នាយករដ្ឋមន្ត្រី

-សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ

-អនុប្រធានទី ១ និងអនុប្រធានទី ២ ព្រឹទ្ធសភា

-អនុប្រធានទី ១ និងអនុប្រធានទី ២ រដ្ឋសភា

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនឹងមានកំណត់ក្នុងច្បាប់មួយ ។

មាត្រា ១៤.-

ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះរាជវង្សានុវង្សខ្មែរ ដែលមានព្រះជន្មាយុយ៉ាងតិច៣០ ព្រះវស្សា ហើយដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ **អង្គឌួង** ឬ

ព្រះមហាក្សត្រ **នរោត្តម** ឬក៏ព្រះមហាក្សត្រ **ស៊ីសុវត្ថិ** ។

មុនចូលគ្រងរាជសម្បត្តិ ព្រះមហាក្សត្រទ្រង់ថ្លែងសច្ចាប្រណិធាន ដូចមានចែងក្នុងឧបសម្ព័ន្ធ ទី៤ ។

មាត្រា ១៥.-

ព្រះជាយានៃព្រះមហាក្សត្រមានព្រះរាជឋានៈជាព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៦.-

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសិទ្ធិធ្វើនយោបាយ ទទួលតួនាទីជាអ្នកដឹកនាំរដ្ឋ ឬជាអ្នកដឹកនាំរាជរដ្ឋាភិបាល ឬទទួលតួនាទីរដ្ឋបាល ឬនយោបាយឡើយ ។

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជាទុកព្រះរាជកាយពលបំពេញព្រះរាជភារៈបំរើប្រយោជន៍សង្គម មនុស្សធម៌ សាសនា និងជួយព្រះមហាក្សត្រក្នុងព្រះរាជកាតព្វកិច្ច ផ្នែកពិធីការ និងការទូត ។

មាត្រា ១៧.-

ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ហើយដែលមានចែងក្នុងវាក្យខ័ណ្ឌទីមួយនៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញនេះ មិនអាចសុំកែប្រែបានជាដាច់ខាត ។

មាត្រា ១៨.-ថ្មី

ព្រះមហាក្សត្រព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភានិងរដ្ឋសភាដោយព្រះរាជសារ ។

ព្រះរាជសារនេះ ព្រឹទ្ធសភានិងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ ។

មាត្រា ១៩ ថ្មី.-

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី ។

មាត្រា ២០.-

ព្រះមហាក្សត្រទ្រង់ទទួលសវនាការជាផ្លូវការពីរដងក្នុងមួយខែ ឲ្យនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីចូលគាល់រាយការណ៍ទូលថ្វាយទ្រង់ជ្រាបអំពីសភាពការណ៍នៃប្រទេសជាតិ ។

មាត្រា ២១.-

តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារៈកិច្ចមន្ត្រីជាន់ខ្ពស់ ស៊ីវិលនិងយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព ។

តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ ។

មាត្រា ២២.-ថ្មី

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភានិងប្រធានព្រឹទ្ធសភា ។

មាត្រា ២៣.-

ព្រះមហាក្សត្រទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ។ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ។

មាត្រា ២៤.-ថ្មី

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា ។

មាត្រា ២៥.-

ព្រះមហាក្សត្រទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រសិតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសក្រៅ មកប្រចាំព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២៦.-ថ្មី

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភានិងព្រឹទ្ធសភា ។

មាត្រា ២៧.-

ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស ។

មាត្រា ២៨.-ថ្មី

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្តលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ ។

មាត្រា ២៩ ថ្មី.-

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈយោធានិងស៊ីវិលតាមច្បាប់កំណត់ ។

មាត្រា ៣០.-ថ្មី

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមាន ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី ។

ជំពូកទី ៣
អំពី សិទ្ធិ និងករណីយកិច្ច
របស់ប្រជាពលរដ្ឋខ្មែរ

មាត្រា ៣១.-

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិ សេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។

មាត្រា ៣២.-

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាពនិងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឲ្យមានឡើយ ។

មាត្រា ៣៣.-

ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬ ចាប់បញ្ជូនខ្លួនទៅឲ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

មាត្រា៣៤.- ថ្នី (មួយ)

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។

បទប្បញ្ញត្តិដកសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់។

មាត្រា ៣៥.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

មាត្រា ៣៦.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នា នឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គមនិងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់។

មាត្រា ៣៧.-

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

មាត្រា ៣៨.-

ច្បាប់រ៉ាប់រងមិនឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាម បញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

មាត្រា ៣៩.-

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទាមសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

មាត្រា ៤០.-

សេរីភាពក្នុងការដើរឆ្លាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់ របស់ប្រជាពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬ វិលត្រឡប់មកវិញបាន។

ការរក្សាសិទ្ធិមិនឲ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការ

ឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទ ត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គល ត្រូវធ្វើឲ្យស្រប នឹងបញ្ញត្តិច្បាប់ ។

មាត្រា ៤១.-

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារពត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

មាត្រា ៤២.- ថ្មី

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគមនិងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

គណបក្សនយោបាយត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។

មាត្រា ៤៣.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

មាត្រា ៤៤.-

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ បិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយ សមរម្យ និងយុត្តិធម៌ ។

មាត្រា ៤៥.-

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។

ការធ្វើអាជីវកម្ម លើការងាររបស់ស្ត្រី ត្រូវហាមឃាត់ ។

បុរស និង ស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ។

មាត្រា ៤៦.-

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឲ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋនិងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឲ្យនារី ជាពិសេសនារីនៅជនបទ ដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជម្ងឺ ឲ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

មាត្រា ៤៧.-

មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ ។

មាត្រា ៤៨.-

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណ លើកុមារ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឲ្យខូចដល់ការអប់រំ និង ការរៀនសូត្ររបស់កុមារ ឬ ដែលនាំអោយអន្តរាយដល់សុខភាព ឬ សុខុមាលភាពរបស់កុមារ ។

មាត្រា ៤៩.- ថ្មី

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់។

មាត្រា ៥០.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិ ស្របច្បាប់របស់ឯកជន ។

ជំពូកទី ៤

អំពី របបនយោបាយ

មាត្រា ៥១.-ថ្មី

ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលនិងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

មាត្រា ៥២.-

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។ រដ្ឋយកចិត្តទុកដាក់ជាអាទិភាព ចំពោះជីវភាព រស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

មាត្រា ៥៣.- ថ្នី

ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។

ព្រះរាជាណាចក្រកម្ពុជាមិនឈ្លានពានប្រទេសណាជាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។

ព្រះរាជាណាចក្រកម្ពុជាប្រឆាំងជាច់ខាតការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ទោះបីក្រោមរូបភាពណាក៏ដោយ។

ព្រះរាជាណាចក្រកម្ពុជាមិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។

ព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ។

ព្រះរាជាណាចក្រកម្ពុជារក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈយោធា អាវុធ គ្រាប់រំសែវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស។

មាត្រា ៥៤.-

ការផលិត ការប្រើប្រាស់ ការរក្សាទុកអាវុធបរមាណូ អាវុធគីមី ឬ អាវុធវេគ្រាណូ ត្រូវហាមឃាត់ដាច់ខាត ។

មាត្រា ៥៥.-

សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្របនឹង ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិ របស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល ។

ជំពូក ទី ៥
អំពី សេដ្ឋកិច្ច

មាត្រា ៥៦.-

ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់។

មាត្រា ៥៧.-

ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។ ថវិកាជាតិត្រូវបានកំណត់ឲ្យអនុវត្តតាមច្បាប់ ។

របបគ្រប់គ្រងរូបិយវត្ថុនិងប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់។

មាត្រា ៥៨.-

ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រៃក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ ។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់ ។

មាត្រា ៥៩.-

រដ្ឋត្រូវរក្សាការពារបរិដ្ឋាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភោគោគ្គសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ហាមពល ប្រេងកាត និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានដលផល ។

មាត្រា ៦០.-

ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី ។ ការតម្រូវឲ្យលក់ផលិតផលជូនរដ្ឋ ឬការយកភោគផល ឬទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយត្រូវហាមឃាត់ វៀរលែងតែក្នុងករណីពិសេសដែលមានច្បាប់អនុញ្ញាត ។

មាត្រា ៦១.-

រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់ទៅលើ នយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន ។

មាត្រា ៦២.-

រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផល ជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល ។

មាត្រា ៦៣.-

រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឲ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានកម្រិតសមរម្យ ។

មាត្រា ៦៤.-

រដ្ឋហាមឃាត់និងផ្តន្ទាទោសជាទម្ងន់ដល់ជនណា ដែលនាំចូល ផលិត លក់ដូរ គ្រឿងញៀន ទំនិញក្លែងក្លាយ ហួសរយៈពេលប្រើដែល ប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើ ។

ជំពូក ទី ៦

អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច

មាត្រា ៦៥.-

រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កំរិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាដំហានៗ ដើម្បីឲ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយនិងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

មាត្រា ៦៦.-

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញនិងឯកភាព នៅទូទាំងប្រទេសដែលធានាឲ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការនិងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត ។

មាត្រា ៦៧.-

រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើបរាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស ។

រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈនិងឯកជននៅគ្រប់ភូមិសិក្សា ។

មាត្រា ៦៨.-

រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈ សំរាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។

រដ្ឋជួយផ្សព្វផ្សាយនិងលើកតំកើងសាលាបាលីនិងពុទ្ធិកសិក្សា។

មាត្រា ៦៩.-

រដ្ឋមានកាតព្វកិច្ចថែរក្សា និងពង្រីកវប្បធម៌ជាតិ ។

រដ្ឋមានកាតព្វកិច្ចការពារ និងពង្រីកភាសាខ្មែរឲ្យសមស្របនឹងសេចក្តីត្រូវការ ។

រដ្ឋមានកាតព្វកិច្ចថែរក្សានិងការពារ ប្រាសាទបុរាណវត្ថុសិល្បៈបុរាណ និងកែលំអរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ ។

មាត្រា ៧០.-

បទល្មើសទាំងឡាយដែលប៉ះពាល់ ឬទាក់ទងនឹងបេតិកភ័ណ្ឌវប្បធម៌ និងបេតិកភ័ណ្ឌសិល្បៈ ត្រូវផ្តន្ទាទោសជាទម្ងន់ ។

មាត្រា ៧១.-

បរិវេណបេតិកភ័ណ្ឌជាតិក៏ដូចជាបេតិកភ័ណ្ឌដែលបានបញ្ចូលជាបេតិកភ័ណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹត ដែលមិនឲ្យមានសកម្មភាពយោធា ។

មាត្រា ៧២.-

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺនិងព្យាបាលជម្ងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួល

ការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ពសាធារណៈ ។

រដ្ឋរៀបចំឲ្យមានគិលានដ្ឋាន និងមន្ទីរសម្ពដល់ជនបទ ។

មាត្រា ៧៣.-

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារនិងមាតា ។ រដ្ឋរៀបចំឲ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង ។

មាត្រា ៧៤.-

រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។

មាត្រា ៧៥.-

រដ្ឋចាត់ចែងឲ្យមានរបបសន្តិសុខសង្គម ដល់កម្មករនិងនិយោជិត ។

ជំពូកទី ៧

អំពី រដ្ឋសភា

មាត្រា ៧៦.- ថ្មី

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៧៧.-

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ ។

មាត្រា ៧៨.-

នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយ

មុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈ ១២ ខែ ។

ក្នុងករណីនេះព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា ។

ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មី នឹងប្រព្រឹត្តទៅក្នុងរយៈពេល ៦០ ថ្ងៃយ៉ាងយូរ ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក ។

ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានតែការកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៧៩.-

អាណត្តិនៃសមាជិករដ្ឋសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល ។

ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះ មានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗ នៃរដ្ឋសភា ។

មាត្រា ៨០.-

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទ័ណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើន បីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៨១.-

រដ្ឋសភាមានឋវិកាស្វយ័ត សំរាប់ដំណើរការ ។

តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់ ។

មាត្រា ៨២.- ថ្មី

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

មាត្រា ៨៣.-

រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនិមួយៗ មានថិរៈវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិច គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ។

ក្នុងករណីនេះ របៀបវារៈជាក់លាក់នៃសម័យប្រជុំជាវិសាមញ្ញត្រូវផ្សាយដល់ប្រជារាស្ត្រជាមួយនឹងថ្ងៃកំណត់ប្រជុំ ។

មាត្រា ៨៤.-

នៅចន្លោះសម័យប្រជុំរបស់រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភារួមមាន : ប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភា និងប្រធានគណៈកម្មការទាំងអស់របស់រដ្ឋសភា ។

មាត្រា ៨៥.-

សម័យប្រជុំរដ្ឋសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់រដ្ឋសភា លើកលែងតែមានការសំរេចផ្សេង ចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើ និងក្រៅពីកន្លែង និងពីកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់រដ្ឋសភាត្រូវទុកជាខុសច្បាប់ ហើយជាអាសាសូន្យពេញលក្ខណៈ ។

មាត្រា ៨៦.-

ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ រដ្ឋសភាមានសិទ្ធិសំរេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើរដ្ឋសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

នៅពេលដែលប្រទេសជាតិបិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ។

មាត្រា ៨៧.-

ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអាញ្ញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយដែលរដ្ឋសភាបានអនុម័ត ព៉ាប់រងការអនុវត្ត បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា ។

ក្នុងករណីដែលប្រធានរដ្ឋសភាមានធុរៈ មិនអាចបំពេញមុខងារបានដោយហេតុមកពីមានជម្ងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូបត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។

មាត្រា ៨៨.-ថ្មី(ពីរ)

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភា នឹងយកជាការបានលុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៨៩.-

តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយ មកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែលមានសារៈសំខាន់ពិសេស ។

មាត្រា ៩O.- ថ្មី(ពីរ)

រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬ លុបចោលសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៩១.-ថ្មី

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភានិងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។

មាត្រា ៩២.-

ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឲ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអាសាសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ ។

មាត្រា ៩៣.-ថ្មី

ច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលកំណត់ខាងលើ ។

មាត្រា ៩៤.-

រដ្ឋសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំនិងការប្រព្រឹត្តទៅ នៃរដ្ឋសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

មាត្រា ៩៥.-

ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬប្រាសចាកសមាជិកភាព ដែលកើតមានឡើង ៦ខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះ តាមលក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៩៦.-

តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ សំណួរនេះត្រូវសរសេរជាលាយលក្ខអក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។

ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូបឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើង ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូបឬច្រើនរូប ។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។

ចម្លើយរបស់រដ្ឋមន្ត្រីឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ឬសរសេរជាលាយលក្ខអក្សរ ។

ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ ។

ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសំរេចបើកឲ្យមាន ឬមិនឲ្យមានការដដែកដេញដោល ។ បើគ្មានការបើកឲ្យដដែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី នឹងបញ្ចប់សំណួរតែម្តង។

បើមានការបើកឲ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធឬនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ ។

រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សម្រាប់ការឆ្លើយសំណួរ ។

ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសំរាប់ឆ្លើយសំណួរខាងលើនេះមិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រកែទណាមួយបានឡើយ។

មាត្រា ៩៧.-

គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ។

មាត្រា ៩៨.- ថ្មី

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

ជំពូកទី ៨ ថ្មី
អំពីព្រឹទ្ធសភា

មាត្រា ៩៩.-ថ្មី

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន ។

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះនិងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ ។

សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំងនិងជ្រើសតាំងសាជាថ្មីបាន ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោតមានអាយុយ៉ាងតិច ៤០ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត ។

មាត្រា ១០០.-ថ្មី

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។

រីឯសមាជិកព្រឹទ្ធសភាឯទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។

មាត្រា ១០១.-ថ្មី

ការរៀបចំ បែបបទនិងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោតនិងមណ្ឌលបោះឆ្នោត ត្រូវចែងក្នុងច្បាប់មួយ ។

មាត្រា ១០២.-ថ្មី

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

ក្នុងពេលមានសង្គ្រាមឬក្នុងកាល:ទេស:ពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភាត្រូវសំរេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងកាល:ទេស:ដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ ព្រឹទ្ធសភាមានសិទ្ធិសំរេចបញ្ចប់កាល:ទេស:ពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

មាត្រា ១០៣.-ថ្មី

អាណត្តិនៃសមាជិកព្រឹទ្ធសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណ:ជាសកម្ម ជាមួយមុខងារជាតំណាងរាស្ត្រនិងជាមួយមុខងារជាសមាជិកស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

មាត្រា ១០៤.-ថ្មី

សមាជិកព្រឹទ្ធសភា មានអភ័យឯកសិទ្ធិសភា ។

សមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួនឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។ ការចោទប្រកាន់ការចាប់ខ្លួន ការឃាត់ខ្លួនឬការឃុំខ្លួនសមាជិកណាមួយនៃព្រឹទ្ធសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទ័ណ្ឌជាក់ស្តែង ។ ក្នុងករណីចុងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភាឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសំរេច ។

សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

មាត្រា ១០៥.-ថ្មី

ព្រឹទ្ធសភាមានថវិកាស្វ័យតសំរាប់ដំណើរការ ។

សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់ ។

មាត្រា ១០៦.-ថ្នី(មួយ)

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

មាត្រា ១០៧.-ថ្នី

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនីមួយៗមានថិរៈវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ ។

មាត្រា ១០៨.-ថ្នី

នៅចន្លោះសម័យប្រជុំរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាទទួលការកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភារួមមាន : ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភានិងប្រធានគណៈកម្មការទាំងអស់របស់ព្រឹទ្ធសភា ។

មាត្រា ១០៩.-ថ្មី

សម័យប្រជុំព្រឹទ្ធសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់ព្រឹទ្ធសភា លើកលែងតែមានការសំរេចផ្សេងចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើនិងក្រៅពីកន្លែង និងកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់ព្រឹទ្ធសភាត្រូវទុកជាខុសច្បាប់ ហើយអសារសូន្យពេញលក្ខណៈ ។

មាត្រា ១១០.-ថ្មី

ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំរបស់ព្រឹទ្ធសភា ទទួលអាញត្តិច្បាប់ និងសេចក្តីសំរេចចិត្តទាំងឡាយដែលព្រឹទ្ធសភាបានអនុម័ត រ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភានិងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់ព្រឹទ្ធសភា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈ មិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានដម្ងីឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិឬបំពេញបេសកកម្មនៅបរទេស អនុប្រធានព្រឹទ្ធសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានព្រឹទ្ធសភាលាលែងពីមុខតំណែងឬទទួលអនិច្ចកម្ម ព្រឹទ្ធសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។

មាត្រា ១១១.-ថ្មី(ពីរ)

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬ យកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រមហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

មាត្រា ១១២.-ថ្មី

ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភានិងរដ្ឋាភិបាល ។

មាត្រា ១១៣.-ថ្មី

ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រមឬពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

បើព្រឹទ្ធសភាសុំឱ្យកែសំរួលសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ ។ រដ្ឋសភាត្រូវពិនិត្យនិងសំរេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសំរួល ដោយបដិសេធចោលទាំងមូលឬទុកជាបានការខ្លះ ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភានិងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសំរេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់ ។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភានិងព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបាន មុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិនិងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ជាលើកទី ២ នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហនិងយកតាមមតិភាគច្រើនដាច់ខាត ។

សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ណាដែលបានសំរេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

មាត្រា ១១៤.-ថ្នី(មួយ)

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

មាត្រា ១១៥.-ថ្នី

ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែងឬប្រាសចាកសមាជិកភាពដែលកើតមានឡើងប្រាំមួយខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់តាំងឬជ្រើសតាំងជំនួសសមាជិកនោះ តាមលក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា និងក្នុងច្បាប់ស្តីពីការចាត់តាំងនិងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ជំពូកទី ៩ ថ្មី

អំពីសមាជរដ្ឋសភានិងព្រឹទ្ធសភា

មាត្រា ១១៦.-ថ្មី

ក្នុងករណីចាំបាច់ រដ្ឋសភានិងព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។

មាត្រា ១១៧.-ថ្មី

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិដូចមានចែងក្នុងមាត្រា ១១៦ ថ្មី ខាងលើ ព្រមទាំងការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជ នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

ជំពូកទី ១០ ថ្មី

អំពីរាជរដ្ឋាភិបាល

មាត្រា១១៨.- ថ្មី (មួយ)

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីជាសមាជិក។

មាត្រា ១១៩.-ថ្មី (មាត្រា ១០០ ចាស់)

តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត ឱ្យបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្គូរផ្គងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបីរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។

មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦ ។

មាត្រា ១២០.-ថ្មី (មាត្រា ១០១ ចាស់)

មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាពនិងសកម្មភាពខាងវិជ្ជាជីវៈផ្នែកពាណិជ្ជកម្មឬឧស្សាហកម្ម ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ។

មាត្រា ១២១.-ថ្មី (មាត្រា ១០២ ចាស់)

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួន ចំពោះនាយករដ្ឋមន្ត្រីនិងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត ។

មាត្រា ១២២.-ថ្មី (មាត្រា ១០៣ ចាស់)

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលមិនអាចយកសំអាងនៃសេចក្តីបង្គាប់ដោយលាយលក្ខអក្សរឬដោយវាចាអំពីនរណាមួយ ដើម្បីដោះសាឱ្យរួចខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ ។

មាត្រា ១២៣.-ថ្មី (មាត្រា ១០៤ ចាស់)

គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្តាហ៍ ជាប្រជុំធំឬជាប្រជុំពិនិត្យស្រាវជ្រាវ ។

អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចដូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

កំណត់ហេតុនៃអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រី ត្រូវធ្វើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប ។

មាត្រា ១២៤.-ថ្មី (មាត្រា ១០៥ ចាស់)

នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួនឱ្យទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន ។

មាត្រា ១២៥.-ថ្មី (មាត្រា ១០៦ ចាស់)

បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរដោយស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងលក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ បើការទំនេរនេះជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្តីទីជាបណ្តោះអាសន្ន ។

មាត្រា ១២៦.-ថ្មី (មាត្រា ១០៧ ចាស់)

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះនិងក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួនរដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភាសំរេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ១២៧.-ថ្មី (មាត្រា ១០៨ ចាស់)

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

ជំពូកទី ១១ ថ្មី

អំពីអំណាចតុលាការ

មាត្រា ១២៨.-ថ្មី (មាត្រា ១០៩ ចាស់)

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការធានារក្សាអនាគតិនិងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូលនិងសាលាដំរះក្តីគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់ ។

មាត្រា ១២៩.-ថ្មី (មាត្រា ១១០ ចាស់)

ការដំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធីនិងច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិដំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់និងឱ្យអស់ពីដួងចិត្តនិងសម្បជញ្ញៈរបស់ខ្លួន ។

មាត្រា ១៣០.-ថ្មី (មាត្រា ១១១ ចាស់)

គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។

មាត្រា ១៣១.-ថ្មី (មាត្រា ១១២ ចាស់)

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

មាត្រា ១៣២.-ថ្មី (មាត្រា ១១៣ ចាស់)

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

មាត្រា ១៣៣.-ថ្មី (មាត្រា ១១៤ ចាស់)

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។

មាត្រា ១៣៤.-ថ្មី (មាត្រា ១១៥ ចាស់)

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយដែលនឹងកំណត់សមាសភាពនិងមុខងារ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រមនិងព្រះរាជអាជ្ញាអមសាលាដំរះក្តីទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រមនិងព្រះរាជអាជ្ញា ត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូលឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រមឬព្រះរាជអាជ្ញា ។

មាត្រា ១៣៥.-ថ្មី (មាត្រា ១១៦ ចាស់)

លក្ខន្តិក:នៃចៅក្រមនិងព្រះរាជអាជ្ញានិងការរៀបចំអង្គការតុលាការនឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា ។

ជំពូកទី ១២ ថ្មី
អំពីក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រា ១៣៦.- ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

មាត្រា ១៣៧.- ថ្មី (មាត្រា ១១៨ ចាស់)

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ប្តីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធានមានសំឡេងឧត្តមានុភាពក្នុងករណីបែកសំឡេងជាពីរស្មើគ្នា ។

មាត្រា ១៣៨.- ថ្មី (មាត្រា ១១៩ ចាស់)

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាទៅ ខាងច្បាប់ ខាងរដ្ឋបាល ខាងការទូតឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើនក្នុងការងារ ។

មាត្រា ១៣៩.- ថ្មី

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រម ក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព ។

មាត្រា ១៤០.- ថ្មី

ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភាឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នោះ ត្រូវប្រកាសឱ្យប្រើ ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានិងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឱ្យប្រើ ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេច ក្នុងរយៈពេលសាមសិប (៣០)ថ្ងៃយ៉ាងយូរ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភានិងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្របឬមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ១៤១.- ថ្មី

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួនមួយភាគដប់ឬតុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រឬប្រធានរដ្ឋសភាឬសមាជិកព្រឹទ្ធសភាឬប្រធានព្រឹទ្ធសភាដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

មាត្រា ១៤២.- ថ្មី (មាត្រា ១២៣ ចាស់)

បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាមិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសឱ្យប្រើឬយកទៅអនុវត្តបានឡើយ ។

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសំរេចបិទផ្លូវតវ៉ា ។

មាត្រា ១៤៣.- ថ្មី (មាត្រា ១២៤ ចាស់)

ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ។

មាត្រា ១៤៤.- ថ្មី (មាត្រា ១២៥ ចាស់)

ច្បាប់រៀបចំអង្គការមួយនឹងកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

ជំពូកទី ១៣ ថ្មី
អំពីការគ្រប់គ្រងរដ្ឋបាល

មាត្រា ១៤៥.- ថ្មី (មួយ)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

មាត្រា ១៤៦.- ថ្មី (មួយ)

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ ។

ជំពូកទី ១៤ ថ្មី
អំពីសមាជជាតិ

មាត្រា ១៤៧.-ថ្មី (មាត្រា ១២៨ ចាស់)

សមាជជាតិបើកឱ្យប្រជារាស្ត្រជ្រាបដោយផ្ទាល់ អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិនិងលើកបញ្ហា និងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ ។

ប្រជារាស្ត្រខ្មែរទាំងពីរភេទមានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ ។

មាត្រា ១៤៨.- ថ្មី (មាត្រា ១២៩ ចាស់)

សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំ នៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ។

សមាជជាតិប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។

មាត្រា ១៤៩.- ថ្មី

សមាជជាតិអនុម័តសំណូមពរជូនព្រឹទ្ធសភា ជូនរដ្ឋសភា និងជូនរដ្ឋអំណាចពិចារណា ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជជាតិនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

ជំពូកទី ១៥ ថ្មី(ពីរ)

អំពីអង្គការរៀបចំការបោះឆ្នោត

មាត្រា ១៥០.- ថ្មី (ពីរ)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គការដែលមានសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

មុខងារជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាចធ្វើជាសមាជិកនៃគណបក្សនយោបាយ ឬធ្វើជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬក្រុមហ៊ុនពាណិជ្ជកម្មណាមួយបានឡើយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វយ័តសម្រាប់ដំណើរការ ។

មាត្រា ១៥១.-ថ្មី(ពីរ)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមាសភាពប្រាំបួនរូបដែលទទួលអាណត្តិប្រាំឆ្នាំ ។ សមាសភាពបួនរូបត្រូវជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល បួនរូបត្រូវជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និងមួយរូបត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដំណើរការរៀបចំឲ្យមានការជ្រើសរើសដោយបើកចំហ និងតម្លាភាព នូវសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាក់ជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បាត់បង់សមាជិកភាពរបស់ខ្លួន គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវចាត់នីតិវិធីជ្រើសរើស សមាសភាពថ្មីជំនួស ក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ គិតពីថ្ងៃបាត់បង់សមាជិកភាព ។ នីតិវិធីលំអិតនៃការជ្រើសរើសសមាសភាពថ្មី ជំនួស ត្រូវកំណត់ដោយឡែកក្នុងច្បាប់ ។

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ចដើម្បីចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

ជំពូកទី ១៦ ថ្នី (ពីរ)

អំពីអាទុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ

មាត្រា ១៥២.- ថ្នី (ពីរ មាត្រា ១៥០ ថ្នី)

រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាជាច់ខាត ។

មាត្រា ១៥៣.- ថ្នី (ពីរ មាត្រា ១៥១ ថ្នី)

ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ១៥៤.- ថ្នី (ពីរ មាត្រា ១៥២ ថ្នី)

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឲ្យធ្វើនៅពេលប្រទេសជាតិបិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។

មាត្រា ១៥៥.- ថ្មី (ពីរ មាត្រា ១៥៣ ថ្មី)

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។



ជំពូកទី ១៧ ថ្មី

អំពីអន្តរប្បញ្ញត្តិ

មាត្រា ១៥៦.- ថ្មី (ពីរ មាត្រា ១៥៤ ថ្មី)

រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឲ្យចូលជាធរមានភ្លាម ដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៥៧.- ថ្មី (ពីរ មាត្រា ១៥៥ ថ្មី)

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធានអនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ក្នុងប្រទេសទាមទារ ។

មាត្រា ១៥៨.- ថ្មី (ពីរ មាត្រា ១៥៦ ថ្មី)

ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៣ ថ្មី និង ១៤ ។

មាត្រា ១៥៩.- ថ្មី (ពីរ មាត្រា ១៥៧ ថ្មី)

នីតិកាលទី ១ នៃព្រឹទ្ធសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

សម្រាប់នីតិកាលទី ១ នៃព្រឹទ្ធសភា :

-សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប ។


-ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី ១ អនុប្រធានទី ២ នៃព្រឹទ្ធសភា ។

-សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិក នៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ។

-កិច្ចប្រជុំជាសមាជរដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។

មាត្រា ១៦០.- ថ្មី (ពីរ មាត្រា ១៥៨ ថ្មី)

ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោលលើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។



រដ្ឋធម្មនុញ្ញនេះ ត្រូវបានសភាធម្មនុញ្ញអនុម័ត
នៅភ្នំពេញថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ នាសម័យប្រជុំពេញអង្គលើកទី ២
ភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣

ប្រធាន



សឺន សាន

ទង់ជាតិ



ស្នែងជាតិ នគរវាដ

១- សូមពួកទេព្តា រក្សា មហាក្សត្រយើង
ឲ្យ បានរុងរឿង ដោយជ័យមង្គល សិរីសួស្តី
យើងខ្ញុំព្រះអង្គ សូមជ្រកក្រោម ម្លប់ព្រះបារមី
នៃព្រះន-របតី ឥន្ទ្រក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ បុរាណថ្កើងថ្កាន ៗ

២- ប្រាសាទសីលា កំចាំងកណ្តាលព្រៃ
គួរឲ្យស្រមៃយ ឆឹកដល់យសសក្តិ មហានគរ
ជាតិខ្មែរដូចថ្ម គង់ឋិតនៅល្អ រឹងប៉ឹងជិងរ
យើងសច្ចឹមពរ តំពូព្រោងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ ៗ

៣- គ្រប់វត្តអារាម ពួតែសូរសំឡេងធម៌
សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា
គង់តែទេវតា ឆាំងជួយជ្រោមជ្រែងផ្តត់ផ្តង់ប្រយោជន៍ឲ្យ
ជាប់ប្រទេសខ្មែរ ជាមហានគរ ៗ

សញ្ញាជាតិ



សច្ចាប្រណិធាន
នៃ
ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

ខ្ញុំសាំងសច្ចាថានឹងប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ និង ច្បាប់ អាំងឡាយនៃព្រះរាជាណាចក្រ ហើយនឹងតាំងចិត្តធ្វើផល ប្រយោជន៍ដល់រដ្ឋ និង ប្រជារាស្ត្រ ។

សច្ចាប្រណិធាន

ទូលព្រះបង្គំ
យើងខ្ញុំ
ប្រធាន អនុប្រធាន និង សមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
សូមធ្វើសច្ចាប្រណិធាន
នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ
និងទេវតារក្សាស្វេតច្ឆត្រ
ដូចតទៅ ៖

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូន ចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតិភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ច នូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬសំរាប់ភាគីរៀងៗខ្លួនឡើយ ។
- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាបូរផ្តោចំហានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ

• ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា

• អធិបតេយ្យភាពជាតិពេញបរិបូណ៌

• បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មាន ក្នុងជំនាន់ឆ្នាំ ១៩៦៣ ដល់ ១៩៦៩

• ឯកភាពជាតិ ហើយមិនអនុញ្ញាតឲ្យមានការបែងចែង ឬការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធ សំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឲ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុង នៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិ របស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាត នូវផលប្រយោជន៍បរទេស ហើយធ្វើឲ្យខូចខាតដល់ផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុង នូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុក នូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំង អំពើពុករលួយ គ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និង សន្តិភាពជាតិ ដើម្បីភាព សម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿង ថ្កើងថ្កាន នៃ មាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំ គ្រប់រូប ។

សច្ចាប្រណិធាន

ទូលព្រះបង្គំ
យើងខ្ញុំ
នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល
សូមធ្វើសច្ចាប្រណិធាន
នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ
និងទេវតារក្សាស្វេតច្ឆត្រ
ដូចតទៅ ៖

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្ម ដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូន ចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ចទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតិភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថាមិនកេងប្រវ័ញ្ច នូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬសំរាប់ភាគី រៀងៗខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ

• ឯករាជ្យភាពទាំងស្រុង នៃមាតុភូមិកម្ពុជា

• អធិបតេយ្យភាពជាតិពេញបរិបូណ៌

• បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មាន ក្នុងដំនាន់ឆ្នាំ ១៩៦៣ ដល់ ១៩៦៩

• ឯកភាពជាតិ ហើយមិនអនុញ្ញាតឲ្យមានការបែងចែង ឬការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធ សំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឲ្យជនណាក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុង នៃកម្ពុជា ឬមកបង្គាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិ របស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាត នូវផលប្រយោជន៍បរទេស ហើយធ្វើឲ្យខូចខាតដល់ផលប្រយោជន៍ របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយ លើផ្ទៃរាបជាតិ និងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុង នូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុក នូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ច ទាំងក្នុងបច្ចុប្បន្នទាំង

ក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភា និង ពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស ដូច មានចែងក្នុងសេចក្តីប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំង អំពើពុករលួយ គ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និង សន្តិភាពជាតិ ដើម្បីភាព សម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿង ថ្កើងថ្កាន នៃ មាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំ គ្រប់រូប ។

សច្ចាប្រណិធាន

ទូលព្រះបង្គំ

យើងខ្ញុំ

ប្រធាន អនុប្រធាននិងសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

សូមធ្វើសច្ចាប្រណិធាន

នៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ព្រះភ័ក្ត្រនៃសម្តេចព្រះសង្ឃរាជ

និងទេវតារក្សាស្វេតច្ឆត្រ

ដូចតទៅ :

- ក្នុងពេលប្រតិបត្តិការ តាមមុខតំណែងខ្លួន និងក្នុងការបំពេញបេសកកម្មដែលប្រជារាស្ត្រកម្ពុជា បានប្រគល់ជូនចំពោះទូលព្រះបង្គំយើងខ្ញុំគ្រប់ៗរូប ទូលព្រះបង្គំយើងខ្ញុំសូមប្តេជ្ញាគោរពរដ្ឋធម្មនុញ្ញ បំរើជានិច្ចទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិនិងមាតុភូមិកម្ពុជា ។ ទូលព្រះបង្គំយើងខ្ញុំ សូមសច្ចាថា មិនកេងប្រវ័ញ្ចនូវផលប្រយោជន៍ជាតិ សំរាប់ផ្ទាល់ខ្លួន ឬសំរាប់គ្រួសារ ឬសំរាប់បក្សពួក ឬសំរាប់ភាគីរៀងៗខ្លួនឡើយ ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ច ទាំងក្នុងបច្ចុប្បន្នទាំងក្នុងអនាគតនូវ :

  • ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា

• អធិបតេយ្យភាពជាតិពេញបរិបូណ៌

• បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់ នៅក្នុងព្រំដែនដីគោក និងព្រំដែនសមុទ្រ ដែលកម្ពុជាធ្លាប់មាន ក្នុងដំនាន់ឆ្នាំ១៩៦៣ ដល់១៩៦៩

• ឯកភាពជាតិ ហើយមិនអនុញ្ញាតឱ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ ។

- ទូលបង្គំយើងខ្ញុំ សូមប្តេជ្ញារក្សាទុកជានិច្ច ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគតនូវអព្យាក្រឹត្យភាព និងភាពមិនចូលបក្សសម្ព័ន្ធសំរាប់កម្ពុជា ហើយមិនអនុញ្ញាតជាដាច់ខាតឱ្យជនណាមួយក៏ដោយ ដែលចង់ជ្រៀតជ្រែកចូលក្នុងផ្ទៃក្នុងនៃកម្ពុជា ឬមកបង្កាប់បញ្ជាចំពោះគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាបានឡើយ ។ ទូលព្រះបង្គំយើងខ្ញុំ មិនបំរើជាដាច់ខាតនូវផលប្រយោជន៍បរទេស ហើយធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិកម្ពុជាឡើយ ។

- ក្នុងការដោះស្រាយបញ្ហាទាំងឡាយលើផ្នែករាបជាតិនិងអន្តរជាតិ ទូលព្រះបង្គំយើងខ្ញុំ នឹងបំបាត់ចោលទាំងស្រុងនូវអំពើហឹង្សាគ្រប់បែបយ៉ាង ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា សូមរក្សាទុកនូវសិទ្ធិកាន់អាវុធតស៊ូប្រឆាំងនឹងការរំលោភឈ្លានពានមកពីក្រៅ ដើម្បីការពារជាតិមាតុភូមិខ្លួន ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាគោរពជានិច្ចទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវលទ្ធិប្រជាធិបតេយ្យ សេរីនិយម ដែលមានរបបសភានិងពហុបក្ស ព្រមទាំងមានការគោរពយ៉ាងម៉ឺងម៉ាត់ចំពោះសិទ្ធិមនុស្ស

ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ។

- ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាង ប្រឆាំងអយុត្តិធម៌សង្គម ហើយតស៊ូដើម្បីផ្សះផ្សាជាតិ ដើម្បីឯកភាពជាតិ ដើម្បីសន្តិភាពសង្គម និង សន្តិភាពជាតិ ដើម្បីភាពសម្បូរសប្បាយ នៃប្រជារាស្ត្រកម្ពុជា និងដើម្បីភាពរុងរឿងថ្កើងថ្កាន នៃមាតុភូមិកម្ពុជា ជាទីគោរពសក្ការៈ និងជាទីស្នេហានៃទូលព្រះបង្គំយើងខ្ញុំគ្រប់រូប ។

គណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ

បានអនុម័តដោយសភាធម្មនុញ្ញនាសម័យប្រជុំពេញអង្គលើកទី ១

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣

១-	ឯកឧត្តមសម្តេចប្រធានសភាធម្មនុញ្ញឬឯកឧត្តមអនុប្រធានសភាធម្មនុញ្ញ « ករណីសម្តេចប្រធានអវត្តមាន »		ជាប្រធាន *
២-	ឯកឧត្តម	ចែម ស្ងួន	ជាអនុប្រធាន
៣-	ឯកឧត្តមបណ្ឌិត	តាវ សេងហួរ	ជាអ្នករាយការណ៍
៤-	ឯកឧត្តម	កាន់ ម៉ន	ជាសមាជិក
៥-	ឯកឧត្តម	គាត ឈន់	ជាសមាជិក
៦-	ឯកឧត្តម	ឈួរ លាងហួត	ជាសមាជិក
៧-	ឯកឧត្តម	ថោ ប៉េងលាត	ជាសមាជិក
៨-	ឯកឧត្តម	សម រង្សី	ជាសមាជិក
៩-	អ្នកអង្គម្ចាស់	ស៊ីសុវត្ថិ សិរីឥន្ទ	ជាសមាជិក
១០-	ឯកឧត្តម	សឺន ស៊ូប៉ែរ៉ី	ជាសមាជិក
១១-	ឯកឧត្តម	សោម ចាន់បុត្រ	ជាសមាជិក
១២-	ឯកឧត្តម	អ៊ុន នឹង	ជាសមាជិក
១៣-	ឯកឧត្តម	ឡួយ ស៊ឹមឈាង	ជាសមាជិក
១៤-	ឯកឧត្តម	ជាម យៀប	ជាសមាជិកបំរុង
១៥-	ឯកឧត្តម	ប៉ុល ហំម	ជាសមាជិកបំរុង
១៦-	ឯកឧត្តម	ពូ សុធីរៈ	ជាសមាជិកបំរុង
១៧-	ឯកឧត្តម	សរ សាអាត	ជាសមាជិកបំរុង

១៨- ឯកឧត្តម	អ៊ឹង គៀត	ជាសមាជិកបំរុង
១៩- ឯកឧត្តម	អ៊ុក រ៉ាប៊ុន	ជាសមាជិកបំរុង
២០- ឯកឧត្តម	អ៊ុង ផន	ជាសមាជិកបំរុង
២១- ឯកឧត្តម	ឯក សំអុល	ជាសមាជិកបំរុង
២២- ឯកឧត្តម	សាយ បូរី	ជាអ្នកជំនាញការ
២៣- ឯកឧត្តម	ចាន់ សុខ	ជាអ្នកជំនាញការ
២៤- ឯកឧត្តម	ឈន អៀម	ជាអ្នកជំនាញការ
២៥- ឯកឧត្តម	ហេង វង្សប៊ុនធាត	ជាអ្នកជំនាញការ
២៦- ឯកឧត្តម	ខៀវ រ៉ាដា	ជាអ្នកជំនាញការ

<u>កំណត់សំគាល់</u> : * យោងជំពូក៧ប្រការ១៨ស្តីពីការគណៈកម្មការ
និង ប្រធានគណៈកម្មការសភាធម្មនុញ្ញ

ច្បាប់ធម្មនុញ្ញបន្ថែម
សំដៅ
ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ



ព្រះរាជក្រម

នស/រកម/ ០៧០៤/ ០០១ **យើង**

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ខ្ពតគោសុជាត ទិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៤
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ នៃព្រឹទ្ធសភា នាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤
- យោងតាមសំណើ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០០៤ របស់ព្រឹទ្ធសមាជិករដ្ឋសភា នីតិកាលទី៣

ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

ច្បាប់ធម្មនុញ្ញបន្ថែម
សំដៅ
ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

មាត្រា ១.-

ច្បាប់ធម្មនុញ្ញនេះ មានគោលដៅធានាក្នុងគ្រប់កាល:ទេស:នូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមស្របតាមតម្រូវការនៃភាពចាំបាច់ ។

មាត្រា ២.-

នៅដើមនីតិកាលថ្មីនីមួយៗ រដ្ឋសភា ក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភា មុននឹងផ្តើមការងាររបស់ខ្លួន និង ក្រោយពេលសំរេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗ អាចចាប់ផ្តើមអនុម័ត អត្ថបទដែលមានចារិក ជារដ្ឋធម្មនុញ្ញ ឬ ច្បាប់ដើម្បីអនុវត្តបាននូវគោលដៅដូចមានចែងក្នុងមាត្រា ១ ។

អត្ថបទទាំងនេះ ក្រោយពីបានត្រូវទទួលការបោះឆ្នោតអនុម័តដោយរដ្ឋសភារួចហើយ ត្រូវតែបានទទួលជាបន្ទាន់នូវចំណាត់ការដោយរួសរាន់ពីសំណាក់ព្រឹទ្ធសមាជិករដ្ឋសភា តាមនីតិវិធីកំណត់សំរាប់ អត្ថបទទាំងនោះ រហូតដល់ពេលដែលត្រូវបានប្រកាសអោយចូលជាធរមាន ។

មាត្រា ៣.-

ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ និង ១១៩ថ្មី នៃរដ្ឋធម្មនុញ្ញ មិនអាចសំរេចបាន រដ្ឋសភា តាមសំណើររបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បី ជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជា ប្រធាន និង អនុប្រធានគណៈ កម្មការក្នុងពេលជាមួយគ្នា និង ការផ្តល់សេចក្តីទុកចិត្តចំពោះ រាជរដ្ឋាភិបាល ។

មាត្រា ៤.-

ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង និង ផ្តល់សេចក្តីទុកចិត្តត្រូវអនុវត្តដូចតទៅ :

- បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជា ប្រធាន និង អនុប្រធានគណៈ កម្មការ ជំនាញទាំងអស់ នៃរដ្ឋសភា ត្រូវរៀបចំ និង ស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- តាមសេចក្តីស្នើពីគណបក្សនយោបាយ ដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រ នៃគណបក្សនយោបាយដែលឈ្នះឆ្នោតអោយបង្កើតរាជរដ្ឋាភិបាល ។

វេជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្លូវផ្តេងតំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជី រាយនាម សមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- ព្រឹទ្ធសមាជិករដ្ឋសភា ត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវ បេក្ខជន ប្រធាន អនុប្រធាន នៃរដ្ឋសភា ក៏ដូចជាប្រធាន និង អនុប្រធាន គណកម្មការ ជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជន នាយករដ្ឋមន្ត្រី និង សមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភា បោះឆ្នោត ។

មាត្រា ៥.-

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់ មិនអាចដាក់ពិភាក្សា អ្វីឡើយ ហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះ ក្រោយ ការប្រកាសលទ្ធផល នៃការបោះឆ្នោតជាកញ្ចប់នេះដែរ ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬ មិន ព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយ ដែលព្រឹទ្ធសមាជិករដ្ឋសភាបាន ដាក់ជូន ។ ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយវិធីលើកដៃ ។

មាត្រា ៦.-ថ្នី នៃច្បាប់ធម្មនុញ្ញបន្ថែម

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើន ដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែល នេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

មាត្រា ៧.-

ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានប្រកាសជាការប្រញាប់ និង យកមកអនុវត្តចាប់តាំងពីដើម នីតិកាល បច្ចុប្បន្ននេះទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាសបន្ទាប់

ប្រមុខរដ្ឋស្តីទី

ត.ស.០៤.០៧.១៧

ហត្ថលេខា និងព្រះរាជលញ្ជីករ

ញឹក ប៊ុនឆៃ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមទ្បាយព្រះហស្តលេខាព្រះមហាក្សត្រ

ព្រឹទ្ធសមាជិក និង ជាប្រធានអង្គប្រជុំរដ្ឋសភា

ហត្ថលេខា

ជា សុជ្ជ

លេខ: ៩៣០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃ...ខែ កក្កដា ឆ្នាំ២០០៤

អគ្គលេខាធិការដ្ឋាន

កំណត់សម្គាល់ក្នុងការបោះពុម្ពផ្សាយ

ដើម្បីសម្រួលដល់ការស្រាវជ្រាវ ក៏ដូចជាបង្កភាពងាយស្រួលក្នុងការអានរដ្ឋធម្មនុញ្ញនេះ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ បានចាត់ឱ្យមានការរៀបចំភ្ជាប់ជាមួយនូវ (១) មាត្រាទាំងឡាយដែលត្រូវបានធ្វើវិសោធនកម្ម (២) ប្រមូលផ្តុំវិសោធនកម្មតាមមាត្រា (៣) មាតិកា ។

មាត្រានាំចង្អាយដែលត្រូវបានធ្វើវិសោធនកម្ម

កំណត់សម្គាល់

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ នេះ បានធ្វើវិសោធនកម្មចំនួន ៨ លើកគឺ :

១- ច្បាប់ធម្មនុញ្ញស្តីពីការកែប្រែមាត្រា ២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤ នាសម័យប្រជុំវិសាមញ្ញសម័យពិសេស ហើយប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤ ។

២- ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី២ ហើយប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៩ ។

៣- ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១៩ និងមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃចន្ទ ទី២ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិច្បាប់នេះទាំងស្រុង

កាលពីថ្ងៃច័ន្ទ ទី២៣ ខែកក្កដា ឆ្នាំ២០០១ និងប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧០១/១១ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០១ ។

៤- ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៨៨ និងមាត្រា១១ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ។

៥- ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១១ថ្មី(មួយ) មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការដាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាអនុម័តនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៦ ។

៦- ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១៤៥ថ្មី និងមាត្រា ១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាដែល រដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែល ព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់អាចពិនិត្យ និងឱ្យ យោបល់តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ បានឡើយ ហើយប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ។

៧- ច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ៧៦ និងមាត្រាទាំង ឡាយពីដំពូកទី១៥ថ្មី ដល់ដំពូកទី១៦ថ្មីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពី ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ និងប្រកាស ឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០១៤/០២២ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ។

៨- ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៣៤ថ្មី មាត្រា ៤២ មាត្រា ៤៩ មាត្រា ៥៣ និងមាត្រា ១១៨ ថ្មី នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពី ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាជា

វិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី១

មាត្រា ២៨.-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី២

មាត្រា ១១.-

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជភារៈជាព្រះប្រមុខរដ្ឋបានដូចធម្មតា ដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នោះប្រធានរដ្ឋសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គក្នុងឋានៈជា "ព្រះរាជានុសិទ្ធ" ។

មាត្រា ១២.-

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធ នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ១៣.-

ក្នុងរយៈវេលាប្រាំពីរថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ
- អនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃរដ្ឋសភា ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ នឹងមានកំណត់ក្នុងច្បាប់មួយ ។

មាត្រា ១៨.-

ព្រះមហាក្សត្រព្រះអង្គទ្រង់ទាក់ទងជាមួយរដ្ឋសភាដោយព្រះរាជសារ ។ ព្រះរាជសារនេះ រដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ ។

មាត្រា ២២.-

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិបិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា ។

មាត្រា ២៤.-

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា ។

មាត្រា ២៦.-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា ។

មាត្រា ២៨ ថ្មី.-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួនហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្តលេខានៅលើ ព្រះរាជក្រមឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួស ដោយព្រះរាជសារប្រគល់សិទ្ធិ ។

មាត្រា ៣O.-

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

មាត្រា ៣៤.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឲ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឲ្យគេបោះឆ្នោត ។

បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោតនិងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៥១.-

ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

មាត្រា ៩០.-

រដ្ឋសភាជាអង្គការតែមួយគត់ដែលមានអំណាចនីតិបញ្ញត្តិ ។ អំណាចនេះ រដ្ឋសភាមិនអាចប្រគល់ឲ្យទៅអង្គការ ឬបុគ្គលណាមួយបានឡើយ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឲ្យរដ្ឋខ្ចីប្រាក់ពីគេ ការឲ្យរដ្ឋឲ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឲ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៩១.-

តំណាងរាស្ត្រ និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះ សំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកទៅលើប្រជាពលរដ្ឋ ។

មាត្រា ៩៣.-

ច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល ១០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឲ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល ២០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឲ្យប្រើ ។

ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឲ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ ត្រូវចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយនៅទូទាំងប្រទេសឲ្យទាន់តាមពេលកំណត់ខាងលើ ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៣

មាត្រា ១៩.-

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា ១០០ ។

មាត្រា ២៩.-

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធា និងស៊ីវិល តាមច្បាប់កំណត់ ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៤

មាត្រា ៨៨.-

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ១១១.- ថ្មី

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការសុំពីប្រធានឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រីឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសម្លេងដែលតម្រូវសំរាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសំរាប់ព្រឹទ្ធសភាផងដែរ ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៥

មាត្រា ៨២.-

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធាន មុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៥ ។

មាត្រា ៨៨ ថ្មី.-

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិករដ្ឋសភាទាំងមូល ។

ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៩០.- ថ្មី

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុនិងការបង្កើត កែប្រែឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រមឬលុបចោលសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

មាត្រា ៩៨.-

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោសតាមសម្លេងឆ្នោតពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

មាត្រា ១០៦.-ថ្មី

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗនិងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភានិងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

មាត្រា ១១១ថ្មី (មួយ).-

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសំរាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសំរាប់ព្រឹទ្ធសភាផងដែរ ។

មាត្រា ១១៤.-ថ្មី

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រមដោយសម្លេងភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

មាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែម

មាត្រា ៦.-

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណី ការបោះឆ្នោតជុំទីមួយមិនបានសំរេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៦

មាត្រា ១៤៥.- ថ្មី (មាត្រា ១២៦ ចាស់)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត និងក្រុង ។

ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។

ក្រុងចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់ ។

មាត្រា ១៤៦.- ថ្មី (មាត្រា ១២៧ ចាស់)

ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំនិងសង្កាត់ ត្រូវគ្រប់គ្រងតាមលិក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៧

មាត្រា ៧៦.-

រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

អង្គការរៀបចំការបោះឆ្នោត បែបបទនិងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៨

មាត្រា ៣៤.-ថ្មី

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោតនិងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោតនិងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៤២.-

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណៈបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។

មាត្រា ៤៩.-

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

មាត្រា ៥៣.-

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹត អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក ។

ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាជាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង នៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក ។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀង យោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតឲ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឲ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ព្រះរាជាណាចក្រកម្ពុជារក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈ យោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស ។

មាត្រា ១១៨.- ថ្មី (មាត្រា ៩៩ ចាស់)

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការជាសមាជិក ។

ប្រមូលផ្តុំវិសោធនកម្មតាមមាត្រា

វិសោធនកម្មច្បាប់ធម្មនុញ្ញបន្ថែម
សំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

មាត្រា ៦.-

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណី ការបោះឆ្នោតជុំទីមួយមិនបានសំរេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

(ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤)

មាត្រា ៦ .-ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៦)

វិសោធនកម្មរដ្ឋធម្មនុញ្ញ

មាត្រា ១១.-

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជការៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតា ដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នោះប្រធានរដ្ឋសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គក្នុងហានៈជា "ព្រះរាជានុសិទ្ធ" ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស. ១៩៩៣)

មាត្រា ១១.-ថ្មី

ក្នុងករណីដែលព្រះមហាក្សត្រពុំអាចបំពេញព្រះរាជការៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតាដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភានិងនាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គក្នុងហានៈជាព្រះរាជានុសិទ្ធិ ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងហានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ ។

តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រក្នុងហានៈជាព្រះរាជានុសិទ្ធិនេះ អាចនឹងដូរឥស្សរជនផ្សេងទៀត ក្នុងករណីដូចដែលបានចែងក្នុង

វាក្យខ័ណ្ឌខាងលើ តាមឋានានុក្រមដូចតទៅ :

ក- អនុប្រធានទី ១ ព្រឹទ្ធសភា

ខ- អនុប្រធានទី ១ រដ្ឋសភា

គ- អនុប្រធានទី ២ ព្រឹទ្ធសភា

ឃ- អនុប្រធានទី ២ រដ្ឋសភា

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១២.-

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធ នៃព្រះរាជាណាចក្រកម្ពុជា ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១២.-ថ្មី

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះអង្គចូលទីវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីក្នុងឋានៈជាព្រះរាជានុសិទ្ធិត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១៣.-

ក្នុងរយៈវេលាប្រាំពីរថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ
- អនុប្រធានទីមួយ និងអនុប្រធានទីពីរ នៃរដ្ឋសភា ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ នឹងមានកំណត់ក្នុងច្បាប់មួយ ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១៣.-ថ្មី

ក្នុងរយៈវេលា ៧ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

-ប្រធានព្រឹទ្ធសភា

-ប្រធានរដ្ឋសភា

-នាយករដ្ឋមន្ត្រី

-សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ និងគណៈធម្ម
យុត្តិកនិកាយ

-អនុប្រធានទី ១ និងអនុប្រធានទី ២ ព្រឹទ្ធសភា

-អនុប្រធានទី ១ និងអនុប្រធានទី ២ រដ្ឋសភា

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនឹងមានកំណត់ក្នុងច្បាប់មួយ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១៨.-

ព្រះមហាក្សត្រព្រះអង្គទ្រង់ទាក់ទងជាមួយរដ្ឋសភាដោយព្រះរាជសារ ។ ព្រះរាជសារនេះ រដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១៨.-ថ្មី

ព្រះមហាក្សត្រព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភានិងរដ្ឋសភាដោយព្រះរាជសារ ។

ព្រះរាជសារនេះ ព្រឹទ្ធសភានិងរដ្ឋសភាមិនអាចយកទៅជជែកពិភាក្សាឡើយ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១៩.-

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា ១០០ ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១៩ ថ្មី.-

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រីនិងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី ។

(ព្រះរាជក្រមលេខ នស/រកម/០៧០១/១១ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០១)

មាត្រា ២២.-

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិបិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ២២.-ថ្មី

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភានិងប្រធានព្រឹទ្ធសភា។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ២៤.-

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ២៤.-ថ្មី

ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ២៦.-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ២៦.-ថ្មី

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភានិងព្រឹទ្ធសភា ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ១៩៩៩)

មាត្រា ២៨.-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ២៨ ថ្មី .-

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួនហើយត្រូវព្យាបាលព្រះរោគ នៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយ ព្រះហស្តលេខានៅលើ ព្រះរាជក្រមឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋ ស្តីទីចុះហត្ថលេខាជំនួស ដោយព្រះរាជសារប្រគល់សិទ្ធិ ។

(ព្រះរាជក្រម ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤)

មាត្រា ២៨.-ថ្មី

ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគ នៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយ ព្រះហស្តលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ២៩.-

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈយោធា និងស៊ីវិល តាមច្បាប់កំណត់ ។

(ព្រះរាជក្រមចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ២៩ ថ្មី.-

ព្រះមហាក្សត្រទ្រង់បង្កើតនិងប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធានិងស៊ីវិល តាមច្បាប់កំណត់ ។

(ព្រះរាជក្រមលេខ នស/រកម/០៧០១/១១ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០១)

មាត្រា ៣០.-

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានរដ្ឋសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៣០.-ថ្មី

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមានការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ១១ថ្មី ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ៣៤.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឲ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឲ្យគេបោះឆ្នោត ។

បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតត្រូវ ចែងក្នុងច្បាប់បោះឆ្នោត ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៣៤.-ថ្មី

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោតនិងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោតនិងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា៣៤.-ថ្មី (មួយ)

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។

បទប្បញ្ញត្តិដកសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់។

(ព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨)

មាត្រា ៤២.-

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណៈបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា៤២.- ថ្មី

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគមនិងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

គណបក្សនយោបាយត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី

នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។

(ព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨)

មាត្រា ៤៩.-

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា៤៩.- ថ្មី

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់។

(ព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨)

មាត្រា ៥១.-

ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៥១.-ថ្មី

ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលនិងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ៥៣.-

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។ ព្រះរាជាណាចក្រកម្ពុជារួមរស់

ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀត ទាំងអស់នៅលើសកលលោក ។

ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង នៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក ។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀង យោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតឲ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឲ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈ យោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធនិងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា៥៣.- ថ្មី

ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ដោយ

សន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។

ព្រះរាជាណាចក្រកម្ពុជាមិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។

ព្រះរាជាណាចក្រកម្ពុជាប្រឆាំងដាច់ខាតការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ទោះបីក្រោមរូបភាពណាក៏ដោយ។

ព្រះរាជាណាចក្រកម្ពុជាមិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ។

ព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ។

ព្រះរាជាណាចក្រកម្ពុជារក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈយោធា អាវុធ គ្រាប់រំសែវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស។

(ព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨)

មាត្រា ៧៦.-

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

អង្គការរៀបចំការបោះឆ្នោត បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៧៦.- ថ្មី

រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។

តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

(ព្រះរាជក្រមលេខ នស/រកម/១០១៤/០២២ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៤)

មាត្រា ៨២.-

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធាន មុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៥ ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៨២ .- ថ្មី

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ៨៨.-

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៨៨ ថ្មី.-

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិករដ្ឋសភាទាំងមូល ។

ខ-កូរ៉ុមប្រាំមួយភាគដប់នៃសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥)

មាត្រា ៨៨ .-ថ្មី(ពីរ)

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភា នឹងយកជាការបានលុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ៩O.-

រដ្ឋសភាជាអង្គការតែមួយគត់ដែលមានអំណាចនីតិបញ្ញត្តិ ។ អំណាចនេះ រដ្ឋសភាមិនអាចប្រគល់ឲ្យទៅអង្គការ ឬបុគ្គលណាមួយបានឡើយ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឲ្យរដ្ឋខ្ចីប្រាក់ពីគេ ការឲ្យរដ្ឋឲ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឲ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៩០.-ថ្មី

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុនិងការបង្កើត កែប្រែឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រមឬលុបចោលសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ៩០ .-ថ្មី(ពីរ)

រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬ លុបចោលសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ៩១.-

តំណាងរាស្ត្រ និងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះ សំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកទៅលើប្រជាពលរដ្ឋ ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៩១.-ថ្មី

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភានិងនាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ៩៣.-

ច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល ១០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឲ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល ២០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឲ្យប្រើ ។

ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឲ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ ត្រូវចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយនៅទូទាំងប្រទេសឲ្យទាន់តាមពេលកំណត់ខាងលើ ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៩៣.-ថ្មី

ច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា

ប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថា ជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលកំណត់ខាងលើ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ៩៨.-

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោសតាមសម្លេងឆ្នោតពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ៩៨ .- ថ្មី

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ២០០៦)

មាត្រា ១០៦.-ថ្មី

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗនិងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភានិងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១០៦ .-ថ្មី(មួយ)

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ១១១.-ថ្មី

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការសុំពីប្រធានឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសម្លេងដែលតម្រូវសំរាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសំរាប់ព្រឹទ្ធសភាផងដែរ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១១១ ថ្មី (មួយ).-

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី ឬយកមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ- កូរ៉ុមប្រាំមួយភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយ

ប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

(ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥)

មាត្រា ១១១ .-ថ្មី(ពីរ)

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬ យកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ១១៤.-ថ្មី

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រមដោយសម្លេងភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា ១១៤ .-ថ្មី(មួយ)

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

(ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦)

មាត្រា ៩៩.-

គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិក ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១១៨.-ថ្មី (មាត្រា ៩៩ ចាស់)

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយ

ឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ជាសមាជិក ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា១១៨.- ថ្មី (មួយ)

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយ ឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ជាសមាជិក។

(ព្រះរាជក្រមលេខ នស/រកម/០២១៨/០០២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨)

មាត្រា ១២៦.-

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត និងក្រុង ។

ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។

ក្រុងចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់ ។

(ព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១៤៥.-ថ្មី (មាត្រា ១២៦ ចាស់)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត និងក្រុង ។

ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។

ក្រុងចែកជាខ័ណ្ឌ ខ័ណ្ឌចែកជាសង្កាត់ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា១៤៥ .-ថ្មី (មួយ)

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

(ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨)

មាត្រា ១២៧.-

ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ និង សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។

(ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣)

មាត្រា ១៥៦.-ថ្មី (មាត្រា ១២៧ ចាស់)

ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំនិងសង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ ។

(ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩)

មាត្រា១៥៦ .-ថ្មី (មួយ)

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ ។

(ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៨)

មាតិកា

មាតិកា

ព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ថ្ងៃទី២៤ ខែកញ្ញា គ.ស.១៩៩៣

បុព្វកថា ១

ជំពូកទី១: អំពី អធិបតេយ្យ ៣

ជំពូកទី២: អំពី ព្រះមហាក្សត្រ ៥

ជំពូកទី៣: អំពី សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ១២

ជំពូកទី៤: អំពី របបនយោបាយ ២០

ជំពូកទី៥: អំពី សេដ្ឋកិច្ច ២៣

ជំពូកទី៦: អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច ២៦

ជំពូកទី៧: អំពី រដ្ឋសភា ២៩

ជំពូកទី៨ ថ្មី: អំពី ព្រឹទ្ធសភា ៣៩

ជំពូកទី៩ ថ្មី: អំពី សមាជរដ្ឋសភា និងព្រឹទ្ធសភា ៤៧

ជំពូកទី១០ ថ្មី: អំពី រាជរដ្ឋាភិបាល ៤៨

ជំពូកទី១១ ថ្មី: អំពី អំណាចតុលាការ ៥១

ជំពូកទី១២ ថ្មី: អំពី ក្រុមប្រឹក្សាធម្មនុញ្ញ ៥៤

ជំពូកទី១៣ ថ្មី: អំពី ការគ្រប់គ្រងរដ្ឋបាល ៥៧

ជំពូកទី១៤ ថ្មី: អំពី សមាជជាតិ ៥៨

ជំពូកទី១៥ ថ្មី(ពីរ): អំពី អង្គការរៀបចំការបោះឆ្នោត ៥៩

ជំពូកទី១៦ ថ្មី(ពីរ): អំពីអានុភាព ការសើរើ និងវិសោធនកម្ម
រដ្ឋធម្មនុញ្ញ ៦២
ជំពូកទី១៧ ថ្មី: អំពីអន្តរប្បញ្ញត្តិ ៦៤
ឧបសម្ព័ន្ធទី១: ទង់ជាតិ ៦៧
ឧបសម្ព័ន្ធទី២: ភ្លេងជាតិ នគរវាជ ៦៩
ឧបសម្ព័ន្ធទី៣: សញ្ញាជាតិ ៧១
ឧបសម្ព័ន្ធទី៤: សច្ចាប្រណិធាននៃព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ៧៣
ឧបសម្ព័ន្ធ ៥: សច្ចាប្រណិធានសម្រាប់ប្រធាន អនុប្រធាន និង សមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ៧៥
ឧបសម្ព័ន្ធ ៦: សច្ចាប្រណិធានសម្រាប់នាយករដ្ឋមន្ត្រី និង សមាជិករាជរដ្ឋាភិបាល ៧៩
ឧបសម្ព័ន្ធទី៧: សច្ចាប្រណិធានសម្រាប់ប្រធាន អនុប្រធាន និង សមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ៨៣
គណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ ៨៧
ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ៨៩
ព្រះរាជក្រម នស/រកម/ ០៧០៤ / ០០១ ..... ៩១
កំណត់សម្គាល់ក្នុងការបោះពុម្ពផ្សាយ ៩៧
មាត្រាទាំងឡាយដែលត្រូវបានធ្វើវិសោធនកម្ម ៩៩
កំណត់សម្គាល់ ១០១
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី១ ..... ១០៥

មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី២ ..... ១០៦
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៣ ..... ១១១
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៤ ..... ១១២
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៥ ..... ១១៣
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៦ ..... ១១៧
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៧ ..... ១១៨
មាត្រាដែលត្រូវបានធ្វើវិសោធនកម្មលើកទី៨ ..... ១១៩
ប្រមូលផ្តុំវិសោធនកម្មតាមមាត្រា ១២៣
វិសោធនកម្មច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជា
ប្រក្រតីនៃស្ថាប័នជាតិ ១២៥
វិសោធនកម្មរដ្ឋធម្មនុញ្ញ ១២៦
មាតិកា ១៥៥

ឧបសម្ព័ន្ធ ២



រាជរដ្ឋាភិបាលកម្ពុជា

ច្បាប់

ស្តីពី

គណបក្សនយោបាយ

ក្រសួងមហាផ្ទៃ

អារម្ភកថា

ផ្អែកតាមមាត្រា៤២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចែងថា " ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់"។ អនុលោមតាមបទប្បញ្ញត្តិខាងលើនេះ ច្បាប់ស្តីពីគណបក្សនយោបាយ ត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ក្នុងគោលបំណងធានា និងលើកកម្ពស់សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសិទ្ធិមនុស្ស ការបង្រួបបង្រួមផ្សះផ្សាជាតិ និងការកសាងប្រទេសជាតិឡើងវិញ តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងនីតិរដ្ឋ បន្ទាប់ពីប្រទេសកម្ពុជាបានឆ្លងកាត់ការបែកបាក់ជាតិ និងទទួលរងទុក្ខវេទនារាប់ម៉ឺនជំពូក ក្នុងអំឡុងពេលជាង២ទស្សវត្សរ៍កន្លងមកនេះ។

ច្បាប់នេះត្រូវបានដាក់ឲ្យប្រើប្រាស់ប្រមាណជិត២០ឆ្នាំ មកហើយ និងត្រូវបានធ្វើវិសោធនកម្ម ចំនួន៣(បី)លើក **ដោយលើកទី១** នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ **លើកទី២** នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៧ **និងលើកទី៣** នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩។ ការធ្វើវិសោធនកម្មច្បាប់នេះ ត្រូវបានធ្វើឡើងដើម្បីពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់គណបក្សនយោបាយស្របតាមការវិវត្តនៃសង្គមកម្ពុជា គោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ព្រមទាំងដើម្បីពង្រឹងខឿនសន្តិសុខជាតិ ឯកភាពជាតិ និងអធិបតេយ្យជាតិ។

ក្រសួងមហាផ្ទៃ សង្ឃឹម និងជឿជាក់ថា ច្បាប់ស្តីពីគណបក្សនយោបាយ នឹងបានជាប្រយោជន៍យ៉ាងច្រើនសម្រាប់ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាគណបក្សនយោបាយ ក្នុងការសុំបង្កើត ការសុំចុះបញ្ជី និងការធ្វើសកម្មភាពឲ្យស្របតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីឲ្យគណបក្សនយោបាយបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយគណនេយ្យភាព តម្លាភាព និងអព្យាក្រឹត្យភាព ក្នុងគោលបំណងពង្រឹងគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋនៅកម្ពុជាឲ្យកាន់តែរឹងមាំថែមទៀត ។

ថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ.ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០



ច្បាប់

ស្តីពី

គណបក្សនយោបាយ

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១ ..-

ច្បាប់នេះ មានគោលដៅកំណត់បែបបទ និងលក្ខខណ្ឌនៃការបង្កើត ការចុះបញ្ជីនិងការធ្វើសកម្មភាពរបស់គណបក្សនយោបាយក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២ ..-

គណបក្សនយោបាយ គឺជាក្រុមមនុស្សដែលមានគំនិត និងឆន្ទៈស្របគ្នា ហើយរួបរួមគ្នាដោយស្ម័គ្រចិត្តតាមកិច្ចសន្យា បង្កើតឡើងនូវអង្គការមួយ ដែលមានលក្ខណៈអចិន្ត្រៃយ៍ និងស្វ័យភាព ដើម្បីចូលរួមក្នុងឆាកនយោបាយជាតិតាមរបបប្រជាធិបតេយ្យសេរីពហុបក្ស ដោយការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ស្របតាមការកំណត់នៃរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធជាធរមាន ។

មាត្រា ៣ ..-

គ្រប់គណបក្សនយោបាយត្រូវមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ ឬទីរួមខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤ ..-

គ្រប់គណបក្សនយោបាយមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលបុព្វសិទ្ធិ និងការយកចិត្តទុកដាក់ដោយស្មើភាពគ្នាពីរាជរដ្ឋាភិបាល និងអាជ្ញាធរគ្រប់ជាន់ថ្នាក់។

មាត្រា ៥ ..-

ការចូលជាសមាជិករបស់គណបក្សនយោបាយណាមួយ គឺជាការជ្រើសរើសផ្ទាល់ខ្លួន ដោយសេរីរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។ គ្មានជនណាម្នាក់មានសិទ្ធិបង្ខិតបង្ខំឲ្យគេចូលជាសមាជិកគណបក្សនយោបាយណាមួយឡើយ។

គ្មានជនណាម្នាក់ត្រូវបានគេដកហូតសិទ្ធិក្នុងការអនុវត្តសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ ឬសិទ្ធិរស់ជីវៈ ដោយសារមូលហេតុជននោះជាសមាជិក ឬមិនមែនជាសមាជិករបស់គណបក្សនយោបាយណាមួយដែលបង្កើតឡើងដោយស្របច្បាប់នោះទេ។

មាត្រា ៦ .. ថ្មី(ពីរ)

គ្រប់គណបក្សនយោបាយមិនត្រូវធ្វើសកម្មភាពណាមួយដូចខាងក្រោម៖

១ - ធ្វើឲ្យមានអបគមន៍ ដែលនាំឲ្យអន្តរាយដល់ឯកភាពជាតិ និងបូរណភាពដែនដី។

២- ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យ សេរី ពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

៣ - ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ។

៤ - បង្កើតកងកម្លាំងប្រដាប់អាវុធ។

៥- ធ្វើការញុះញង់ដែលអាចនាំឲ្យមានការបែកបាក់ជាតិ។

៦- ប្រើប្រាស់សារជាសម្លេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់ទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន។

៧- យល់ព្រមដោយចំហរ ឬដោយតុណ្ហីភាព ឬឃុបឃិតជាមួយទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ឲ្យធ្វើសកម្មភាពណាមួយដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន។

៨- គាំទ្រ ឬរៀបចំផែនការ ឬឃុបឃិតជាមួយរាល់បុគ្គលដែលធ្វើសកម្មភាពក្នុងគោលបំណងប្រឆាំងនឹងផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ដូចមានចែងពីចំណុចទី១ ដល់ចំណុចទី៥ ខាងលើ។

មាត្រា ៧ ..

គ្រប់គណបក្សនយោបាយមិនត្រូវស្ថិតនៅក្រោមចំណុះ ឬការបង្គាប់បញ្ជារបស់គណបក្សនយោបាយបរទេស ឬរបស់រដ្ឋាភិបាលបរទេស។

មាត្រា ៨ ..

ការចុះបញ្ជីគណបក្សនយោបាយជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

ជំពូកទី ២
ការបង្កើតគណបក្សនយោបាយ

មាត្រា ៩ ..

ប្រជាពលរដ្ឋខ្មែរចំនួនយ៉ាងតិច ៨០នាក់ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ ហើយដែលមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិផ្តើមបង្កើតគណបក្សនយោបាយមួយបានដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ។ ក្រសួងមហាផ្ទៃត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរថា បានទទួលសេចក្តីជូនដំណឹងនេះ ក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃ។ បើហួសការកំណត់ ១៥ថ្ងៃនេះត្រូវចាត់ទុកថាបានទទួលសេចក្តីជូនដំណឹងនេះ ។

គណបក្សនយោបាយដែលទើបផ្តើមបង្កើតត្រូវធ្វើការបោះឆ្នោតជ្រើសតាំង គណៈកម្មាធិការបណ្តោះអាសន្នដែលមានសមាជិកយ៉ាងតិច ៧រូប ហើយដែលម្នាក់ៗ មានអាយុយ៉ាងតិច ២៥ឆ្នាំ សម្រាប់រៀបចំបែបបទ និងបំពេញលក្ខខណ្ឌនៃការសុំចុះបញ្ជីគណបក្សនយោបាយ តាមការកំណត់ដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ដើម្បីទទួលសុពលភាព។

ទោះបីមិនទាន់ទទួលសុពលភាពក៏ដោយ ក្នុងរយៈពេលនេះ គណបក្សនយោបាយអាចលើកផ្ទាំកនៅទីស្នាក់ការរបស់ខ្លួនបាន។

មាត្រា ១០ ..

គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំលក្ខន្តិកៈ និងគោលនយោបាយសំខាន់ៗ ជាលាយលក្ខណ៍អក្សរ ដែលមានចំណុចសំខាន់ៗយ៉ាងតិចណាស់ ដូចខាងក្រោមនេះ៖

ក- លក្ខន្តិកៈត្រូវមាន៖

១- ឈ្មោះជាអក្សរពេញ អក្សរកាត់ និងសញ្ញាសម្គាល់។

២- អាសយដ្ឋាននៃទីស្នាក់ការកណ្តាល។

៣- កាលបរិច្ឆេទនៃការបង្កើតគណបក្សនយោបាយ។ កាលបរិច្ឆេទគណបក្សនយោបាយនេះមិនត្រូវជាន់លើថ្ងៃបុណ្យជាតិ និងអន្តរជាតិ។

៤- វិធានស្តីពីការបញ្ចូលជាសមាជិកភាព និងការបណ្តេញចេញពីសមាជិកភាព។

៥- សិទ្ធិ និងភារកិច្ចរបស់សមាជិក។

៦- រចនាសម្ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមបន្តបន្ទាប់។

៧- សមត្ថកិច្ចនៃអង្គការនានារបស់គណបក្សនយោបាយ។

៨- បែបបទនៃការជ្រើសរើស និងដកហូតមុខងាររបស់សមាជិកគណៈកម្មាធិការនាយក ។

៩- ការកំណត់អំពីការប្រជុំសាមញ្ញ នៃអង្គការនានារបស់គណបក្សនយោបាយ ។

១០- ចំនួនសមាជិកចាំបាច់ (កូរ៉ុម) ដែលត្រូវចូលរួមក្នុងអង្គប្រជុំ នៃអង្គការនានារបស់គណបក្សនយោបាយ ដើម្បីឲ្យអង្គប្រជុំនោះយកជាការបាន ។

១១- ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់គណបក្សនយោបាយ។

១២- វិធានស្តីពីការរំលាយគណបក្សនយោបាយ និងការចាត់ចែងទ្រព្យសម្បត្តិរបស់គណបក្សនយោបាយ នៅពេលត្រូវរំលាយ។

១៣- វិធានស្តីពីការធ្វើវិសោធនកម្មលក្ខន្តិកៈគណបក្សនយោបាយ។

ខ- គោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗ ត្រូវចែងអំពីគោលជៅ និងវត្ថុបំណងរបស់គណបក្សនយោបាយ។

មាត្រា ១១ ..ថ្មី

គ្រប់គណបក្សនយោបាយត្រូវមានឈ្មោះ និងសញ្ញាសម្គាល់តាមការកំណត់ដូចខាងក្រោម៖

១ - ឈ្មោះជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយ ត្រូវតែខុសគ្នាពីឈ្មោះជាអក្សរពេញ ឬអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយនានា។

២- ឈ្មោះរបស់គណបក្សនយោបាយ មិនត្រូវធ្វើឡើងដោយគ្រាន់តែកែសម្រួលបន្តិចបន្តួចនៅលើឈ្មោះគណបក្សនយោបាយនានា ឬយកឈ្មោះរូបវន្តបុគ្គលមកដាក់ឡើយ។

៣- សញ្ញាសម្គាល់របស់គណបក្សនយោបាយមិនត្រូវចម្លង ឬយកតាមសញ្ញាជាតិ រូបភាពតំណាងឲ្យសាសនា ប្រាសាទអង្គរវត្ត ឬព្រះឆាយាល័ក្ខណ៍ ឬរូបសំណាករបស់ព្រះមហាក្សត្រខ្មែរគ្រប់អង្គ ឬរូបភាពរបស់រូបវន្តបុគ្គលឡើយ។

ជំពូកទី ៣
សមាជិកភាព

មាត្រា ១២ .. ថ្មី

មានតែប្រជាពលរដ្ឋខ្មែរ ដែលមានអាយុយ៉ាងតិច ១៨ (ដប់ប្រាំបី)ឆ្នាំ និងមានសិទ្ធិពលរដ្ឋប៉ុណ្ណោះ ដែលអាចចូលជាសមាជិកគណបក្សនយោបាយបាន។

មាត្រា ១៣ .-

ការចូលជាសមាជិកនៃគណបក្សនយោបាយ ត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត។

សមាជិកគណបក្សនយោបាយ អាចលាឈប់ពីគណបក្សនយោបាយបានគ្រប់ពេលវេលា ដោយមិនបាច់បញ្ជាក់ពីមូលហេតុឡើយ។

មាត្រា ១៤ .-

សមាជិកគណបក្សនយោបាយមានសិទ្ធិ កាតព្វកិច្ចដូចគ្នាស្របតាមលក្ខន្តិក: នៃគណបក្សនយោបាយ។

មាត្រា ១៥ .-

ប្រជាពលរដ្ឋខ្មែរម្នាក់មិនអាចជាសមាជិកគណបក្សនយោបាយលើសពីមួយក្នុងពេលតែមួយបានទេ។ ក្នុងករណីដែលបុគ្គលមួយរូបចូលជាសមាជិកគណបក្សនានាយ៉ាងច្រើន សមាជិកភាពក្នុងគណបក្សនយោបាយចុងក្រោយត្រូវចាត់ទុកជាបានការ។

បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ អាចចូលជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ។ គណបក្សនយោបាយមិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងក្នុងស្ថាប័ន សាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិទេ។

មាត្រា ១៦ .-

សមាជិកគណបក្សនយោបាយ ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោមនេះ ៖

១ - បានលាឈប់ ឬបានបោះបង់សមាជិកភាព នៃគណបក្សនយោបាយ។

២ - ត្រូវបានបណ្តេញចេញពីគណបក្សនយោបាយស្របតាមលក្ខន្តិក:របស់គណបក្សនយោបាយសាមី។

ជំពូកទី ៤ ថ្មី
អង្គការនានា និងថ្នាក់ដឹកនាំរបស់គណបក្សនយោបាយ

មាត្រា ១៧ .- ថ្មី

គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំឲ្យមានអង្គការដឹកនាំយ៉ាងតិចដូចខាងក្រោម ៖

១ - មហាសន្និបាត ឬសមាជ ឬអង្គការសមមូល។

២ - ក្រុមប្រឹក្សាជាតិ ឬគណៈកម្មាធិការកណ្តាល ឬអង្គការសមមូល។

៣ - គណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូល។

៤ - គណៈកម្មាធិការអាជ្ញាកណ្តាល ឬគណៈកម្មាធិការត្រួតពិនិត្យ ឬគណៈកម្មាធិការវិនិច្ឆ័យ ឬអង្គការសមមូល។

ឈ្មោះអង្គការដឹកនាំរបស់គណបក្សនយោបាយគ្រប់ថ្នាក់នេះ អាចប្រែប្រួលអាស្រ័យទៅតាមការកំណត់របស់លក្ខន្តិក:នៃគណបក្សនយោបាយនីមួយៗ។

គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំឲ្យមានប្រធាន និងអាចមានអនុប្រធានតាមការចាំបាច់។ ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ ត្រូវជ្រើសរើសដោយអនុវត្តតាមលក្ខន្តិក: នៃគណបក្សនយោបាយនីមួយៗ។

អាណត្តិ ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការដឹកនាំរបស់គណបក្សនយោបាយនីមួយៗ ដូចមានចែងខាងលើនេះ ព្រមទាំងអង្គការដឹកនាំផ្សេងទៀតរបស់គណបក្សនយោបាយ ត្រូវកំណត់ក្នុងលក្ខន្តិក: ឬបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយ ។

មាត្រា ១៨ .. ថ្មី

ពលរដ្ឋទាំងពីរភេទ ដែលមានសញ្ជាតិខ្មែរពីកំណើត និងមានអាយុយ៉ាងតិច២៥(ម្ភៃប្រាំ)ឆ្នាំ អាចធ្វើជាប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬធ្វើជាសមាសភាពនៃអង្គការដឹកនាំ នៃគណបក្សនយោបាយបាន។

ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ នៃគណបក្សនយោបាយ មិនត្រូវជាបុគ្គលដែលជាទណ្ឌិតជាប់ទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោសឡើយ។

ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ នៃគណបក្សនយោបាយ ត្រូវបាត់បង់នូវតួនាទីរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោម៖

- សាមីខ្លួនទទួលមរណភាព ។
- សាមីខ្លួនបានសុំលាឈប់ជាលាយលក្ខណ៍អក្សរ ។
- សាមីខ្លួនត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោស លើកលែងតែទោសនោះត្រូវបានលើកលែងទោសដោយព្រះមហាក្សត្រ ។

គណបក្សនយោបាយ ត្រូវចាត់នីតិវិធីដើម្បីជំនួសប្រធានគណបក្សនយោបាយ ដែលបាត់បង់តួនាទី ដូចមានចែងក្នុងកថាខណ្ឌខាងលើ ក្នុងរយៈពេលយ៉ាងយូរ៩០(កៅសិប)ថ្ងៃ គិតពីថ្ងៃបាត់បង់តួនាទីនោះ។

បទប្បញ្ញត្តិនេះ ក៏ត្រូវយកទៅអនុវត្តផងដែរចំពោះបុគ្គលដែលមានតួនាទី ឬសិទ្ធិអំណាចប្រហាក់ប្រហែលទៅនឹងប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ។

ជំពូកទី ៥
ការចុះបញ្ជីគណបក្សនយោបាយ

មាត្រា ១៩ .. ថ្មី

ក្នុងរយៈពេលយ៉ាងយូរ**១៨០(មួយរយប៉ែតសិប)ថ្ងៃ** បន្ទាប់ពីគណបក្សនយោបាយត្រូវបានបង្កើតឡើងស្របតាមមាត្រា៩ នៃច្បាប់នេះ គណបក្សនយោបាយនោះត្រូវស្នើសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដើម្បីទទួលបានសុពលភាព និងអាចធ្វើសកម្មភាពបានដោយស្របច្បាប់ក្នុងឋានៈជានីតិបុគ្គល ដោយត្រូវមានសមាជិកយ៉ាងតិច ៤.០០០(បួនពាន់)នាក់ និងត្រូវបំពេញបែបបទ និងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ។

គណបក្សនយោបាយដែលមិនទទួលបានការចុះបញ្ជីស្របតាមបទប្បញ្ញត្តិ នៃជំពូកនេះ មិនអាចធ្វើសកម្មភាពនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

មាត្រា ២០ ..

គណបក្សនយោបាយ ត្រូវបំពេញបែបបទ និងលក្ខខណ្ឌដូចខាងក្រោម៖

១- ពាក្យសុំចុះបញ្ជីគណបក្សនយោបាយ ត្រូវមានហត្ថលេខារបស់ប្រធានគណបក្សនយោបាយ។
២- ឈ្មោះជាអក្សរពេញ និងអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយ។
៣- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ។
៤- ច្បាប់ដើម នៃលក្ខន្តិកៈគណបក្សនយោបាយចំនួនពីរច្បាប់។
៥- បទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយ ប្រសិនបើមាន។
៦- គោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗរបស់គណបក្សនយោបាយ។
៧- សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយ ស្តីពីការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងបទប្បញ្ញត្តិផ្សេងៗជាធរមាន និងគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស។
៨- បញ្ជីឈ្មោះដោយមានអាយុ អាសយដ្ឋាន និងស្នាមមេដៃរបស់សមាជិកទាំង ៤.០០០នាក់ ដោយមានបញ្ជាក់លេខប័ណ្ណសមាជិកគណបក្ស និងកាលបរិច្ឆេទនៃការចូលសមាជិកភាពគណបក្សនយោបាយ។
៩- ជីវប្រវត្តិសង្ខេបរបស់ប្រធាន ឬស្តាបនិកចំនួន៣ នាក់យ៉ាងតិច ក្នុងមួយនាក់មួយច្បាប់ ដោយមានបិទរូបថតទំហំ ៤ គុណនឹង៦។
១០- សេចក្តីប្រកាសអំពីគណនីធនាគារនៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។
១១- បង្កាន់ដៃថ្លៃអាករចុះបញ្ជីគណបក្សនយោបាយមួយច្បាប់។ ថ្លៃអាករនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា ២១ ..

ក្រសួងមហាផ្ទៃ ត្រូវចេញបង្កាន់ដៃទទួលពាក្យសុំមួយច្បាប់ ឲ្យគណបក្សនយោបាយដែលបានបំពេញទម្រង់បែបបទគ្រប់គ្រាន់តាមការកំណត់ដូចមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ។

មាត្រា ២២ ..

ក្រសួងមហាផ្ទៃ ត្រូវពិនិត្យខ្លឹមសារ នៃសំណុំឯកសាររបស់គណបក្សនយោបាយ បន្ទាប់ពីថ្ងៃចេញបង្កាន់ទទួលពាក្យសុំ ដូចមានចែងក្នុងមាត្រា២១ នៃច្បាប់នេះ។

ក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃ ក្រសួងមហាផ្ទៃត្រូវសម្រេចយល់ព្រម ឬមិនយល់ព្រមឲ្យចុះបញ្ជីគណបក្សនយោបាយ។

មាត្រា ២៣ ..

ក្នុងករណីពិនិត្យឃើញថា សំណុំឯកសាររបស់គណបក្សនយោបាយណាមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់នានាជាធរមាន ក្រសួងមហាផ្ទៃត្រូវធ្វើលិខិតឆ្លើយតបស្តីពីការយល់ព្រមឲ្យចុះបញ្ជី ផ្ញើជូនទៅសាមីគណបក្សនយោបាយនោះវិញ ដោយភ្ជាប់ជាមួយនូវលក្ខន្តិកៈមួយច្បាប់ ដែលមានចារបញ្ជាក់កាលបរិច្ឆេទ នៃការចុះបញ្ជីគណបក្សនយោបាយ ដោយមានចុះហត្ថលេខា និងត្រារបស់ក្រសួងមហាផ្ទៃ។

មាត្រា ២៤ ..

ក្នុងករណីពិនិត្យឃើញថា សំណុំឯកសាររបស់គណបក្សនយោបាយ ដែលមិនទាន់មានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់នានាជាធរមាន ក្រសួងមហាផ្ទៃត្រូវធ្វើលិខិតជូនដំណឹងផ្ញើជូនទៅសាមីគណបក្សនយោបាយនេះវិញ។ គណបក្សនយោបាយនោះ

ត្រូវបំពេញបន្ថែមលើសំណុំឯកសារតាមលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃ យ៉ាងយូរ១៥ ថ្ងៃ ចាប់ពីថ្ងៃទទួលលិខិតនេះ។ បើហួសរយៈពេលកំណត់១៥ថ្ងៃនេះ ក្រសួងមហាផ្ទៃ ត្រូវធ្វើលិខិតមិនយល់ព្រមឲ្យចុះបញ្ជីគណបក្សនយោបាយផ្ញើជូនទៅសាមីគណបក្សនយោបាយ។

មាត្រា ២៥ .- ថ្មី

គណបក្សនយោបាយណា ដែលក្រសួងមហាផ្ទៃបានចេញលិខិតមិនយល់ព្រមឲ្យចុះបញ្ជីគណបក្សនយោបាយ ដូចមានចែងក្នុងមាត្រា២៤ នៃច្បាប់នេះ គណបក្សនយោបាយនោះមានសិទ្ធិប្តឹងទៅតុលាការកំពូល។

តុលាការកំពូល ត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងរបស់សាមីគណបក្សនយោបាយនោះ។

ក្រោយពីបានទទួលសេចក្តីសម្រេចរបស់តុលាការកំពូលដែលសម្រេចលើភាពត្រឹមត្រូវ នៃខ្លឹមសារ នៃសំណុំឯកសាររបស់គណបក្សនយោបាយនោះ ក្រសួងមហាផ្ទៃត្រូវចុះបញ្ជីគណបក្សនយោបាយនោះភ្លាមតាមការកំណត់ដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ ។

មាត្រា ២៦ .- ថ្មី

គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ ត្រូវបញ្ជូនទៅក្រសួងមហាផ្ទៃនូវបញ្ជីឈ្មោះប្រធាន និងអនុប្រធាន នៃគណបក្សនយោបាយ ក្នុងករណីដែលមានអនុប្រធាន និងសមាសភាព នៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេប ដែលមានបិទរូបថតទំហំ ០៤ (បួន) គុណនឹង ០៦ (ប្រាំមួយ) ។

ការផ្លាស់ប្តូរប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេបរបស់សមាសភាពថ្មី ដែលមានបិទរូបថតទំហំ ០៤ (បួន) គុណនឹង ០៦ (ប្រាំមួយ)។

គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ អាចប្តូរឈ្មោះ សញ្ញាសម្គាល់ ទីស្នាក់ការ កណ្តាល កែប្រែគោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗ ឬធ្វើវិសោធនកម្មលើលក្ខន្តិកៈបានស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយខ្លួន។ ក្នុងករណីនេះគណបក្សនយោបាយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវសំណុំឯកសារថ្មីដែលកែប្រែរួចហើយ។

ជំពូកទី ៦
ហិរញ្ញវត្ថុរបស់គណបក្សនយោបាយ

មាត្រា ២៧ .-

ចាត់ទុកជាហិរញ្ញវត្ថុរបស់គណបក្សនយោបាយចំណូលដែលបានមកពីៈ

១- វិភាគទាន ឬភាគទានរបស់សមាជិក។

២- ចំណូលផ្សេងៗ របស់គណបក្សនយោបាយដែលបានមកពីការធ្វើអាជីវកម្មស្របច្បាប់។

៣- ប្រាក់ពីថវិការបស់រដ្ឋ តាមការកំណត់ដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ។

៤- អំណោយរបស់ក្រុមហ៊ុនឯកជនខ្មែរ ឬសប្បុរសជនខ្មែរ។

៥- ទ្រព្យសម្បត្តិផ្ទាល់របស់គណបក្សនយោបាយ។

មាត្រា ២៨ .-

រដ្ឋអាចផ្តល់ប្រាក់ពីថវិកាជាតិស្មើៗគ្នា ដល់គ្រប់គណបក្សនយោបាយ សម្រាប់តែប្រើប្រាស់ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

គណបក្សនយោបាយណាដែលមិនបានទទួលសន្លឹកឆ្នោតគាំទ្រចំនួន៣% នៃសន្លឹកឆ្នោតបានការសរុបទូទាំងប្រទេស ឬមិនបានទទួលអាសនៈមួយក្នុងសភា គណបក្សនយោបាយនោះត្រូវសងប្រាក់នោះគ្រប់ចំនួនមករដ្ឋវិញក្នុងរយៈពេល៣ខែ យ៉ាងយូរ ចាប់ពីថ្ងៃប្រកាសលទ្ធផលជាស្ថាពរ នៃការបោះឆ្នោត។

មាត្រា ២៩ .- ថ្មី

គណបក្សនយោបាយត្រូវបានហាមឃាត់មិនឲ្យទទួលវិភាគទាន ទោះជាតាមរូបភាពណាក៏ដោយ ពីស្ថាប័នរដ្ឋ សមាគម អង្គការមិនមែនរដ្ឋាភិបាល សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ វិទ្យាស្ថានសាធារណៈ លើកលែងតែករណីដូចមានចែងក្នុងមាត្រា២៨ នៃច្បាប់នេះ។

គណបក្សនយោបាយត្រូវបានហាមឃាត់មិនឲ្យទទួលវិភាគទាន ទោះតាមរូបភាពណាក៏ដោយ ពីស្ថាប័នបរទេស ក្រុមហ៊ុនបរទេស ជនបរទេស ឬអង្គការដែលមានប្រភពហិរញ្ញប្បទានពីបរទេស។

ជំពូកទី ៧
របាយការណ៍ និងការត្រួតពិនិត្យ

មាត្រា ៣០ .-

របាយការណ៍ និងឯកសារពាក់ព័ន្ធនិងគណនេយ្យត្រូវតម្កល់ទុករយៈពេលយ៉ាងតិច៧ឆ្នាំ ហើយអាចអនុញ្ញាតឲ្យត្រួតពិនិត្យ ដោយអនុលោមតាមលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយ ឬការសម្រេចរបស់តុលាការ ឬស្ថាប័នមានសមត្ថកិច្ច។

មាត្រា ៣១ .-

គណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយរួចហើយ ត្រូវផ្ញើរបាយការណ៍មកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យបានមុនថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ។ របាយការណ៍ត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ និងហេរញ្ញិក។

របាយការណ៍នេះត្រូវមានខ្លឹមសារ និងឯកសារដូចខាងក្រោម៖

១- សកម្មភាពសំខាន់ៗ របស់គណបក្សនយោបាយ។

២- តារាងតុល្យភាព ដែលបង្ហាញនូវប្រាក់ចំណូល និងប្រាក់ចំណាយប្រចាំឆ្នាំតាមប្រភេទ។ តារាងតុល្យភាពនេះ ត្រូវរៀបចំឡើងដោយគណនេយ្យរបស់គណបក្សនយោបាយ។

៣- បញ្ជីតុល្យការគណនីរបស់គណបក្សនយោបាយនៅក្នុងធនាគារ។

៤- បញ្ជីតុល្យការ នៃទ្រព្យសម្បត្តិទាំងអស់ រាប់បញ្ចូលទាំងទ្រព្យសម្បត្តិជាកម្មសិទ្ធិ ឬផលកម្រៃក្នុងជំនួញ និងបំណុលរបស់គណបក្សនយោបាយ។

មាត្រា ៣២ .-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវក្នុងការពិនិត្យបញ្ជីតុល្យការទាំងឡាយដែលមានចែងក្នុងចំណុច២,៣,៤ មាត្រា៣១ នៃច្បាប់នេះ។

ជំពូកទី ៨
ការរំលាយ ការរួមបញ្ចូលគ្នា និងការធ្វើសម្ព័ន្ធភាពគណបក្សនយោបាយ

មាត្រា ៣៣ .-

គណបក្សនយោបាយអាចរំលាយខ្លួនឯងបាន តាមសេចក្តីសម្រេចរបស់មហាសន្និបាត ដោយ

អនុលោមតាមលក្ខន្តិកៈរបស់ខ្លួន បន្ទាប់ពីបានធ្វើការជម្រះបញ្ជី និងចាត់ចែងទ្រព្យសម្បត្តិរបស់គណបក្សនយោបាយ។ គណបក្សនយោបាយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ពីការរំលាយនេះដល់ក្រសួងមហាផ្ទៃភ្លាមដើម្បីលុបឈ្មោះគណបក្សនយោបាយនោះចេញពីបញ្ជីគណបក្សនយោបាយ។

មាត្រា ៣៤ .. ថ្មី

គ្មានសមត្ថកិច្ចណាមានសិទ្ធិរំលាយគណបក្សនយោបាយណាមួយបានឡើយ លើកលែងគណបក្សនោះ ត្រូវបានរំលាយដោយតុលាការ។

មាត្រា ៣៥ ..

គណបក្សនយោបាយដែលត្រូវបានប្រកាសរំលាយ ដូចមានចែងក្នុង**មាត្រា៣៣** នៃច្បាប់នេះ ការចាត់ចែងទ្រព្យសម្បត្តិដែលនៅសេសសល់ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត។

មាត្រា ៣៦ ..

គណបក្សនយោបាយអាចប្រកាសរួមបញ្ចូលគ្នា ជាមួយគណបក្សនយោបាយផ្សេងទៀតបានតាមការកំណត់របស់លក្ខន្តិកៈ។ ក្នុងករណីដែលលក្ខន្តិកៈមិនបានចែង ត្រូវអនុវត្តតាមសេចក្តីសម្រេច របស់មហាសន្និបាតគណបក្សនយោបាយ។

ក្រសួងមហាផ្ទៃត្រូវលុបឈ្មោះគណបក្សនយោបាយដែលបានប្រកាសរួមបញ្ចូលគ្នានោះ ចេញពីបញ្ជីគណបក្សនយោបាយ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីការរួមបញ្ចូលនោះ ។

មាត្រា ៣៧ ..

គណបក្សនយោបាយអាចធ្វើសម្ព័ន្ធភាពទ្វេភាគី ឬពហុភាគីជាមួយគ្នាបានដោយសេរីតាមសេចក្តីសម្រេចរបស់គណបក្សនយោបាយនីមួយៗ។

ជំពូកទី ៩ ថ្មី
វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ

មាត្រា ៣៨ .. ថ្មី

គ្រប់គណបក្សនយោបាយទាំងអស់ត្រូវគោរពរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា។

ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តខុសទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃអាចចាត់វិធានការដូចខាងក្រោម៖

- ចេញលិខិតជូនដំណឹងឲ្យគណបក្សនយោបាយនោះ ធ្វើការកែតម្រូវក្នុងរយៈពេលមួយជាកំណត់។
- ធ្វើការព្រមានជាលាយលក្ខណ៍អក្សរ និងចាត់វិធានការបញ្ឈប់សកម្មភាពខុសច្បាប់ក្នុងករណីចាំបាច់។
- សម្រេចផ្អាកសកម្មភាពរបស់គណបក្សនយោបាយនោះជាបណ្តោះអាសន្ន ក្នុងរយៈពេលមួយជាកំណត់។
- ប្តឹងទៅតុលាការកំពូលដើម្បីរំលាយគណបក្សនយោបាយនោះ ក្នុងករណីកំហុសមានលក្ខណៈធ្ងន់ធ្ងរ។

មាត្រា ៣៩ .. ថ្មី

ត្រូវផាកពិន័យជាប្រាក់ចំនួន ៥.000.000 (ប្រាំលាន) រៀល ដោយក្រសួងមហាផ្ទៃ ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៣១ នៃច្បាប់នេះ ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀត ផាកពិន័យជាប្រាក់ទ្វេមួយជាពីរ ហើយក្រសួងមហាផ្ទៃអាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្ន ក្នុងរយៈពេលមួយជាកំណត់។

មាត្រា ៤០ .. ថ្មី

គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា២៩ថ្មី នៃច្បាប់នេះ ត្រូវផាកពិន័យជាប្រាក់ដោយក្រសួងមហាផ្ទៃ ចំនួន២០.០០០.០០០(ម្ភៃលាន)រៀល។ ក្នុងករណីវិភាគទានដែលគណបក្សនយោបាយបានទទួលដោយល្មើសនឹងមាត្រា២៩ថ្មី នៃច្បាប់នេះ មានតម្លៃលើសពី ២០.០០០.០០០ (ម្ភៃលាន)រៀល ត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរនៃតម្លៃនៃវិភាគទាននោះ។ ក្រសួងមហាផ្ទៃ អាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្នក្នុងរយៈពេលមួយជាកំណត់។

ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀតត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរ នៃប្រាក់ពិន័យលើកមុន ហើយក្រសួងមហាផ្ទៃអាចប្តឹងរំលាយគណបក្សនយោបាយនោះទៅតុលាការកំពូល។

មាត្រា ៤១ .. ថ្មី

ត្រូវផាកពិន័យជាប្រាក់ចំនួន ៣.០០០.០០០(បីលាន)រៀល ដោយក្រសួងមហាផ្ទៃ ចំពោះជនណា ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៥ និងកថាខណ្ឌទី២ មាត្រា១៥ នៃច្បាប់នេះ។

មាត្រា ៤២ .. ថ្មី

ត្រូវពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន)រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន) រៀល និង/ឬផ្តន្ទាទោសដាក់ពន្ធនាគារពី០១ (មួយ)ខែ ដល់០១(មួយ)ឆ្នាំ ចំពោះជនណាដែលបានប្រព្រឹត្តករណីណាមួយដូចខាងក្រោម៖

១- បន្តគ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដែលក្រសួងមហាផ្ទៃ មិនយល់ព្រមឲ្យចុះបញ្ជីគណបក្សនយោបាយ។

២- បន្តគ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដែលតុលាការបានសម្រេចរំលាយជាស្ថាពរ។

៣- គ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដោយមិនបានសុំចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ ក្នុងរយៈពេលលើសពី១៨០ (មួយរយប៉ែតសិប)ថ្ងៃ គិតចាប់ពីថ្ងៃធ្វើការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការបណ្តោះអាសន្នដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ។

៤- នៅតែបន្តធ្វើសកម្មភាពក្នុងនាមគណបក្សនយោបាយ ទោះជាមានសេចក្តីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះក៏ដោយ ។

៥- នៅតែបន្តបើកទីស្នាក់ការគណបក្សនយោបាយខ្លួន ទោះជាមានសេចក្តីសម្រេចស្ថាពរបស់តុលាការសម្រេចរំលាយគណបក្សនយោបាយនោះក៏ដោយ។

មាត្រា ៤៣ .. ថ្មី

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ ដូចមានចែងក្នុងជំពូកនេះ អាចប្តឹងតវ៉ាទៅតុលាការកំពូលក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតពីកាលបរិច្ឆេទទទួលបានសេចក្តីសម្រេចនេះ។ ក្នុងអំឡុងពេលនៃការប្តឹងតវ៉ា និងអំឡុងពេលនៃការដោះស្រាយបណ្តឹងតវ៉ាសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ មិនមានអានុភាពអនុវត្តឡើយ លើកលែងតែសេចក្តីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយជាបណ្តោះអាសន្ន ។

មាត្រា ៤៤ .. ថ្មី(ពីរ)

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៦ថ្មី(ពីរ)នៃច្បាប់នេះ និងមាត្រា៧ នៃច្បាប់ស្តីពីគណបក្សនយោបាយ តុលាការអាចសម្រេចដូចខាងក្រោម៖

- ផ្អាកសកម្មភាពគណបក្សនយោបាយនោះមិនលើសពី៥(ប្រាំ)ឆ្នាំ។
- រំលាយគណបក្សនយោបាយនោះ។

មាត្រា ៤៥ .. ថ្មី

តុលាការដែលមានសមត្ថកិច្ច ដើម្បីពិនិត្យលើបណ្តឹងនានាដោយអនុវត្តតាមច្បាប់នេះ គឺតុលាការកំពូល។ ដោយឡែកចំពោះមាត្រា៤២ ថ្មី នៃច្បាប់នេះ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

តំណាងមហាអយ្យការអមតុលាការកំពូលត្រូវចូលរួមសុំឲ្យមានការគោរពច្បាប់ នៅក្នុងពេលដែលមានបណ្តឹងដាក់ជូនតុលាការកំពូលពិនិត្យ ។

ក្នុងករណីដែលគណបក្សនយោបាយត្រូវបានរំលាយ តុលាការអាចសម្រេចហាមឃាត់ការធ្វើសកម្មភាពនយោបាយរបស់ថ្នាក់ដឹកនាំនៃគណបក្សនយោបាយនោះសម្រាប់រយៈពេល០៥ (ប្រាំ) ឆ្នាំបាន។

តុលាការកំពូលត្រូវសម្រេចសេចក្តីលើអង្គហេតុ និងអង្គច្បាប់ ដោយសាកពេញអង្គ។ សាលដីការបស់តុលាការកំពូលជាសេចក្តីសម្រេចចិទ្ធផ្លូវតវ៉ា ។

មាត្រា ៤៥ .. ថ្មី(ស្នូនម្ដុយ)

គណបក្សនយោបាយដែលត្រូវបានសម្រេចផ្តាកសកម្មភាព មិនត្រូវបានអនុញ្ញាតឲ្យចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឡើយ។

ត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលគណបក្សនយោបាយនោះត្រូវបានសម្រេចផ្តាកសកម្មភាព ឬត្រូវបានសម្រេចរំលាយ ស្របតាមច្បាប់នេះ។

បុគ្គលដែលត្រូវបានតុលាការសម្រេចហាមឃាត់ការធ្វើសកម្មភាពនយោបាយ មិនអាច៖

- បង្កើតគណបក្សនយោបាយ ឬ
- ចូលរួមក្នុងគណបក្សនយោបាយណាមួយ ឬ
- ឈរឈ្មោះឲ្យគេបោះឆ្នោត ឬ
- ធ្វើសកម្មភាពណាមួយគាំទ្រ ឬប្រឆាំងគណបក្សណាមួយឡើយ។

បុគ្គលដែលត្រូវបានតុលាការសម្រេចហាមឃាត់ការធ្វើសកម្មភាពនយោបាយនេះ នឹងអាចទទួលបានវិញនូវសិទ្ធិនយោបាយពេញលេញដោយពេញច្បាប់ បន្ទាប់ពីផុតរយៈពេលនៃការហាមឃាត់ដែលកំណត់ដោយសាលដីការបស់តុលាការកំពូល ឬក្នុងករណីដែលបុគ្គលនោះ ត្រូវបានផ្តល់នីតិសម្បទាឡើងវិញដោយព្រះមហាក្សត្រ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា ៤៦ .. ថ្មី

ការអនុវត្តជំពូកនេះ មិនរារាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ ក្នុងករណីដែលអំពើបំពានលើបញ្ញត្តិដែលចែងក្នុងជំពូកនេះ ជាបទល្មើសដែលបានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌ ។

មាត្រា ៤៧ .. ថ្មី

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបកាយ) នៃគន្លឹទី៨ (នីតិវិធីប្រតិបត្តិ) នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្តីសម្រេចអំពីប្រាក់ពិន័យបានចូលជាស្ថាពរ ។

ជំពូកទី ១០
អន្តរប្បញ្ញត្តិ

មាត្រា ៤៨ .. ថ្មី

បន្ទាប់ពីច្បាប់នេះចូលជាធរមាន គណបក្សនយោបាយទាំងអស់ដែលត្រូវបានបង្កើត និងបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជសរកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ត្រូវបន្តសុពលភាព និងអាចធ្វើសកម្មភាពស្របតាមច្បាប់នេះ និងច្បាប់ជាធរមានផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែគណបក្សនយោបាយទាំងនេះត្រូវបំពេញសំណុំបែបបទធ្វើនិយ័តកម្មស្របតាមបទប្បញ្ញត្តិ នៃច្បាប់នេះក្នុងរយៈពេល៩០ (កៅសិប) ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ។

មាត្រា ៤៨ .. ថ្មី(ស្នូន)

ចំពោះគណបក្សនយោបាយណាដែលមានឈ្មោះ ឬសញ្ញាសម្គាល់របស់គណបក្សនយោបាយជាឈ្មោះ ឬរូបភាពរបស់រូបវន្តបុគ្គល ត្រូវធ្វើការផ្លាស់ប្តូរឈ្មោះ ឬសញ្ញាសម្គាល់ឲ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេល៩០ (កៅសិប)ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមាន។

ជំពូកទី ១១
អវសានប្បញ្ញត្តិ

មាត្រា ៤៩ .. ថ្មី (**មាត្រា៤៤ ចាស់**)

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥0 .. ថ្មី (**មាត្រា៤៥ ចាស់**)

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ថ្ងៃពុធ ១១រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី០២ ខែ មករា ឆ្នាំ២០១៩

ពរលៈ.១៩០១.០០១

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្រង់ព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ចិន ឈិន**

កំណត់សំគាល់

ច្បាប់ស្តីពីគណបក្សនយោយ ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ ជស/រកម/១១៩៧/ ០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ និងត្រូវបានធ្វើវិសោធនកម្មចំនួន៣(បី)លើក ដូចខាងក្រោម៖

លើកទី១៖

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោយ ដែលរដ្ឋសភាអនុម័តកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាវិសាមញ្ញ នីតិកាលទី៥ ដូចតទៅ ៖

- ចំណងជើងជំពូកទី៤ ត្រូវបានកែប្រែទៅជាជំពូកទី៤ថ្មី អង្គការនានា និងថ្នាក់ដឹកនាំរបស់ គណបក្សនយោបាយ។

- ចំណងជើងជំពូកទី៩ ត្រូវបានកែប្រែទៅជាជំពូកទី៩ថ្មី វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ

- មាត្រា ៦ មាត្រា ១២ មាត្រា ១៧ មាត្រា ១៨ មាត្រា ១៩ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៩ មាត្រា ៣៤ និងមាត្រាទាំងឡាយពីជំពូកទី៩ ដល់ជំពូកទី១១។

លើកទី២៖

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោយ ដែលរដ្ឋសភាអនុម័តកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ ដូចតទៅ ៖

- មាត្រា ៦ថ្មី មាត្រា១១ និងមាត្រា ៤៨ថ្មី ត្រូវបានកែប្រែ និងត្រូវបានបន្ថែម មាត្រា ៤៥ថ្មី(ស្ងួន) និងមាត្រា ៤៨ថ្មី(ស្ងួន) ។

លើកទី៣៖

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៤៩ថ្មី(ស្ងួន) នៃច្បាប់ស្តីពីគណបក្សនយោយ ដែលរដ្ឋសភា អនុម័តកាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ ដូចតទៅ ៖

- មាត្រា៤៥ថ្មី(ស្ងួន) ត្រូវបានកែប្រែទៅជា មាត្រា៤៥ថ្មី(ស្ងួនមួយ)។

ជស/រកម/១១៩៧០៨

ព្រះរាជក្រម

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

ព្រះបរមរតនកោដ្ឋ ឧត្តមភក្តិឥស្សរៈ អគ្គមហាបុរសរតនៈ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ទទួលសារ
លេខ.....
ថ្ងៃទី.....
ម៉ោង.....

****

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ស្តីពីការដែលទទួលឯករាជ្យពីបារាំង
- បានឃើញព្រះរាជក្រមលេខ ០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៥៤ ស្តីពីការប្រើប្រាស់ទង់ជាតិ ត្រា និងឈ្មោះរដ្ឋបត្តិ
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៥៤.៥០ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៥៤ ស្តីពីការកែសម្រួលបទបញ្ជាស្តីពីការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩៥៧.១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៥៧ ស្តីពីការកែសម្រួលបទបញ្ជាស្តីពីការបោះឆ្នោតសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.០៩ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតព្រឹទ្ធសភា
- តាមសេចក្តីក្រាបបង្គំទូលសូមរំលឹកពីមាត្រា២ថ្មីនៃច្បាប់ស្តីពីការបង្កើតព្រឹទ្ធសភា ដែលមានខ្លឹមសារថា ព្រឹទ្ធសភាមានសមាជិកចំនួន ស្មើពាក់កណ្តាលនៃចំនួនសមាជិកសភា ដែល

ឧបសម្ព័ន្ធ ១១
អនុលោមច្បាប់ស្តីពី

មាត្រា ៤៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជាឱកាសណ៍ ។

មាត្រា ៤៥.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧
ក្នុងព្រះបរមរាជ ស័ក ពុទ្ធសាសនាបរិនិព្វាន
ព្រះវស្សាទី

ជា ស៊ីម

បានឯកភាពសេចក្តីព្រាងច្បាប់នេះថ្វាយ
សូមទ្រង់ព្រះមេត្តាប្រទានព្រះបរមានុញ្ញាត

នាយករដ្ឋមន្ត្រីទី១ នៃព្រះរាជាណាចក្រកម្ពុជា

ហ៊ុន សែន

បានចំណាបជូន
ឯកឧត្តមប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ
សម ប្រធានរដ្ឋសភា និងជាប្រធានក្រុមប្រឹក្សាសូរិយោបនីយ៍

ស រង្ស៊ី



ព្រះរាជក្រម

ន.ស/រកម/០៣១៧/០០៣ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានតូចិជាតិសាសនា ក្សេត្តនក្តីយា ខេមរាជ្ជាកម្ត្រ ពុទ្ធិង្គ្លាចតមហាអប្ត្រ
ខេមរាជនា សម្តេចោតាស អង្គុជ្ជងអាជ្ជរជ្ជមុរណាសន្តិ សុតមន្តណា សីរីធិមុណា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ច្បាប់ធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៤០៣ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៩៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៨៥/០២៧/២០១៧ អបធ.ច ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



ហត្ថាភ័ន...

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឆ្នាំ ២០១៧

ក្នុងព្រះបរមនាមនិងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ជីរ

សម្តេចតិបុលសេនាតេជ្ជ សាយ ឈុំ

នាយសារ. ១៧០៣. ២៥៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមទ្បាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ:២៥៨ ស.ណ

សំណេរនេះមានត្រាជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃ ០៧ ខែ ឆ្នាំ ២០១៧

អគ្គលេខាធិការរដ្ឋាភិបាល

ឯកឧត្តម សយ សុខា



ព្រះរាជក្រម

ន.ស/រកម/០៧១៧/០០៧

យើង

ព្រះអរុណរាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សហគតូមិជាតិសាសនា រក្សាពន្ធិយា ខេមរាជ្ជពាស្ត្រ ពុទ្ធិគ្រោចពាមហាក្សត្រ

ខេមរាជនា សម្ងហោតាស អម្ពុជ៦តរាជជ្ជេម្ងលោសត្តិ សុភមង្គលា សិរីវិមុលា

ខេមរាស្រីមិត្តស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៩៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះ ទាំងស្រុងកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៨៧/០២៧/២០១៧ សប.ច ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



ឲ្យសាសនា ប្រាសាទអង្គរវត្ត ឬព្រះឆាយាលក្ខណ៍ ឬរូបសំណាករបស់ព្រះមហាក្សត្រខ្មែរ គ្រប់អង្គ ឬរូបភាពរបស់រូបវន្តបុគ្គលឡើយ ។

មាត្រា ៤៤.- ថ្មី(ពីរ)

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៦ថ្មី(ពីរ) នៃច្បាប់នេះ និងមាត្រា៧ នៃច្បាប់ស្តីពីគណបក្សនយោបាយ តុលាការអាចសម្រេចដូចខាងក្រោម ៖

-ផ្អាកសកម្មភាពគណបក្សនយោបាយនោះមិនលើសពី ៥(ប្រាំ)ឆ្នាំ ។

-លែយគណបក្សនយោបាយនោះ ។

មាត្រា ៤៥.- ថ្មី(ស្នង)

គណបក្សនយោបាយដែលត្រូវបានសម្រេចផ្អាកសកម្មភាព មិនត្រូវបានអនុញ្ញាតឲ្យចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឡើយ ។

ត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលគណបក្សនយោបាយនោះត្រូវបានសម្រេចផ្អាកសកម្មភាព ឬត្រូវបានសម្រេចលែយ ស្របតាមច្បាប់នេះ ។

មាត្រា ៤៨.-ថ្មី(ស្នង)

ចំពោះគណបក្សនយោបាយណាដែលមានឈ្មោះ ឬសញ្ញាសម្គាល់របស់គណបក្សនយោបាយជាឈ្មោះ ឬរូបភាពរបស់រូបវន្តបុគ្គល ត្រូវធ្វើការផ្លាស់ប្តូរឈ្មោះ ឬសញ្ញាសម្គាល់ ឲ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ។

មាត្រាពីរ.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៧

ក្នុងព្រះបរមនាមនិងតាមព្រះរាជក្រាសំបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ជការ

សម្តេចតិបុលសេនាតន្តី សាយ ឈុំ

ត.ស.ន.១៧០៧.៤៨៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមទ្បាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ: ៥៤៧ ស.ណ

សំណៅដែលមានតុល្យភាពរបស់ធនាគារជាតិនៃកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១៧

អភ្នុលេខាធិការរដ្ឋមន្ត្រីទទួលបន្ទុក

សយ សុខា

ព្រះរាជក្រម

ណស/រកម/០១១៩/០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
ខេមរាភិវឌ្ឍន៍ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន
ខេមរាស្រីតិភក្តី ព្រះមហាក្សត្រីនៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១៦ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៨៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៨៥ថ្មី (ស្នូន) នៃច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ នាសម័យប្រជុំផ្ដៀសការលើកទី១ និតិកាលទី៦ រួចហើយនោះ ដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះ ទាំងស្រុងតាមលិខិតថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨ ក្នុងសម័យប្រជុំវេនល្ងាចអង្គលើកទី២ និតិកាលទី៨ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ ១៩៧/០០៥/២០១៨ សជឧ.ច ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ច្បាប់
ស្តីពី
វិសោធនកម្មមាត្រា ៤៥ថ្មី (ស្នូន) នៃច្បាប់ស្តីពីគណបក្សនយោបាយ

មាត្រាមួយ៖

មាត្រា ៤៥ថ្មី (ស្នូន) នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

មាត្រា ៤៥...ថ្មី (ស្នូនមួយ)

គណបក្សនយោបាយដែលត្រូវបានសម្រេចផ្អាកសកម្មភាព មិនត្រូវបានអនុញ្ញាតឱ្យចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឡើយ ។

ត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលគណបក្សនយោបាយនោះ ត្រូវបានសម្រេចផ្អាកសកម្មភាព ឬត្រូវបានសម្រេចរំលាយ ស្របតាមច្បាប់នេះ ។

បុគ្គលដែលត្រូវបានតុលាការសម្រេចហាមឃាត់ការធ្វើសកម្មភាពនយោបាយ មិនអាច :

-បង្កើតគណបក្សនយោបាយ ឬ

-ចូលរួមក្នុងគណបក្សនយោបាយណាមួយ ឬ

-ឈរឈ្មោះឱ្យគេបោះឆ្នោត ឬ

-ធ្វើសកម្មភាពណាមួយគាំទ្រ ឬប្រឆាំងគណបក្សណាមួយបានឡើយ ។

បុគ្គលដែលត្រូវបានតុលាការសម្រេចហាមឃាត់ការធ្វើសកម្មភាពនយោបាយនេះ នឹងអាចទទួលបានវិញនូវសិទ្ធិនយោបាយពេញលេញដោយពេញច្បាប់ បន្ទាប់ពីផុតរយៈពេលនៃការហាមឃាត់ដែលកំណត់ដោយសាលដីការបស់តុលាការកំពូល ឬក្នុងករណីដែលបុគ្គលនោះ ត្រូវបានផ្តល់នីតិសម្បទាឡើងវិញដោយព្រះមហាក្សត្រ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ហត្ថាតីរ...

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៨

លេខ: ១៨០១.០០៧

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្រង់ព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិសោភ័ណ្ឌ ប៊ិន ឈិន

ឧបសម្ព័ន្ធ ៣

ព្រះរាជក្រម

នស/រកម/០៣១៥/០០៣ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្រាតភូមិន្ទាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិឡ្ហាចរាមហាក្សត្រ
ខេមរាជ្ជា សម្ភូហោតាស កម្ពុជឯករាជ្ជូបរណាសន្តិ សុតមន្តណា សិរីតិបុណា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ទទួលកាលបរិច្ឆេទ
ចូល លេខ ៥២៧៧
ថ្ងៃទី ២៧ ខែ ភ្នំ ឆ្នាំ ២០១៤ ម៉ោង ១៧:២០
បញ្ជូនទៅ ៩-៩

- បានទ្រង់ឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៩៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៦ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៤/០០២/២០១៥ សប.ច ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ច្បាប់
ស្តីពី
ការបោះឆ្នោតជ្រើសតាំង
តំណាងរាស្ត្រ



ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលជាសមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវអនុវត្តតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

មាត្រា ៣.-

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើឡើងរៀងរាល់ ០៥ (ប្រាំ) ឆ្នាំម្តង ។

កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើនៅថ្ងៃអាទិត្យតែ ០១ (មួយ) ថ្ងៃ លើកលែងតែក្នុងស្ថានភាពណាមួយដូចខាងក្រោម ៖

-ក្នុងករណីប្រធានសក្តិដែលចាំបាច់ត្រូវលើកថ្ងៃបោះឆ្នោត ។

-ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ។ ក្នុងករណីនេះការបោះឆ្នោតជ្រើសតាំងរដ្ឋសភាថ្មី ត្រូវប្រព្រឹត្តទៅក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃយ៉ាងយូរ ចាប់ពីថ្ងៃរំលាយរដ្ឋសភា ។

-ក្នុងករណីដែលរដ្ឋសភាត្រូវបានប្រកាសឲ្យបន្តនីតិកាលរបស់ខ្លួន ស្របតាមកថាខណ្ឌទី ៥ នៃមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤.-

ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានចែងក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ជំពូកទី ២
ប្រព័ន្ធបោះឆ្នោត និងការកំណត់អាសនៈ

មាត្រា ៥.-

តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រតាមរាជធានី ខេត្ត ដោយយករាជធានី ខេត្តជាមណ្ឌលបោះឆ្នោត ។

មាត្រា ៦.-

អាសនៈនៅក្នុងរដ្ឋសភាមានចំនួន ១២៥ (មួយរយម្ភៃប្រាំ) ដែលបែងចែកតាមមណ្ឌលរាជធានី ខេត្ត ដូចខាងក្រោម ៖

-មណ្ឌលខេត្តបន្ទាយមានជ័យ	ចំនួន ០៦ (ប្រាំមួយ) អាសនៈ
-មណ្ឌលខេត្តបាត់ដំបង	ចំនួន ០៨ (ប្រាំបី) អាសនៈ
-មណ្ឌលខេត្តកំពង់ចាម	ចំនួន ១០ (ដប់) អាសនៈ
-មណ្ឌលខេត្តត្បូងឃ្មុំ	ចំនួន ០៨ (ប្រាំបី) អាសនៈ
-មណ្ឌលខេត្តកំពង់ឆ្នាំង	ចំនួន ០៤ (បួន) អាសនៈ
-មណ្ឌលខេត្តកំពង់ស្ពឺ	ចំនួន ០៦ (ប្រាំមួយ) អាសនៈ
-មណ្ឌលខេត្តកំពង់ធំ	ចំនួន ០៦ (ប្រាំមួយ) អាសនៈ
-មណ្ឌលខេត្តកំពត	ចំនួន ០៦ (ប្រាំមួយ) អាសនៈ
-មណ្ឌលខេត្តកណ្តាល	ចំនួន ១១ (ដប់មួយ) អាសនៈ
-មណ្ឌលខេត្តកោះកុង	ចំនួន ០១ (មួយ) អាសនៈ
-មណ្ឌលខេត្តក្រចេះ	ចំនួន ០៣ (បី) អាសនៈ
-មណ្ឌលខេត្តមណ្ឌលគិរី	ចំនួន ០១ (មួយ) អាសនៈ
-មណ្ឌលរាជធានីភ្នំពេញ	ចំនួន ១២ (ដប់ពីរ) អាសនៈ
-មណ្ឌលខេត្តព្រះវិហារ	ចំនួន ០១ (មួយ) អាសនៈ
-មណ្ឌលខេត្តព្រៃវែង	ចំនួន ១១ (ដប់មួយ) អាសនៈ
-មណ្ឌលខេត្តពោធិ៍សាត់	ចំនួន ០៤ (បួន) អាសនៈ
-មណ្ឌលខេត្តរតនគិរី	ចំនួន ០១ (មួយ) អាសនៈ

-មណ្ឌលខេត្តសៀមរាប	ចំនួន ០៦ (ប្រាំមួយ) អាសនៈ
-មណ្ឌលខេត្តព្រះសីហនុ	ចំនួន ០៣ (បី) អាសនៈ
-មណ្ឌលខេត្តស្ទឹងត្រែង	ចំនួន ០១ (មួយ) អាសនៈ
-មណ្ឌលខេត្តស្វាយរៀង	ចំនួន ០៥ (ប្រាំ) អាសនៈ
-មណ្ឌលខេត្តតាកែវ	ចំនួន ០៨ (ប្រាំបី) អាសនៈ
-មណ្ឌលខេត្តកែប	ចំនួន ០១ (មួយ) អាសនៈ
-មណ្ឌលខេត្តប៉ៃលិន	ចំនួន ០១ (មួយ) អាសនៈ
-មណ្ឌលខេត្តឧត្តរមានជ័យ	ចំនួន ០១ (មួយ) អាសនៈ ។

ជំពូកទី ៣
ភ្នាក់ងារគណបក្សនយោបាយ
និងអ្នកសង្កេតការណ៍ឆ្នោត

មាត្រា ៧.-

គណបក្សនយោបាយនីមួយៗដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួន ០២ (ពីរ) រូប ពេញសិទ្ធិ ០១ (មួយ) រូប និងបម្រុង០១ (មួយ) រូប ក្នុងចំណោមអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហៅថាភ្នាក់ងារគណបក្សនយោបាយ ដើម្បីចូលរួមសង្កេតការណ៍មើលការបោះឆ្នោត តាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ។

ភ្នាក់ងារពេញសិទ្ធិត្រូវបានអនុញ្ញាតឲ្យចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

ភ្នាក់ងារបម្រុងត្រូវបានអនុញ្ញាតឲ្យជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីដែលភ្នាក់ងារពេញសិទ្ធិអវត្តមាន។

គណបក្សនយោបាយនីមួយៗ មានសិទ្ធិផ្លាស់ប្តូរភ្នាក់ងារគណបក្សនយោបាយរបស់ខ្លួន ។

មាត្រា ៨.-

គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងរបស់ខ្លួនមកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជនតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣៧ នៃច្បាប់នេះ ។

ពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ ត្រូវបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងលិខិតបញ្ជាក់ការចុះឈ្មោះបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ និងការិយាល័យបោះឆ្នោតដែលភ្នាក់ងារនោះត្រូវបំពេញការងារ ។

មាត្រា ៩.-

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចុះឈ្មោះ ហើយផ្តល់ប័ណ្ណសម្គាល់ដល់ភ្នាក់-ងារគណបក្សនយោបាយណាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះ ។

ក្នុងករណីភ្នាក់ងារពេញសិទ្ធិ និងភ្នាក់បម្រុងណាម្នាក់ដែលបំពេញមិនបានត្រឹមត្រូវតាមលក្ខ-ខណ្ឌ ដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះ-ឆ្នោត ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅគណបក្សនយោបាយសាមី ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្រោយពីបានទទួលពាក្យស្នើសុំ ។

គណបក្សនយោបាយ មានសិទ្ធិជាក់ពាក្យស្នើសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងរបស់ខ្លួនជាថ្មីមួយលើកទៀត ជំនួសឈ្មោះភ្នាក់ងារពេញសិទ្ធិ និង ភ្នាក់ងារបម្រុងដែលបានបដិសេធមកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធ ។

មាត្រា ១០.-

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចបញ្ជូនតំណាងរបស់ខ្លួនឲ្យមកចូលរួមជាអ្នកសង្កេតការណ៍បោះឆ្នោត ។

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវរៀបចំសុំចុះឈ្មោះជាអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅតាមពេលវេលាបែបបទ និងនីតិវិធី ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១១.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចុះឈ្មោះ និងផ្តល់ប័ណ្ណសម្គាល់ឲ្យអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលណា ដែលមានលក្ខណសម្បត្តិត្រឹមត្រូវតាមការកំណត់ ដូចមានចែងក្នុងបទបញ្ជា និងនីតិវិធីរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១២.-

ក្នុងករណីអ្នកសង្កេតការណ៍ណាម្នាក់ ដែលគ្មានលក្ខណសម្បត្តិគ្រប់គ្រាន់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅសាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានដាក់ពាក្យសុំសង្កេតការណ៍បោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំ ។

មាត្រា ១៣.-

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាថ្មីមួយលើកទៀត ជំនួសឈ្មោះអ្នកសង្កេតការណ៍ដែលបានបដិសេធ ឲ្យមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធ ។

មាត្រា ១៤.-

ភ្នាក់ងារគណបក្សនយោបាយនីមួយៗដែលទទួលបានការអនុញ្ញាត មានសិទ្ធិ មានវត្តមាននៅតាមការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោត តាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៥.-

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិជំទាស់ ឬតវ៉ា រាល់ការរំលោភទៅលើច្បាប់នេះ ឬលើបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតដែលភ្នាក់ងារនោះបានឃើញផ្ទាល់ ។

មាត្រា ១៦.-

ការជំទាស់ ឬការតវ៉ា ដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់នេះ ត្រូវធ្វើឡើងទៅប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានការិយាល័យរាប់សន្លឹកឆ្នោត នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ។

មាត្រា ១៧.-

របៀបបែបបទនៃការជំទាស់ ឬការតវ៉ា ដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា ១៦ នៃច្បាប់នេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៨.-

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយមិនត្រូវ ៖

-ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត ។

-រំខាន ឬជ្រៀតជ្រែកដំណើរការបោះឆ្នោត និងដំណើរការរាប់សន្លឹកឆ្នោត ។

-លើកឡើងនូវការជំទាស់ ឬការតវ៉ាទៅជនណាម្នាក់ក្រៅពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានការិយាល័យរាប់សន្លឹកឆ្នោតបានឡើយ ។

-រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៩.-

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត អ្នកសង្កេតការណ៍មិនត្រូវ ៖

-ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត ។

-រំខាន ឬជ្រៀតជ្រែកដំណើរការបោះឆ្នោត និងដំណើរការរាប់សន្លឹកឆ្នោត ។

-រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ២០.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការផ្សព្វផ្សាយដល់គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលទទួលសង្កេតការណ៍បោះឆ្នោត អំពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទប្បញ្ញត្តិសំខាន់ៗនៃច្បាប់នេះ ព្រមទាំងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

មាត្រា ២១.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និងតំណាងអង្គការអន្តរជាតិ ឲ្យចូលរួមសង្កេតការណ៍ ការបោះឆ្នោត ។

មាត្រា ២២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចតាក់តែងបទបញ្ជាសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា អនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។



ជំពូកទី ៤
ការចុះបញ្ជីគណបក្សនយោបាយ
ឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

មាត្រា ២៣.-

ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១-មានសញ្ជាតិខ្មែរពីកំណើត

២-មានអាយុ ២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត

៣-មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

៤-មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា

៥-មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត ។

មាត្រា ២៤.-

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ៖

១-មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ ក្នុងមុខតំណែង និងបព្វជិតសាសនា ឬ

២-ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

៣-ជនដែលត្រូវផ្តន្ទាទោសដកសិទ្ធិបោះឆ្នោតឬដកសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត

៤-ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ

៥-ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីឈ្មោះបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ

៦-សមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ

៧-សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ

៨-សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ២៥.-

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនាដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរយ៉ាងតិច ០៧ (ប្រាំពីរ)ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត ។

ប្រសិនបើសាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវដាក់ពាក្យសុំតាមឋានានុក្រមទៅសាមីក្រសួង ឬសាមីអង្គភាព ទៅបម្រើការក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម សាមីខ្លួនត្រូវមានសិទ្ធិឡើងឋានន្តរសក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ ។

នៅពេលចប់អាណត្តិជាតំណាងរាស្ត្រ សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច ។

មាត្រា ២៦.-

បែបបទនៃការអនុវត្តមាត្រា២៣ និងមាត្រា២៤ នៃច្បាប់នេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ២៧.-

ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវចាប់ផ្តើម ៩០ (កៅសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាផ្លូវការ គណបក្សនយោបាយត្រូវធ្វើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តាមបែបបទកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយ៉ាងយូរ ៧០ (ចិតសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោតដោយភ្ជាប់មកជាមួយ ៖

១-សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ ០១ (មួយ) ច្បាប់ ។

២-ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់និងសញ្ញាសម្គាល់គណបក្សនយោបាយ ។

៣-អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ ។

៤-បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតសរុបទូទាំងប្រទេស ។ បញ្ជីនេះត្រូវមានបេក្ខជនពេញសិទ្ធិចំនួនយ៉ាងតិច ១/៣ (មួយភាគបី) នៃចំនួនអាសនៈក្នុងរដ្ឋសភា និងបេក្ខជនបម្រុងចំនួនស្មើគ្នានឹងបេក្ខជនពេញសិទ្ធិ ។

៥-ឈ្មោះមណ្ឌលដែលគណបក្សនយោបាយមានបំណងទៅឈរ និងបញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលទាំងនោះ ។ បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលត្រូវមានចំនួនបេក្ខជនគ្រប់តាមចំនួនកំណត់អាសនៈ និងតាមគំរូដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្តល់ឲ្យ ។

ចំពោះមណ្ឌលបោះឆ្នោតដែលមានអាសនៈ ០១ (មួយ) ឬ ០២ (ពីរ) ត្រូវមានបេក្ខជនបម្រុងចំនួនយ៉ាងតិច ០៣ (បី) រូប ។

៦-សេចក្តីប្រកាសអំពីគណនីធនាគារ ដែលគណបក្សនយោបាយបានទុកប្រាក់ចំណូលផ្សេងៗ រួមមានទាំងវិភាគទានដែលបានមកពីប្រភពណាក៏ដោយ នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ។

៧-លក្ខន្តិកៈគណបក្សនយោបាយ និងឯកសារផ្សេងៗដែលបញ្ជាក់ពីការបង្កើតគណបក្សនយោបាយ ។

៨-សេចក្តីប្រកាសរបស់គណបក្សនយោបាយសន្យាថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលនៃការបោះឆ្នោតដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងចូលរួមអនុវត្តច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រមសីលធម៌ និងច្បាប់ស្តីពីគណបក្សនយោបាយ ។

៩-បញ្ជីរាយនាមគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលរបស់គណបក្សនយោបាយ ។

១០-បង្កាន់ដៃបង់ប្រាក់តម្កល់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដែលចេញដោយធនាគារជាតិ ។ ប្រាក់តម្កល់នេះត្រូវបានបង្វិលជូនទៅសាមីគណបក្សនយោបាយវិញ ក្នុងករណីដែលគណបក្សនយោបាយនោះ បានទទួលសន្លឹកឆ្នោតយ៉ាងតិច ០៣ (បី) ភាគរយ នៃចំនួនសន្លឹកឆ្នោតបានការ ឬបានអាសនៈ ០១ (មួយ) ក្នុងរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ការចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវប្រព្រឹត្តទៅរយៈពេល ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្រកាសរំលាយរដ្ឋសភា ។

មាត្រា ២៨.-

បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមមណ្ឌលត្រូវ ៖

១-ចុះឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ

២-មានសេចក្តីបញ្ជាក់អំពីការចុះឈ្មោះបោះឆ្នោត ដោយអាជ្ញាធរឃុំ សង្កាត់ដែលសាមីខ្លួនបេក្ខជននោះ បានចុះឈ្មោះបោះឆ្នោត

៣-ភ្ជាប់សេចក្តីប្រកាសរបស់បេក្ខជនយល់ព្រមទទួលការតែងតាំងជាបេក្ខជន តាមមណ្ឌលរបស់គណបក្សនយោបាយ ។

មាត្រា ២៩.-

បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់មណ្ឌលតែមួយគត់ ។

បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះលើសពីមួយមណ្ឌល ត្រូវបានប្រកាសថាបាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទោះជាសាមីខ្លួនទៅឈរឈ្មោះជាបេក្ខជនឈរឈ្មោះក្នុងគណបក្សនយោបាយណាផ្សេងទៀតក៏ដោយ ។

មាត្រា ៣០.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ ទីកន្លែង និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គឺរៀងរាល់ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង ៧:០០នាទី ដល់ម៉ោង ១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:៣០នាទី ។

ក្នុងករណីរដ្ឋសភាត្រូវបានរំលាយមុនអាណត្តិ រយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវកំណត់ផ្សេងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញបង្កាន់ដៃនៃការទទួលពាក្យដែលមានចុះហត្ថលេខា ឬស្នាមមេដៃនៃអ្នកទទួល និងអ្នកប្រគល់ជូនគណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងរក្សាគល់បញ្ជី ០១ (មួយ) ច្បាប់ទុកជាឯកសារ ។

មាត្រា ៣១.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពិនិត្យលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជាបន្ទាន់ ។

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជូនសាមីគណបក្សនយោបាយ ។

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយនោះពុំបានបំពេញលក្ខខណ្ឌណាមួយ ដែលមានចែងក្នុងមាត្រា ២៣ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៧ និងមាត្រា ២៨ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយវិញ ដើម្បីបំពេញបន្ថែម ។

គណបក្សនយោបាយនេះត្រូវបំពេញលក្ខខណ្ឌដែលខ្វះខាតយ៉ាងយូរ ០៥(ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃដែលសាមីគណបក្សនយោបាយបានទទួលលិខិតជូនដំណឹង ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិគណបក្សនយោបាយត្រូវបំពេញលក្ខ-ខណ្ឌ ដែលខ្វះខាតឲ្យបានទាន់មុនពេលបញ្ឈប់បញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះ-ឆ្នោត ។

ផុតកំណត់នេះ បើគណបក្សនយោបាយពុំបានបំពេញលក្ខខណ្ឌទាំងនោះទេ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចាត់ទុកថា គណបក្សនយោបាយនោះបោះបង់ការចុះបញ្ជីគណបក្សនយោ-បាយឈរឈ្មោះបោះឆ្នោត ។

មាត្រា ៣២.-

ប្រសិនបើបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនណាមួយត្រូវបានបដិសេធតាមបទប្បញ្ញត្តិនៃមាត្រា ២៣ ឬមាត្រា ២៤ ឬមាត្រា ២៥ ឬមាត្រា ២៨ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

-បំពេញបែបបទនៃការបដិសេធបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធ ០១ (មួយ) ច្បាប់ទៅសាមីខ្លួន និងសាមីគណបក្សនយោបាយ ។

-ផ្តល់ព័ត៌មានដល់សាមីខ្លួន និងទៅសាមីគណបក្សនយោបាយថា អនុលោមតាមមាត្រា ៣៣ នៃច្បាប់នេះ សាមីខ្លួន ឬសាមីគណបក្សនយោបាយអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ សាមីខ្លួន ឬសាមីគណបក្សនយោបាយ អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញជាបន្ទាន់ ។

-ផ្ញើសេចក្តីចម្លងនៃសេចក្តីបដិសេធ ០១ (មួយ) ច្បាប់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ជាឯកសារ ។

មាត្រា ៣៣.-

បេក្ខភាពណាដែលត្រូវបានបដិសេធ ឬបញ្ជីរាយនាមបេក្ខជនរបស់គណបក្សនយោបាយណា ដែលត្រូវបានបដិសេធដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សាមីខ្លួន ឬសាមីគណបក្ស នយោបាយនោះ មានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ សាមីខ្លួន ឬសាមីគណបក្សនយោបាយ អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញជាបន្ទាន់ ។

ក្នុងករណីបានទទួលសម្រង់នៃសេចក្តីសម្រេចបដិសេធ និងទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាហើយ ប៉ុន្តែ សាមីគណបក្សនយោបាយឬតំណាងពុំបានដាក់ពាក្យប្តឹងតវ៉ាទៅតាមពេលវេលាកំណត់ ដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ ខាងលើនេះទេ ត្រូវចាត់ទុកថា គណបក្សនយោ-បាយនោះ មិនបានប្តឹងតវ៉ា ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និង សម្រេចលើបណ្តឹងតវ៉ានេះជាបន្ទាន់ ។

មាត្រា ៣៤.-

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមលើបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្តី សម្រេចយល់ព្រម និងជូនដំណឹងទៅសាមីគណបក្សនយោបាយ ឬតំណាង ហើយបង្គាប់ឲ្យគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះសាមីគណបក្សនយោបាយទៅក្នុងបញ្ជីគណបក្សនយោ-បាយឈរឈ្មោះបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រជាបន្ទាន់ ។

បន្ទាប់ពីទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជូនសាមីគណបក្ស នយោបាយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្ញើលិខិតនេះ ០១ (មួយ)ច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ៣៥.-

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចបដិសេធបណ្តឹងតវ៉ា សេចក្តីសម្រេចនេះ គឺជាសេចក្តីសម្រេចចុងក្រោយ បិទផ្លូវតវ៉ា ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្តល់សេចក្តីសម្រេចបដិសេធនេះ ០១ (មួយ) ច្បាប់ ទៅសាមីគណបក្សនយោបាយ ឬតំណាង និងផ្ញើសេចក្តីសម្រេចបដិសេធ ០១ (មួយ) ច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៣៦.-

សវនាការឬផ្នែកមួយនៃសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលវិនិច្ឆ័យទៅលើបណ្តឹងតវ៉ា ត្រូវធ្វើជាចំហ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបិទផ្សាយ ថ្ងៃ ខែ ឆ្នាំ ទីកន្លែង និងពេលវេលានៃការបើកសវនាការវិនិច្ឆ័យលើបណ្តឹងតវ៉ានេះ ។

មាត្រា ៣៧.-

បន្ទាប់ពីបានបញ្ឈប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬ/និងក្រោយពេលដែលបណ្តឹងតវ៉ាត្រូវបានដោះស្រាយជាស្ថាពរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមរាជធានី ខេត្តរបស់គណបក្សនយោបាយទាំងនោះ ទៅតាមការកំណត់ ដូចមានចែងក្នុងបទបញ្ជា និងនីតិវិធី ។

ជំពូកទី ៥
ការិយាល័យបោះឆ្នោត

មាត្រា ៣៨.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសម្រេចបង្កើតការិយាល័យបោះឆ្នោតមួយ ឬច្រើនសម្រាប់ឃុំ សង្កាត់នីមួយៗ ស្របតាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវទទួលខុសត្រូវតំបន់មួយដែលបានកំណត់ ។

ការិយាល័យបោះឆ្នោត និងតំបន់ដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវស្ថិតនៅក្នុងព្រំប្រទល់ឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៣៩.-

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោតយ៉ាងច្រើន ៧៥០ (ប្រាំពីរយហាសិប) នាក់ ។

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវប្រមូលផ្តុំដោយភូមិទាំងមូល និងត្រូវបង្កលក្ខណៈឲ្យសមាជិកទាំងអស់របស់គ្រួសារក្នុងភូមិបានទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

ក្នុងករណីដែលការិយាល័យបោះឆ្នោតណាមួយមានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០ (ប្រាំពីរយហាសិប) នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះ ទៅក្នុងការិយាល័យបោះឆ្នោតដែលនៅជិតបំផុតក្នុងឃុំ សង្កាត់ជាមួយ ឬអាចបង្កើតការិយាល័យបោះឆ្នោតថ្មី តាមការចាំបាច់ ។

មាត្រា ៤០.-

គ្រប់ការិយាល័យបោះឆ្នោត និងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត ត្រូវមានបរិវេណខាងក្នុងដែលដៅសម្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បរិវេណខាងក្នុងជាតំបន់ដែលនៅជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ខណ្ឌដោយរណ្តៅមណ្ឌលមួយ ដែលមានកាំប្រវែងយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ែត្រ ។

បរិវេណខាងក្នុងត្រូវរៀបចំឲ្យមានច្រកចូលមួយ និងច្រកចេញមួយ ។

មាត្រា ៤១.-

គ្រប់ការិយាល័យបោះឆ្នោត និងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត ត្រូវមានបរិវេណខាងក្រៅដែលដៅសម្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បរិវេណខាងក្រៅជាតំបន់ដែលនៅជុំវិញការិយាល័យទាំងនោះ ខណ្ឌដោយរណ្តៅមណ្ឌលមួយដែលមានកាំប្រវែង ១០០ (មួយរយ) ម៉ែត្រ ឬមានទម្រង់ផ្សេង ឬមានកាំតូចជាង ស្របទៅតាមស្ថានភាពជាក់ស្តែងនៃបរិវេណខាងក្រៅរបស់ការិយាល័យនីមួយៗនោះ ។

មាត្រា ៤២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិជ្រើសយកបរិវេណ ឬអគារតែមួយធ្វើជាការិយាល័យបោះឆ្នោត សម្រាប់ការិយាល័យបោះឆ្នោតពីរ ឬច្រើន ប្រសិនបើមិនធ្វើឲ្យប៉ះពាល់ដល់ប្រក្រតីភាពនៃការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ។

ការិយាល័យបោះឆ្នោតជាច្រើនដែលតាំងនៅបរិវេណ ឬអគារតែមួយនោះ ត្រូវរៀបចំឲ្យស្ថិតនៅដាច់ដោយឡែកពីគ្នា ។

ការិយាល័យបោះឆ្នោតនីមួយៗដែលតាំងនៅបរិវេណ ឬអគារតែមួយនោះ ត្រូវគ្រប់គ្រងឲ្យដាច់ចេញពីគ្នា និងឧុសពីការិយាល័យបោះឆ្នោតផ្សេងទៀត ទៅតាមបទបញ្ជា និងនីតិវិធីដែលបានកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៤៣.-

ឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតដែលបានកំណត់ហើយ ត្រូវបិទផ្សាយជាសាធារណៈ ។

គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតអាចសុំតារាងឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតនេះបាន ដោយបង់ថ្លៃ ។

តម្លៃនេះ ត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបញ្ជូនតារាងឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតនៃមណ្ឌលនីមួយៗ ០១ (មួយ) ច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

ជំពូកទី ៦
ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត

មាត្រា ៤៤.-

ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត ត្រូវធានាសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឲ្យមានបញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដែលបង្កើតឡើងតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៣៨ និងមាត្រា ៣៩ នៃច្បាប់នេះ ។

បញ្ជីបោះឆ្នោតត្រូវកត់ត្រាទិន្នន័យអ្នកបោះឆ្នោតម្នាក់ៗ ដូចខាងក្រោម ៖

-នាមត្រកូល នាមខ្លួន

-ភេទ

-ថ្ងៃខែឆ្នាំកំណើត

-លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត និង

-ការដៅសម្គាល់អត្តសញ្ញាណដែលមានតែមួយគត់សម្រាប់អ្នកបោះឆ្នោតម្នាក់ៗ ដូចជា រូបថត និងស្នាមម្រាមដៃ ឬ/និងការដៅសម្គាល់ផ្សេងទៀត តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

នាមត្រកូល នាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើតរបស់អ្នកបោះឆ្នោតម្នាក់ៗ ត្រូវស្រង់ចេញពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកបោះឆ្នោតនោះ ។

បញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវកត់ចូលក្នុងសៀវភៅបញ្ជីមួយ ឬប្រព័ន្ធទិន្នន័យ ហើយរក្សាទុកជាអចិន្ត្រៃយ៍នៅសាលាឃុំ សង្កាត់ នៅលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត និងនៅទីស្នាក់ការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្របតាមបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីឈ្មោះបោះឆ្នោតផ្លូវការ ៩០ (កៅសិប) ថ្ងៃយ៉ាងតិច មុនថ្ងៃបោះឆ្នោត ។

ក្នុងករណីដែលវដ្តសភាត្រូវបានរំលាយមុនអាណត្តិ បញ្ជីបោះឆ្នោតត្រូវយកបញ្ជីបោះឆ្នោតដែលមានសុពលភាពចុងក្រោយទុកជាផ្លូវការ ហើយត្រូវផ្សព្វផ្សាយបញ្ជីនេះយ៉ាងតិច ៥០ (ហាសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

មាត្រា ៤៥.-

សៀវភៅបញ្ជី ឬទិន្នន័យបញ្ជីបោះឆ្នោត ត្រូវរក្សាទុកជាអចិន្ត្រៃយ៍នៅសាលាឃុំ សង្កាត់ នៅលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត និងនៅទីស្នាក់ការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្របតាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ។

រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ត្រូវធ្វើចាប់ពីថ្ងៃទី ០១ ខែ ឧសភា រហូតដល់ថ្ងៃទី ៣១ ខែ កក្កដា ជារៀងរាល់ឆ្នាំ ។

នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចសម្រេចកាលបរិច្ឆេទ និងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត និងផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតផ្សេងពីនេះ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចបន្ថែមរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតយ៉ាងយូរ ៥០ (ហាសិប) ថ្ងៃ ។

ក្នុងករណីដែលវដ្តសភាត្រូវបានរំលាយក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឬប្រធានសភ្ជា ឬអសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចសម្រេចរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតផ្សេងពីនេះ ។

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់ ដែលត្រូវបង្កើតថ្មី ដែលត្រូវកែសម្រួលព្រំប្រទល់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ និងលក្ខខណ្ឌដែលចែងក្នុងច្បាប់នេះ និងបទបញ្ជា និងនីតិវិធី ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៤៦.-

ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរ

-មានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត

-មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវបោះឆ្នោត

-មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត

-ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទុទៅដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញបទបញ្ជា និងនីតិវិធីដើម្បីអនុវត្តដាក់ស្តែងនូវមាត្រានេះ ។

មាត្រា ៤៧.-

បេក្ខជនដែលឈរឈ្មោះបោះឆ្នោត សហព័ទ្ធ និងកូនអាចទៅបោះឆ្នោតនៅមណ្ឌលបោះឆ្នោតដែលខ្លួនឈរឈ្មោះបោះឆ្នោតបាន ។

បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជនរបស់គណបក្សនយោបាយដែលបានអនុម័តយល់ព្រមឲ្យចុះបញ្ជីឈរឈ្មោះដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួន ដែលបានចុះឈ្មោះបោះឆ្នោតនៅមណ្ឌលបោះឆ្នោតផ្សេងពីមណ្ឌលដែលខ្លួនឈរឈ្មោះ បេក្ខជននោះ អាចធ្វើសេចក្តីស្នើសុំមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឲ្យចុះឈ្មោះរបស់ខ្លួន ព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួន ក្នុងករណីមានការយល់ព្រមពីសហព័ទ្ធ និងកូនរបស់ខ្លួននៅការិយាល័យបោះឆ្នោតណាមួយក្នុងមណ្ឌលដែលខ្លួនឈរឈ្មោះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ឲ្យលុបឈ្មោះរបស់បេក្ខជនសហព័ទ្ធ និងកូនរបស់បេក្ខជននោះចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ដែលបានចុះឈ្មោះកន្លងមក រួចហើយចាត់ឲ្យចុះឈ្មោះបេក្ខជន សហព័ទ្ធ និងកូនរបស់បេក្ខជននោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងមណ្ឌល ដែលបេក្ខជននោះឈរឈ្មោះតាមការស្នើសុំ ។

មាត្រា ៤៨.-

ប្រជាពលរដ្ឋម្នាក់ៗ ត្រូវមានឈ្មោះតែមួយក្នុងបញ្ជីឈ្មោះបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់ ។

ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋាន ឬ/និងទីសំណាក់ច្រើនជាងមួយកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើសយកកន្លែងតែមួយគត់ ដែលជាទីតាំងនៃជីវភាពរស់នៅជាក់ស្តែងរបស់បុគ្គលនោះ ដើម្បីចុះឈ្មោះបោះឆ្នោត ។

លំនៅឋាន គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ។

ក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថា ជាលំនៅឋាន ។ ទីសំណាក់សំដៅលើទីស្ថានដែលបុគ្គលម្នាក់ស្នាក់អាស្រ័យនៅ ឬអាស្រ័យនៅជាក់ស្តែង ក្នុងរយៈពេលជាកំណត់ណាមួយ ។

មាត្រា ៤៩.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញបទបញ្ជា និងនីតិវិធីដើម្បីប្រជាពលរដ្ឋដែលពុំមានលំនៅឋានច្បាស់លាស់ ឬចាកចេញពីលំនៅឋានទៅស្នាក់នៅកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា អាចចុះឈ្មោះបោះឆ្នោតនៅការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនមានទីសំណាក់នៅក្នុងឃុំ សង្កាត់នោះ ។

មាត្រា ៥០.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើប្រតិកូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឲ្យបំពេញតួនាទីជាតំណាងខ្លួន ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់តាំងក្រុមចុះឈ្មោះបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ ដើម្បីជួយគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការអនុវត្តនូវតួនាទី និងការទទួលខុសត្រូវខាងលើនេះ ។ ក្រុមចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ មានប្រធានមួយរូបដែលចាត់តាំងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អនុប្រធានមួយរូបជាស្មៀនឃុំ សង្កាត់សាមី និងសមាជិកមួយចំនួនតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំស្របតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដឹកនាំក្រុមចុះឈ្មោះបោះឆ្នោតឲ្យអនុវត្តឲ្យបានត្រឹមត្រូវនូវច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចាត់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ០១ (មួយ) ទៅ ០២ (ពីរ) រូប ចំពោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សា ០៥ (ប្រាំ) រូប និង ០២ (ពីរ) ទៅ ០៣ (បី) រូប ចំពោះឃុំ សង្កាត់

ណាដែលមានក្រុមប្រឹក្សាចាប់ពី ០៧ (ប្រាំពីរ) រូបឡើងទៅ ឲ្យប្រចាំការពិនិត្យមើលដំណើរប្រព្រឹត្ត ទៅនៃក្រុមចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្រចាំការនេះ មិនទទួលប្រាក់កម្រៃបន្ថែមឡើយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ អំពីការធ្វើប្រតិភូកម្មអំណាចស្របតាមសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវ ធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាព និងផ្តត់ផ្តង់មធ្យោបាយ សម្ភារ ថវិកាសមស្របដល់ក្រុម ប្រឹក្សាឃុំ សង្កាត់ និងក្រុមចុះឈ្មោះបោះឆ្នោត ដើម្បីអនុវត្តការទទួលខុសត្រូវនេះ ។

មាត្រា ៥១.-

ក.ដើម្បីចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋត្រូវទៅបង្ហាញខ្លួននៅសាលាឃុំ សង្កាត់របស់ខ្លួន ឬទីកន្លែងណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅតាមការកំណត់របស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ។

ពេលបង្ហាញខ្លួន ប្រជាពលរដ្ឋត្រូវ ៖

-បង្ហាញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សម្រាប់សម្គាល់អត្តសញ្ញាណរបស់ខ្លួនដល់ក្រុមចុះ ឈ្មោះបោះឆ្នោត

-មានសិទ្ធិបោះឆ្នោត ស្របតាមមាត្រា ៤៦ នៃច្បាប់នេះ

-មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬ មិនទាន់បានចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់ ។

បន្ទាប់ពីបញ្ជីបោះឆ្នោតត្រូវបានផ្តល់សុពលភាពរួចហើយ ក្នុងករណីដែលមានប្រជាពលរដ្ឋ ដែលទទួលមរណភាព ដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ដែលត្រូវបានលុប ឈ្មោះពីបញ្ជីបោះឆ្នោតដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ហើយមាន ឯកសារជាសំអាងត្រឹមត្រូវ និងច្បាស់លាស់ ស្មៀនឃុំ សង្កាត់ ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋទាំងនោះ ដាក់ក្នុងបញ្ជីមួយដោយឡែក តាមទម្រង់ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ។ បញ្ជីនេះត្រូវចែកជូនលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀប ចំការបោះឆ្នោត រៀងរាល់ ០២ (ពីរ) ខែម្តង ។ ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៤៥ នៃច្បាប់នេះ លេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការ បោះឆ្នោត ត្រូវសហការជាមួយក្រុមចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗដើម្បីលុបឈ្មោះប្រជា-ពលរដ្ឋទាំងនោះចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។

បន្ទាប់ពីបញ្ជីបោះឆ្នោតត្រូវបានផ្តល់សុពលភាពរួចហើយ ក្នុងករណីមានប្រជាពលរដ្ឋដែលមិនបានចុះឈ្មោះពីមុនមក ដែលទើបដល់អាយុត្រូវបោះឆ្នោត ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ស្មៀនឃុំ សង្កាត់ ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋទាំងនោះដាក់ក្នុងបញ្ជីមួយដោយឡែក តាមទម្រង់ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ បញ្ជីនេះ ត្រូវចម្លងជូនលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតរៀងរាល់ ០២ (ពីរ) ខែម្តង ។ ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រជាពលរដ្ឋទាំងនោះ ត្រូវបំពេញលក្ខខណ្ឌសម្រាប់ការចុះឈ្មោះ ដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃចំណុច ក នៃមាត្រានេះ ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិភាក្សាជាមួយលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដើម្បីចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោតធ្វើការចុះឈ្មោះចល័តស្របតាមបទបញ្ជា និងនីតិវិធី ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ខ.ដើម្បីបញ្ជាក់អត្តសញ្ញាណ អាយុ សញ្ជាតិខ្មែរ និងលំនៅឋាន ឬទីសំណាក់ប្រជាពលរដ្ឋ ត្រូវបង្ហាញដោយផ្ទាល់នូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរបស់ខ្លួនចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត ។

ចំពោះប្រជាពលរដ្ឋដែលមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរបស់ខ្លួនបានខូច ឬបាត់ ប្រជាពលរដ្ឋនោះត្រូវរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបំពេញបែបបទផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូន ។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចមិនអាចផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិ ខ្មែរជូនបានទាន់ពេលវេលា ប្រជាពលរដ្ឋនោះត្រូវមកបង្ហាញខ្លួនដោយផ្ទាល់ចំពោះមុខអាជ្ញាធរឃុំ សង្កាត់ដែលសាមីខ្លួនកំពុងស្នាក់នៅ ដោយនាំមកនូវសាក្សី ០២ (ពីរ) រូប ដែលមានសិទ្ធិបោះឆ្នោត និងមានលំនៅឋាន ឬទីសំណាក់ពិតប្រាកដក្នុងឃុំ សង្កាត់ជាមួយ ដើម្បីអាជ្ញាធរឃុំ សង្កាត់បំពេញបែបបទផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូន ។

ឯកសារបញ្ជាក់អត្តសញ្ញាណខាងលើនេះ ត្រូវបិទរូបថតសាមីខ្លួន និងត្រូវបញ្ជាក់អំពីនាមត្រកូល នាមខ្លួន ភេទ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ និងលំនៅឋាន ឬទីសំណាក់របស់សាមីខ្លួន និងសាក្សីទាំង ០២ (ពីរ) រូប ព្រមទាំងស្នាមមេដៃស្តាំរបស់សាមីខ្លួន និងស្នាមមេដៃស្តាំរបស់សាក្សីទាំង ០២ (ពីរ) រូប ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញសេចក្តីណែនាំរួមអំពីបែបបទ នីតិវិធីនៃការផ្តល់ឯកសារ បញ្ជាក់អត្តសញ្ញាណដូចបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃចំណុច ខ នៃមាត្រានេះ ។

គ.ប្រជាពលរដ្ឋដែលមានលំនៅឋាន ឬទីសំណាក់ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលបានចុះក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរបស់ខ្លួន ប្រជាពលរដ្ឋនោះ ត្រូវនាំមកបង្ហាញដោយផ្ទាល់ ចំពោះ

ក្រុមចុះឈ្មោះបោះឆ្នោតនូវសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារច្បាប់ដើម ដែលមានចុះនាមត្រកូល នាមខ្លួន កេទ សញ្ជាតិ និងថ្ងៃ ខែ ឆ្នាំកំណើតរបស់ប្រជាពលរដ្ឋនោះ ក្នុងសៀវភៅនោះ ។

ក្នុងករណីដែលប្រជាពលរដ្ឋមិនទាន់មានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារប្រជាពលរដ្ឋនោះ អាចស្នើសុំលិខិតបញ្ជាក់ទីលំនៅពីអាជ្ញាធរឃុំសង្កាត់ ដែលសាមីខ្លួនមានលំនៅហាន ឬទីសំណាក់ ។ អាជ្ញាធរឃុំ សង្កាត់ ត្រូវចេញលិខិតបញ្ជាក់ទីលំនៅនេះជូនប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលានៃការចុះឈ្មោះបោះឆ្នោត ស្របតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តកំណត់ ។

ឃ.ក្នុងករណីដែលប្រជាពលរដ្ឋមានឯកសារគ្រប់គ្រាន់ត្រឹមត្រូវ ដូចមានចែងក្នុងចំណុច ខ និងចំណុច គ នៃមាត្រា ៥១ នៃច្បាប់នេះ ក្រុមចុះឈ្មោះបោះឆ្នោតត្រូវ ៖

-ចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីឈ្មោះបោះឆ្នោត

-កត់ឈ្មោះប្រជាពលរដ្ឋនោះ ចូលក្នុងសៀវភៅបញ្ជីបោះឆ្នោត

-ចេញបង្កាន់ដៃបញ្ជាក់អំពីការចុះឈ្មោះជូនសាមីខ្លួន

-បញ្ជាក់ប្រាប់ប្រជាពលរដ្ឋ អំពីការិយាល័យបោះឆ្នោតដែលប្រជាពលរដ្ឋនោះ ត្រូវទៅបោះឆ្នោត ។

ចំពោះប្រជាពលរដ្ឋណាដែលមានឈ្មោះក្នុងសៀវភៅបញ្ជីបោះឆ្នោតរួចហើយ ក្រុមចុះឈ្មោះបោះឆ្នោត គ្រាន់តែពិនិត្យកស្តុតាងនៃការចុះឈ្មោះរបស់ជននោះ ប្រសិនបើជននោះមិនស្ថិតក្នុងករណីណាមួយដូចបានចែងក្នុងកថាខណ្ឌទី ៣ នៃចំណុច ក នៃមាត្រា ៥១ នៃច្បាប់នេះ ក្រុមចុះឈ្មោះបោះឆ្នោត ត្រូវធ្វើបច្ចុប្បន្នភាពឈ្មោះរបស់ជននោះ ចូលក្នុងបញ្ជីបោះឆ្នោត ។

មាត្រា ៥២.-

ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ហាមឃាត់មិនឲ្យយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ព្រមទាំងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលក្នុងសាលាឃុំ សង្កាត់ ឬទីកន្លែងកំណត់ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ។

ក្នុងករណី មានជនណាបង្កការអុកឡុកវឹខាន ក្រុមចុះឈ្មោះបោះឆ្នោត ត្រូវស្នើសុំអន្តរាគមន៍ជាបន្ទាន់ពីអាជ្ញាធរមានសមត្ថកិច្ច ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជានាឲ្យដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និងគ្មានការភ័យខ្លាច ឬការបំភិតបំភ័យនានា ។

មាត្រា ៥៣.-

ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក្នុងករណីមានកស្តុតាងបញ្ជាក់ថាជនណាដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមមាត្រា ៨៦ និងចំណុច ក ចំណុច ខ និងចំណុច គ

នៃមាត្រា ៥១ នៃច្បាប់នេះ ក្រុមចុះឈ្មោះបោះឆ្នោតត្រូវបដិសេធការចុះឈ្មោះបោះឆ្នោតរបស់ជននោះ ដោយត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធ ០១ (មួយ) ច្បាប់ ជូនសាមីខ្លួន ។

-ផ្តល់ព័ត៌មានជូនសាមីខ្លួនថា អនុលោមតាមមាត្រា៥៤នៃច្បាប់នេះ សាមីខ្លួន ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

-ធ្វើសំណុំឯកសារបដិសេធ ០១ (មួយ) ច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមរយៈលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

មាត្រា ៥៤.-

ជនណាដែលការសុំចុះឈ្មោះរបស់ខ្លួនត្រូវបានបដិសេធដោយក្រុមចុះឈ្មោះបោះឆ្នោត ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

មាត្រា ៥៥.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈលើបណ្តឹងតវ៉ានេះ ដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

មាត្រា ៥៦.-

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់យល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោត អនុវត្តការចុះឈ្មោះតាមលក្ខខណ្ឌ ដូចមានចែងក្នុងចំណុច ឃ នៃមាត្រា ៥១ នៃច្បាប់នេះ ។

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ ពុំយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធ ០១ (មួយ) ច្បាប់ជូនសាមីខ្លួន ។

-ផ្តល់ព័ត៌មានជូនសាមីខ្លួនថា អនុលោមតាមមាត្រា ៥៧ នៃច្បាប់នេះ សាមីខ្លួន ឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

-ផ្ញើសំណុំឯកសារបដិសេធ ០១ (មួយ) ច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមរយៈលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

មាត្រា ៥៧.-

ជនណាដែលបណ្តឹងតវ៉ារបស់ខ្លួនត្រូវបានបដិសេធដោយក្រុមប្រឹក្សាឃុំ សង្កាត់ ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

មាត្រា ៥៨.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសម្រេចលើបណ្តឹងតវ៉ានេះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបញ្ជាឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោតធ្វើការចុះឈ្មោះអ្នកដែលត្រូវបានបដិសេធដោយអនុវត្តលក្ខខណ្ឌចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងចំណុច ឃ នៃមាត្រា ៥១ នៃច្បាប់នេះ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពុំយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

-ចេញសេចក្តីសម្រេចបដិសេធដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងសេចក្តីសម្រេចបដិសេធនេះ ០១ (មួយ) ច្បាប់ ទៅអ្នកប្តឹងតវ៉ា ។

-ផ្តល់ព័ត៌មានទៅសាមីខ្លួនថា អនុលោមតាមមាត្រា ៥៩ នៃច្បាប់នេះ សាមីខ្លួន ឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីចម្លង សេចក្តីសម្រេចបដិសេធ ។

-ផ្ញើសេចក្តីចម្លងសេចក្តីសម្រេចបដិសេធនេះ ០១ (មួយ) ច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

មាត្រា ៥៩.-

ជនណាដែលការសុំចុះឈ្មោះរបស់ខ្លួន ត្រូវបានបដិសេធដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីចម្លងសេចក្តីសម្រេចបដិសេធ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្តឹងតវ៉ានេះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបានពាក្យបណ្តឹង ។

ក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រម ឬមិនយល់ព្រមតាមបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

-ចេញសេចក្តីសម្រេចឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះ ឬបដិសេធឈ្មោះអ្នកដែលមានបញ្ហា ។

-ផ្ញើសេចក្តីចម្លងសេចក្តីសម្រេចយល់ព្រម ឬបដិសេធនេះ ០១ (មួយ) ច្បាប់ទៅអ្នកប្តឹងតវ៉ា ឬតំណាង ។

ប្រសិនបើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ តម្រូវឲ្យចុះឈ្មោះអ្នកដែលមានបញ្ហា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបញ្ជាឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោតធ្វើការចុះឈ្មោះអ្នកដែលមានបញ្ហានោះ តាមលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងចំណុច ឃ នៃមាត្រា ៥១ នៃច្បាប់នេះ ហើយផ្ញើបញ្ជីបោះឆ្នោតកែប្រែថ្មីនោះ ០១ (មួយ) ច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ៦០.-

បន្ទាប់ពីថ្ងៃបញ្ឈប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ហើយការប្តឹងតវ៉ាទៅនឹងការចុះឈ្មោះត្រូវបានដោះស្រាយរួចរាល់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបញ្ចូលឈ្មោះ និងទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោតថ្មីទៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យបញ្ជីឈ្មោះអ្នកបោះឆ្នោតតាមឃុំ សង្កាត់ ឬរាជធានី ខេត្ត ឬមជ្ឈមណ្ឌលផ្ទុកទិន្នន័យបញ្ជីបោះឆ្នោតទូទាំងប្រទេសរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរកឃើញជនណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះជននោះ ពីបញ្ជីបោះឆ្នោតច្រើនកន្លែងនោះ ដោយរក្សាទុកឈ្មោះជននោះតែមួយគត់នៅឃុំ សង្កាត់ចុងក្រោយដែលសាមីខ្លួនបានចុះឈ្មោះបោះឆ្នោត ។

បន្ទាប់ពីបានពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះបោះឆ្នោតក្នុងប្រព័ន្ធផ្ទុកទិន្នន័យរួច គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ឲ្យបិទផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតដំបូង រួមនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតដោយមូលហេតុ ដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃចំណុច ក នៃមាត្រា ៥១ នៃច្បាប់នេះ និងបញ្ជីឈ្មោះអ្នកដែលមានឈ្មោះច្រើនជាងមួយកន្លែង ហើយដែលនឹងត្រូវលុបចេញតាមឃុំ សង្កាត់នីមួយៗ នៅសាលាឃុំ សង្កាត់ និងទីតាំងណាមួយក្នុងឃុំ សង្កាត់ តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិសុំបញ្ជីបោះឆ្នោតថតចម្លងនេះបាន ដោយបង់ថ្លៃ ។ តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

មាត្រា ៦១.-

ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ជនណាក៏ដោយ ក៏អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខ្លួនពីការបោត់បង់ឈ្មោះ ឬដំទាស់ការចុះឈ្មោះ ឬការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃជនណាម្នាក់ដែលខ្លួនមានកស្តុតាងបញ្ជាក់ថា ៖

-ជននោះពុំមានលក្ខខណ្ឌត្រឹមត្រូវគ្រប់គ្រាន់តាមមាត្រា ៤៦ និងមាត្រា ៥១ នៃច្បាប់នេះ ។

-ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង ។

-ជននោះបានមកចុះឈ្មោះ មានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែជននោះគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

-ជននោះត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលុបឈ្មោះមិនត្រឹមត្រូវ ។

-ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោត តែកត់ត្រាមិនច្បាស់លាស់ ។

អ្នកប្តឹងតវ៉ាត្រូវបង្ហាញកស្តុតាងជាឯកសារណាមួយទៅក្រុមប្រឹក្សាឃុំ សង្កាត់ ។

អ្នកប្តឹងជំទាស់ត្រូវផ្តល់ព័ត៌មានបន្ថែម ក្នុងករណីមានការស្នើសុំពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល ការប្តឹង ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ មានរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

មាត្រា ៦២.-

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រជុំសម្រេចជាសាធារណៈលើបណ្តឹងតវ៉ា ឬជំទាស់ក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ា ឬជំទាស់នេះជាការត្រឹមត្រូវ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោត ធ្វើការចុះឈ្មោះ ឬកែតម្រូវទិន្នន័យអ្នកដែលមានបញ្ហានោះក្នុងបញ្ជីបោះឆ្នោត ឬលុបឈ្មោះអ្នកដែលមានបញ្ហានោះចេញពីបញ្ជីបោះឆ្នោត ។

ប្រសិនបើអ្នកតវ៉ា ឬអ្នកជំទាស់ ឬអ្នកដែលមានបញ្ហាពុំពេញចិត្តនឹងការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេល ០៥ (ប្រាំ)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសម្រេចលើបណ្តឹងតវ៉ា ឬជំទាស់នោះ ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ា ឬជំទាស់នោះជាការត្រឹមត្រូវ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបញ្ជាឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោត ធ្វើការចុះឈ្មោះអ្នកដែលមានបញ្ហានោះ ក្នុងបញ្ជីបោះឆ្នោតតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ឃ នៃមាត្រា៥១នៃច្បាប់នេះ ឬលុបឈ្មោះអ្នកដែលមានបញ្ហានោះចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ឬប្រព័ន្ធផ្ទុកទិន្នន័យបញ្ជីបោះឆ្នោត ។

ប្រសិនបើអ្នកតវ៉ា ឬអ្នកជំទាស់ពុំពេញចិត្តនឹងការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីចម្លងសេចក្តីសម្រេចបដិសេធពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៦៣.-

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្តឹងតវ៉ា ឬជំទាស់នោះ ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបានពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ា ឬជំទាស់នោះជាការត្រឹមត្រូវ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

-ចេញសេចក្តីសម្រេចឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះ ឬបដិសេធឈ្មោះអ្នកប្តឹងតវ៉ា ឬអ្នកជំទាស់ ឬអ្នកដែលមានបញ្ហា ។

-ធ្វើសេចក្តីចម្លងនៃសេចក្តីឃ្លាំព្រមឬបដិសេធនេះ ០១ (មួយ) ច្បាប់ ទៅអ្នកប្តឹងតវ៉ា ឬអ្នកជំទាស់ ឬអ្នកដែលមានបញ្ហា ។

ប្រសិនបើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញតម្រូវឲ្យចុះឈ្មោះអ្នកប្តឹងតវ៉ា ឬអ្នកដែលមានបញ្ហា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបញ្ជាឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ចាត់ឲ្យក្រុម

ចុះឈ្មោះបោះឆ្នោតធ្វើការចុះឈ្មោះជំនួស តាមលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងចំណុច ឃ នៃមាត្រា ៥១ នៃច្បាប់នេះ ហើយផ្ញើបញ្ជីបោះឆ្នោតកែប្រែថ្មីនោះ ០១ (មួយ) ច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ៦៤.-

នៅពេលដែលបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានសម្រេចជាស្ថាពរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់បញ្ជូនបញ្ជីបោះឆ្នោតផ្លូវការក្នុងឆ្នាំនីមួយៗទៅលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ០១ (មួយ) ច្បាប់ និងសាលាឃុំ សង្កាត់ ០១ (មួយ) ច្បាប់ ដើម្បីរក្សាទុកជាឯកសារផ្លូវការ ។

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិស្នើសុំពិនិត្យមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីឈ្មោះបោះឆ្នោតនេះបាន ។

គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិសុំបញ្ជីបោះឆ្នោតថតចម្លងនេះបានដោយបង់ថ្លៃ ។ តម្លៃនេះ ត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

មាត្រា ៦៥.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ឲ្យចិទផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតផ្លូវការនៅការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ នៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត និងទីស្នាក់ការគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត តាមកាលបរិច្ឆេទដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៦៦.-

គណបក្សនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ និងបរទេសអង្គការអន្តរជាតិ និងប្រទេសនានាអាចបញ្ជូនភ្នាក់ងារ ឬតំណាងរបស់ខ្លួនចូលសង្កេតការណ៍ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតជារៀងរាល់ឆ្នាំ ។

ភ្នាក់ងារ ឬតំណាងទាំងអស់ត្រូវមានការទទួលស្គាល់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ជំពូកទី ៧
ការឃោសនាបោះឆ្នោត

មាត្រា ៦៧.-

ការឃោសនាបោះឆ្នោតមានទិសដៅឲ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត ។

មាត្រា ៦៨.-

ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឲ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយ ណាមួយ មានដូចជា ៖

-ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ។

-ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានដំនិះគ្រប់ប្រភេទ នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ យ៉ាងច្រើន ០៤ (បួន) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

-ការជួបជុំ ឬការឃោសនាតាមផ្ទះ ។

-ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ។

-ការផ្សព្វផ្សាយតាមរលកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាស្សែតវីដេអូ ឬស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ ។

-សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនានានា។

-សកម្មភាពចែកចាយខិតប័ណ្ណគណបក្សនយោបាយ ។

-សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារផ្សេងៗទៀត ដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬបេក្ខជន ជូនអ្នកបោះឆ្នោត ។

-សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទក្រដាសផ្សាយ ។

-ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត ។

-ការរៀបចំកម្មវិធីប្រកួតកីឡា ។

មាត្រា ៦៩.-

ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង សោភ័ណ-ភាពសាធារណៈ ។

ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារយោសនារបស់គណបក្សនយោបាយ មិនត្រូវបានអនុញ្ញាតឲ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ ។

ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាយោសនា រូបសញ្ញាយោសនា ពាក្យស្លោក ខិតប័ណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន ។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទ ស្លាកសញ្ញា បដាយោសនា រូបសញ្ញាយោសនា ពាក្យស្លោក ខិតប័ណ្ណរបស់គណបក្សណាមួយបាន ។

ស្លាកសញ្ញាគណបក្សនយោបាយ ឬសម្ភារយោសនារបស់គណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការយោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ ។

គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារយោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈក្នុង រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

មាត្រា ៧០.-

ការស្លៀកសម្លៀកបំពាក់ ឬ/និងពាក់មួក ដែលតាំងបង្ហាញឲ្យឃើញនូវរូបសញ្ញា ឬសារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់ មិនរាប់បញ្ចូលទៅក្នុងសកម្មភាពយោសនាបោះឆ្នោតឡើយ លើកលែងតែការស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត ។

មាត្រា ៧១.-

គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។

គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឲ្យប្រព្រឹត្តអំពើរំលោភ គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជនអ្នកគាំទ្រ ឬលើបុគ្គលណាមួយឡើយ ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រទាំងអស់មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឲ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយឡើយ ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជាង្វាន់លើកទឹកចិត្ត ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៍ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ។

មាត្រា ៧២.-

យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃ ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត ។

រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត ត្រូវបញ្ឈប់ ០៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ ការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត គឺជាការប្រើសំណាកដែលបានជ្រើសរើស ឬ/និងបញ្ជីសំណួរ ដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីការបោះឆ្នោត ។ រាល់ការរៀបចំការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត ត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម ៖

-ដំណើរការប្រកបដោយតម្លាភាព និងភាពមិនលម្អៀង

-រៀបចំឡើងដោយអង្គការ ឬស្ថាប័នដែលមានវិជ្ជាជីវៈ

-ការគោរពសិទ្ធិ សេរីភាពរបស់បុគ្គល

-ក្បាការសម្ងាត់នៃការបោះឆ្នោតរបស់អ្នកបោះឆ្នោត

-ការមិនបង្កឲ្យមានអសន្តិសុខ ភាពចលាចល ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬការធ្វើឲ្យកាន់ច្រឡំក្នុងដំណើរការបោះឆ្នោត

-លទ្ធផលដែលបានមកពីការស្ទង់មតិ ត្រូវផ្តល់ជូនគណបក្សនយោបាយ និងផ្សព្វផ្សាយជូនសាធារណជនដោយស្មើភាព ។

មាត្រា ៧៣.-

គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើម ពីម៉ោង ០៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១០ (ដប់) យប់ ។

គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវឈប់សម្រាកនៅចន្លោះពីម៉ោង ១០ (ដប់) យប់ ដល់ម៉ោង ០៦ (ប្រាំមួយ) ព្រឹក ។

សកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ត្រូវហាមឃាត់ចាប់ពីម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ០២ (ពីរ) រសៀល ។

សកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ត្រូវហាមឃាត់នៅក្បែរ មន្ទីរពេទ្យ ឬក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានា ក្នុងពេលម៉ោងសិស្សកំពុងសិក្សា ។

មាត្រា ៧៤.-

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ ដែលចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងក្រមសីលធម៌ បទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

រាល់ បែបបទប្តឹងជំទាស់ ឬតវ៉ាក្នុងពេលឃោសនាបោះឆ្នោត និងការដោះស្រាយពាក្យបណ្តឹង ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចសេចក្តីចុងក្រោយ ។

មាត្រា ៧៥.-

គ្រប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រួមមានសារព័ត៌មាន វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវចុះផ្សាយគ្រប់ព័ត៌មានដែលស្នើដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយមិនយកថ្លៃ ដើម្បីផ្សព្វ-ផ្សាយពីការងារបោះឆ្នោត និងអប់រំដល់អ្នកបោះឆ្នោត ។

មាត្រា ៧៦.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់វិធានការ ដើម្បីផ្សព្វផ្សាយអត្ថបទឃោសនាតាមសំណើរបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត ផ្អែកតាមគោលការណ៍ស្មើភាព និងតាមលំដាប់ពេលមុនក្រោយ ។

មាត្រា ៧៧.-

ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយ គណបក្សនយោបាយ និងបេក្ខជនទាំងអស់មិនត្រូវប្រើអំពើហិង្សា អំពើរំលោភ សំដីប្រមាថមើលងាយ មិនត្រូវសាបព្រោះឲ្យមានការភ័យខ្លាច ការគាន់ច្រឡំ ធ្វើឲ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

មាត្រា ៧៨.-

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត ដែល

សុំដួលប្រើប្រាស់សម្រាប់បម្រើការឃោសនាដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់ពេលមុនក្រោយ ។

មាត្រា ៧៩.-

ក្នុងសម័យឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណបក្សនយោបាយ ឬបេក្ខជនដែលមានបំណងជួលពេងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈ ដូចមានចែងក្នុងមាត្រា ៧៨ នៃច្បាប់នេះ ត្រូវធ្វើពាក្យសុំទៅអ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ០៣ (បី) ថ្ងៃយ៉ាងតិចមុនថ្ងៃប្រជុំឃោសនា ហើយត្រូវចម្លងពាក្យសុំនេះ ០១ (មួយ) ច្បាប់ ផ្ញើទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

អ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ត្រូវឆ្លើយតបនឹងពាក្យសុំជួលក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យសុំ ។

មាត្រា ៨០.-

ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយ ឬបេក្ខជន ណាម្នាក់ និងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

មាត្រា ៨១.-

គណបក្សនយោបាយ ឬបេក្ខជនអាចធ្វើសកម្មភាពឃោសនានៅលើទីធ្លាឯកជន ឬនៅសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ តែត្រូវជូនដំណឹងដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

មាត្រា ៨២.-

មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវ ៖

-ប្រើឥទ្ធិពល អំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះ ទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ

-ប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោតឲ្យគណបក្សនយោបាយ ឬបេក្ខជនណាមួយ

-ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយ ឬបេក្ខជនណាមួយឡើយ។

ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត ដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ ដែលកំពុងបំពេញការកិច្ច ត្រូវបានកំណត់ដូចតទៅ ៖

- ជាសមាជិកនៃគណៈកម្មការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។

- ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និង បេក្ខជនណាម្នាក់ ។

- ការចូលរួមក្នុងការស្នេហ៍មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

- ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

- ការធ្វើសកម្មភាពចែកចាយសម្ភារឃោសនាបោះឆ្នោត ដល់អ្នកបោះឆ្នោត ក្នុងគោលបំណងគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

- ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

- ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

មាត្រា ៨៣.-

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថកាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឲ្យមានការគំរាមកំហែងឡើយ ។

មាត្រា ៨៤.-

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការ អន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដូចខាងក្រោម ៖

-ផ្តួចផ្តើម ឬចូលរួមក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការផ្តួចផ្តើម ឬការចូលរួមឃោសនា រួមមាន ៖

- ការបញ្ចុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឲ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោត របស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។

-ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀង រួមមាន ៖

- ការស្នើមតិក្នុងគោលបំណងបម្រើឲ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការសរសេរដោលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរដោលាយលក្ខណ៍អក្សរ ក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

-ផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ដែលរួមមាន ៖

· ការផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

· ការផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋ សម្រាប់ចូលរួមក្នុងសកម្មភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

· ការផ្តល់ថវិកា សម្ភារ និងបរិក្ខារ សម្រាប់ជង្គៀក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

មាត្រា ៨៥.-

ហាមជនបរទេសដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងការឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

មាត្រា ៨៦.-

គណបក្សនយោបាយ និងបេក្ខជនទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឲ្យរាំងស្ទះដល់សកម្មភាពគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។

មាត្រា ៨៧.-

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសិរីយការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

មាត្រា ៨៨.-

ចំណាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយ និងរបស់បេក្ខជនម្នាក់ៗជាបន្ទុករបស់គណបក្សនយោបាយ ឬបេក្ខជនផ្ទាល់ ។



មាត្រា ៨៩.-

គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានសៀវភៅគណនី ដើម្បីកត់ត្រាចំណូល ប្រភពនៃប្រាក់ចំណូល និងចំណាយសម្រាប់ការឃោសនាបោះឆ្នោត ។

មាត្រា ៩០.-

វិភាគទានទាំងអស់ដែលគណបក្សនយោបាយបានទទួល ត្រូវបញ្ចូលក្នុងគណនីនៃធនាគារ ហើយរាល់ចំណាយទៅលើការឃោសនា ត្រូវតែចេញពីគណនីតែមួយនេះ: ។

មាត្រា ៩១.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចត្រួតពិនិត្យសៀវភៅគណនីរបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត តាមការចាំបាច់ ។

ជំពូកទី ៨
ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត
និងការប្រកាសរបលទ្ធផលនៃការបោះឆ្នោត

មាត្រា ៩២.-

ការិយាល័យបោះឆ្នោតត្រូវរៀបចំតាមការកំណត់ ដូចមានចែងក្នុងមាត្រា ៣៨ និងមាត្រា ៣៩ នៃច្បាប់នេះ: ។

មាត្រា ៩៣.-

ការបោះឆ្នោតត្រូវធ្វើតែ ០១ (មួយ) ថ្ងៃ ។

ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក រហូតដល់ម៉ោង ១៥:០០ (ដប់ប្រាំ) លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានបោះគ្រប់គ្នាហើយ គណៈកម្មការការិយាល័យបោះឆ្នោត អាចប្រកាសបញ្ចប់ការបោះឆ្នោត មុនម៉ោង ១៥:០០ (ដប់ប្រាំ) ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវប្រកាសបិទ ការបោះឆ្នោតនៅម៉ោង ១៥:០០ (ដប់ប្រាំ) ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោត មិនត្រូវអនុញ្ញាតឲ្យចូលបរិវេណខាងក្នុងក្រោយម៉ោង ១៥:០០ (ដប់ប្រាំ) ឡើយ ។

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោង ១៥:០០ (ដប់ប្រាំ) ហើយអាចអនុញ្ញាតឲ្យបោះ-ឆ្នោត គឺជាជនដែលស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៅម៉ោង ១៥:០០ (ដប់ប្រាំ) ។

មាត្រា ៩៤.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយបញ្ជីឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោត ហើយត្រូវបិទផ្សាយបញ្ជីទាំងនេះនៅគ្រប់ការិយាល័យបោះឆ្នោត ៣០ (សាមសិប) ថ្ងៃ យ៉ាងតិច មុនថ្ងៃបោះឆ្នោត ។

មាត្រា ៩៥.-

គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត អាចសុំសេចក្តីចម្លងនៃបញ្ជីឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតនេះ ដោយបង់ថ្លៃ ។ តម្លៃគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

មាត្រា ៩៦.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់ជូនការិយាល័យបោះឆ្នោតនីមួយៗនូវសម្ភារដូចតទៅ តាមចំនួនសមស្រប ០១ (មួយ) ថ្ងៃមុន ថ្ងៃបោះឆ្នោត ៖

១- បញ្ជីបោះឆ្នោត ។
២- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។
៣- ហិបឆ្នោត ។
៤- បន្ទប់សម្ងាត់ ។
៥- ត្រាសម្ងាត់សម្រាប់បោះលើសន្លឹកឆ្នោត ។
៦- ទឹកជ្រលក់សម្រាប់សម្គាល់ថាបានបោះឆ្នោតហើយ ។
៧- សោ និងប្រដាប់ឃ្លុំ ។
៨- ក្រដាសបៃបបទសម្រាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល ។
៩- ប៊ិចសរសេរដែលមានគុណភាពល្អ ។
១០- ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ ។
១១- ថង់ប្លាស្ទិក ។
១២- សម្ភារ និងបរិក្ខារចាំបាច់ផ្សេងៗទៀត ។

មាត្រា ៥៧.-

មុនថ្ងៃបោះឆ្នោត ០១ (មួយ) ថ្ងៃ ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវប្រជុំសមាជិកទាំងអស់ដើម្បីត្រួតពិនិត្យវត្តមានសមាជិក និងពិនិត្យទីតាំងការិយាល័យបោះឆ្នោត និងពិនិត្យសម្ភារបរិក្ខារបម្រើឲ្យការងារបោះឆ្នោត ។

ប្រសិនបើមានសមាជិកណាម្នាក់អវត្តមាន សមាជិកនោះត្រូវជំនួសដោយសមាជិកថ្មីដែលជ្រើសតាំងឡើង ស្របតាមបទប្បញ្ញត្តិដែលចែងក្នុងបទបញ្ជា និងនីតិវិធី ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ការ ដើម្បីឲ្យការិយាល័យបោះឆ្នោតមានសម្ភារ បរិក្ខារ និងសង្ហារិមចាំបាច់សម្រាប់ការបោះឆ្នោត ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ពិនិត្យស្ថានភាពសន្តិសុខនៅការិយាល័យបោះឆ្នោត ហើយចាត់វិធានការ ការពារសន្តិសុខ ប្រសិនបើចាំបាច់ ។

មាត្រា ៥៨.-

នៅថ្ងៃបោះឆ្នោត សមាជិកគណៈកម្មការការិយាល័យបោះឆ្នោតត្រូវមកដល់ទីតាំងការិយាល័យបោះឆ្នោត ដើម្បីរៀបចំការបោះឆ្នោតយ៉ាងយូរនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក ។

ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានអនុញ្ញាត ឲ្យចូលក្នុងការិយាល័យបោះឆ្នោតនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក ។

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍មុននឹងអនុញ្ញាតឲ្យអ្នកទាំងនេះចូលក្នុងការិយាល័យបោះឆ្នោត ។

មាត្រា ៥៩.-

នៅចន្លោះពីម៉ោង ៦:០០នាទីព្រឹក ដល់ម៉ោង ៦:៣០នាទីព្រឹក នៅថ្ងៃបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោត ត្រូវរៀបចំកិច្ចការ ដូចខាងក្រោម ៖

-ពិនិត្យឡើងវិញនូវហិបឆ្នោតដែលបានផ្តល់ឲ្យ និងពិនិត្យផ្លាកលេខ ឬសញ្ញាសម្គាល់ហិបឆ្នោតឲ្យបានត្រឹមត្រូវ

-បង្ហាញអ្នកនៅក្នុងការិយាល័យបោះឆ្នោតថា ហិបឆ្នោតនីមួយៗពុំមានអ្វីក្នុងនោះឡើយ

-បិទគម្របក្នុងនៃហិបឆ្នោត ហើយចាក់សោឃ្លុំ

-បិទផ្លាកលេខ ឬសញ្ញាសម្គាល់ជាប់នឹងហិបឆ្នោត ដោយមានបោះត្រារបស់ការិយាល័យបោះឆ្នោតពីលើ

-អនុញ្ញាតឲ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោត ផ្លាកលេខ ឬសញ្ញាសម្គាល់ផ្សេងៗដែលបិទលើហិបឆ្នោត

-តុ និងកៅអីសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នៅខាងឆ្វេងដៃតុរបស់ប្រធាន ឬ/និងនៅខាងក្រោយតុអនុប្រធាន និងលេខាធិការ ប្រសិនបើមាន ។

ក្នុងករណីសម្ភារៈឧបករណ៍បោះឆ្នោតត្រូវបានប្រគល់ឲ្យការិយាល័យបោះឆ្នោតក្រោយម៉ោង ៦:៣០ នាទីព្រឹក ពេលទទួល ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវអនុវត្តតាមនីតិវិធីខាងលើ ករណីនេះប្រធានគណៈកម្មការការិយាល័យបោះឆ្នោតអាចព្យួរការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះជាបណ្តោះអាសន្ន រហូតដល់ពេលដែលនីតិវិធីខាងលើបានបំពេញរួចរាល់ ។

បន្ទាប់ពីបានបិទផ្លាកលេខ ឬសញ្ញាសម្គាល់លើហិបឆ្នោតរួចហើយ ហិបឆ្នោត ទាំងនេះមិនអាចបើកចំហឡើយ លើកលែងតែក្នុងបំណងរាប់សន្លឹកឆ្នោត ដូចមានចែងនៅក្នុងច្បាប់នេះ និងមិនអាចយកចេញពីការិយាល័យបោះឆ្នោត លើកលែងតែការដឹកជញ្ជូនទៅកន្លែងរាប់សន្លឹកឆ្នោត ក្នុងករណីដែលច្បាប់ ឬបទបញ្ជាតម្រូវឲ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ។

មាត្រា ១០០.-

នៅចន្លោះពីម៉ោង ៦:៣០ នាទីព្រឹក ដល់ម៉ោង ៧:០០ នាទីព្រឹក ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចាត់ឲ្យបើកស្រោមសំបុត្រ ដែលមានត្រាសម្ងាត់សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត រាប់សន្លឹកឆ្នោត និងកត់ត្រាចំនួន ព្រមទាំងលេខរៀងនៅលើគល់បញ្ជីសន្លឹកឆ្នោតតាមបែបបទ ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១០១.-

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវបើកការិយាល័យបោះឆ្នោត នៅម៉ោង ៧:០០ នាទីព្រឹក ។

មាត្រា ១០២.-

អ្នកដែលមានសិទ្ធិចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោតបាន លុះត្រាតែជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរបស់ខ្លួន ហើយជននោះមិនទាន់បានបោះឆ្នោតនៅឡើយ ។

អ្នកបោះឆ្នោតម្នាក់ៗ ត្រូវបានផ្តល់សន្លឹកឆ្នោតឲ្យក្នុងការិយាល័យបោះឆ្នោត ក្នុងករណីដែលអ្នកបោះឆ្នោតនោះបំពេញបានតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

-មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត ដែលសាមីខ្លួនត្រូវបោះឆ្នោត



-មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

មិនទាន់បានបោះឆ្នោតនៅឡើយ ហើយអនុញ្ញាតឲ្យមន្ត្រីបោះឆ្នោតពិនិត្យ មើលម្រាមដៃរបស់បុគ្គលនោះ។

អ្នកបោះឆ្នោតម្នាក់ៗត្រូវគូសនៅលើសន្លឹកឆ្នោតតែម្នាក់ឯង នៅក្នុងបន្ទប់គូសសន្លឹកឆ្នោតដោយឡែក ហើយដាក់សន្លឹកឆ្នោតដែលបានគូសរួចនោះទៅក្នុងហិបឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកត្រូវអនុញ្ញាតឲ្យមន្ត្រីការិយាល័យបោះឆ្នោតជ្រលក់ទឹកខ្មៅលុបមិនជ្រះ ទៅតាមនីតិវិធីដែលបានកំណត់ ។

របៀបគូសសន្លឹកឆ្នោត និងដាក់សន្លឹកឆ្នោតចូលក្នុងហិបឆ្នោត ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវតាក់តែងបទបញ្ជា ដើម្បីអនុវត្តជាក់ស្តែងនូវមាត្រានេះ និងកំណត់អំពីការគ្រប់គ្រងនីតិវិធីបោះឆ្នោត នៅក្នុងការិយាល័យបោះឆ្នោត ។

មាត្រា ១០៣.-

សមាជិកនៃគណៈកម្មការការិយាល័យបោះឆ្នោតត្រូវបានអញ្ជើញឲ្យបោះឆ្នោតមុនគេ បន្ទាប់មកភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតនោះ ។

មាត្រា ១០៤.-

អ្នកបោះឆ្នោតដែលបានធ្វើឲ្យខូចសន្លឹកឆ្នោតដោយអចេតនា ត្រូវប្រគល់សន្លឹកឆ្នោតនេះឲ្យមន្ត្រីការិយាល័យបោះឆ្នោត ហើយមន្ត្រីការិយាល័យបោះឆ្នោតត្រូវប្រគល់សន្លឹកឆ្នោតថ្មីមួយជំនួសវិញ ទៅតាមនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១០៥.-

អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតតែមួយសន្លឹក និងតែមួយដងគត់ ដោយត្រូវទៅបោះឆ្នោតដោយខ្លួនឯងផ្ទាល់ ។

អ្នកបោះឆ្នោតម្នាក់ៗត្រូវបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្តដោយគូសសញ្ញាយកតែគណបក្សនយោបាយមួយ និងមិនត្រូវកែដូរឬបន្ថែមបន្ថយទេ ។ របៀបបោះឆ្នោតលម្អិតផ្សេងទៀត ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១០៦.-

ការបោះឆ្នោតជាការសម្ងាត់របស់អ្នកបោះឆ្នោត ។

ការចេង់ដឹងអំពីការសម្ងាត់ ឬការបង្ហើបការសម្ងាត់តាមរូបភាពណាក៏ដោយត្រូវហាមឃាត់ ។

មាត្រា ១០៧.-

អ្នកបោះឆ្នោតដែលពិការមិនអាចបោះឆ្នោតដោយខ្លួនឯងបាន មានសិទ្ធិជ្រើសរើសអ្នកជំនួយម្នាក់ជានីតិជនទៅជាមួយ ឬមានសិទ្ធិស្នើសុំជំនួយពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវតែតាក់តែងបទបញ្ជាសម្រាប់ការពារសិទ្ធិដល់អ្នកបោះឆ្នោតដែលពិការរាងកាយ ហើយមិនអាចជ្រលក់ទឹកខ្មៅលុបមិនជ្រះបាន ។

មាត្រា ១០៨.-

ដើម្បីរក្សារបៀបរៀបរយក្នុងបន្ទប់បោះឆ្នោត ជនម្នាក់ៗត្រូវគោរពតាមបទបញ្ជានៃការបោះ-ឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១០៩.-

ប្រជាពលរដ្ឋដែលមានតែឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន តែពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ពុំអាចបោះឆ្នោតបានឡើយ ។

មាត្រា ១១០.-

អាចចូលបានក្នុងការិយាល័យបោះឆ្នោតតែអ្នកត្រូវបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១១១.-

មិនអនុញ្ញាតឲ្យជនណាម្នាក់ចូលទៅជ្រៀតជ្រែក ឬជួយអ្នកបោះឆ្នោតក្នុងពេលដែលអ្នកបោះ-ឆ្នោតស្ថិតនៅក្នុងបរិវេណខាងក្នុង ឬក្នុងការិយាល័យបោះឆ្នោតបានឡើយ លើកលែងតែមានការអនុញ្ញាតអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ១១២.-

ហាមដាច់ខាតយកអាវុធ ឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងហាមស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពិសេស ពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១១៣.-

មន្ត្រីការិយាល័យបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ មានសិទ្ធិ ប្តឹងជំទាស់ចំពោះជនណាម្នាក់នៅក្នុងការិយាល័យបោះឆ្នោត ក្នុងករណីដែលជននោះមិនបានបំពេញតាមលក្ខខណ្ឌណាមួយ ដូចមានចែងក្នុងមាត្រា ១០២ នៃច្បាប់នេះ ។

ROYAUME du CAMBODGE * LE MINISTRE du PALAIS ROYAL *

ការប្តឹងជំទាស់ ត្រូវធ្វើទៅកាន់ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ។

ក្នុងករណីប្រធានគណៈកម្មការការិយាល័យបោះឆ្នោតពិនិត្យឃើញថា ជននោះមិនបានបំពេញតាមលក្ខខណ្ឌណាមួយ ដូចមានចែងក្នុងមាត្រា ១០២ នៃច្បាប់នេះ ជននោះមិនត្រូវបានអនុញ្ញាតឲ្យបោះឆ្នោតឡើយ ហើយជននោះត្រូវអមដំណើរដោយមន្ត្រីការិយាល័យបោះឆ្នោតឲ្យចេញក្រៅពីការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុង ។

ក្នុងករណីប្រធានគណៈកម្មការការិយាល័យបោះឆ្នោតសម្រេចថា ជននោះបានបំពេញលក្ខខណ្ឌតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ១០២ នៃច្បាប់នេះ ជននោះត្រូវបានអនុញ្ញាតឲ្យបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយបទបញ្ជានូវរបៀបរបបប្តឹងជំទាស់ការដោះស្រាយ និងការកត់ត្រា អំពីករណីខាងលើនេះ ។

មាត្រា ១១៤.-

ក្នុងករណីដែលភ្នាក់ងារគណបក្សនយោបាយបានយល់ឃើញថា ការបោះឆ្នោតមិនប្រក្រតី ភ្នាក់ងារគណបក្សនយោបាយនោះ អាចប្តឹងជំទាស់ ឬតវ៉ាមកប្រធានគណៈកម្មការការិយាល័យបោះឆ្នោតបាន ។

របៀបបែបបទប្តឹងជំទាស់ ឬតវ៉ា ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធី ។

គណៈកម្មការការិយាល័យបោះឆ្នោតត្រូវដោះស្រាយបណ្តឹងជំទាស់ ឬតវ៉ានេះ ។

ការសម្រេចរបស់គណៈកម្មការការិយាល័យបោះឆ្នោត ជាការសម្រេចបានការក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ប្រសិនបើការបោះឆ្នោតនោះប្រព្រឹត្តទៅដោយប្រក្រតី ។

ប្រសិនបើអ្នកភ្នាក់ងារគណបក្សនយោបាយនៅតែជំទាស់ ឬតវ៉ាគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចុះបណ្តឹងជំទាស់ ឬតវ៉ានេះ ក្នុងកំណត់ហេតុ ដោយឲ្យអ្នកជំទាស់ ឬតវ៉ានោះចុះហត្ថលេខាជាមួយ ។

មាត្រា ១១៥.-

បន្ទាប់ពីប្រកាសបិទការបោះឆ្នោត និងក្រោយពីអ្នកបោះឆ្នោតគ្រប់រូបបានបោះឆ្នោតហើយគ្រាម នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវ ៖

-បិទប្រឡោះសម្រាប់សិកសន្លឹកឆ្នោតនៃហិបឆ្នោត ដោយមានចុះហត្ថលេខារបស់ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយ លើក្រដាសបិទប្រឡោះ

សម្រាប់បោះឆ្នោតនោះ រួចហើយបិទគម្របខាងក្រៅពីលើ និងចាក់សោ ហើយអនុញ្ញាតឲ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ពិនិត្យមើលហិបឆ្នោតនោះ

-ចុះក្នុងកំណត់ហេតុនូវអ្នកដែលបានមកបោះឆ្នោត

-បំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទដោយបង្ហាញពីចំនួនសន្លឹកឆ្នោតដែលបានទទួលដែលបានផ្តល់ឲ្យអ្នកបោះឆ្នោត សន្លឹកឆ្នោតដែលខូច ឬដែលបានដកហូតនៅក្នុងការិយាល័យបោះឆ្នោត

-បំបែកគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ ចេញពីគល់បញ្ជីសន្លឹកឆ្នោតដែលមិនបានប្រើប្រាស់

-បង្ហាញទម្រង់បែបបទខាងលើដែលបានបំពេញ និងចុះហត្ថលេខារួចហើយ ជូនភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ។

ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី លើកំណត់ហេតុខាងលើនេះ ។

មាត្រា ១១៦.-

សន្លឹកឆ្នោតត្រូវរាប់នៅការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ ។

ចំពោះការិយាល័យបោះឆ្នោតណា ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ដោយករណីប្រធានសក្តិ ឬអសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនឹងធ្វើការណែនាំដោយឡែក ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំ និងគ្រប់គ្រងការិយាល័យរាប់សន្លឹកឆ្នោតស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់នេះ ។

មាត្រា ១១៧.-

មន្ត្រីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ជាអ្នកទទួលខុសត្រូវក្នុងការរាប់សន្លឹកឆ្នោតក្នុងការិយាល័យរបស់ខ្លួន ក្នុងករណីនេះ ការិយាល័យបោះឆ្នោតនឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត ។

ក្នុងករណីសន្លឹកឆ្នោត ត្រូវរាប់នៅកន្លែងផ្សេងក្រៅពីការិយាល័យបោះឆ្នោតតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១១៦ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឲ្យមន្ត្រីការិយាល័យបោះឆ្នោតនោះរាប់សន្លឹកឆ្នោត ឬអាចតែងតាំងមន្ត្រីផ្សេងទៀតឲ្យរាប់សន្លឹកឆ្នោត ក្នុងករណីមន្ត្រីការិយាល័យបោះឆ្នោតនោះ អវត្តមាន ។

មាត្រា ១១៨.-

ជនគ្រប់រូបនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងនៅក្នុងបរិវេណខាងក្នុង ត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ប្រធានការិយាល័យរាប់សន្លឹកឆ្នោត តាមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១១៩.-

គណៈកម្មការការិយាល័យបោះឆ្នោតត្រូវផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត ដែលមាននៅក្នុងហិបឆ្នោតជាមួយចំនួនអ្នកដែលបានមកបោះឆ្នោត ដែលរាប់ឃើញក្នុងបញ្ជីបោះឆ្នោត ។

ក្នុងករណីដែលសន្លឹកឆ្នោតក្នុងហិបឆ្នោតមានចំនួនខុសគ្នានឹងចំនួនអ្នកបោះឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចាត់ឲ្យរាប់ឡើងវិញ ។

ប្រសិនបើចំនួនខុសគ្នានៅតែមានដដែល ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចុះក្នុងកំណត់ហេតុ ។

មុននឹងចាប់ផ្តើមរាប់សន្លឹកឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើប្រាស់ទាំងអស់ ដើម្បីធ្វើមោយភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើ រួចត្រូវដាក់សន្លឹកឆ្នោតមោយភាព និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើទៅក្នុងស្បោងផ្លាស្ទិកតែមួយ រួចបិទឲ្យជិត ។

បន្ទាប់មកប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចាត់ឲ្យរាប់សន្លឹកឆ្នោត ដោយអនុលោមតាមបទបញ្ជា និងនីតិវិធី ។

បន្ទាប់ពីបំពេញបែបបទតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១១៥ មាត្រា ១១៦ និងមាត្រា ១១៧ នៃច្បាប់នេះ ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវចាត់ឲ្យបើកហិបឆ្នោត និងចាក់សន្លឹកឆ្នោតទាំងអស់ចេញពីក្នុងហិបឆ្នោតនីមួយៗ រួចហើយ ត្រូវ ៖

-ដាក់វត្ថុដែលមិនមែនជាសន្លឹកឆ្នោត ដាច់ដោយឡែក ប្រសិនបើមាន

-លាសន្លឹកឆ្នោតដែលមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង ដោយដាក់ ផ្គាប់ចុះក្រោមនៅពំនូកទី ១

-ក្នុងករណីមានសន្លឹកឆ្នោតដែលបានចោះ តែមិនមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង ត្រូវដាក់ដោយឡែកនៅពំនូកទី ២

-រាប់ចំនួនសន្លឹកឆ្នោតដែលផ្គាប់ចុះក្រោមទាំងពីរពំនូក ហើយកត់ត្រា និងបង្ហាញអំពីចំនួនសន្លឹកឆ្នោតដែលបានរាប់ទាំងពីរពំនូក ដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

ប្រធានការិយាល័យរាប់សន្លឹកឆ្នោត ត្រូវធ្វើឯងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានរាប់ពីហិបឆ្នោត ជាមួយនឹងចំនួនដែលបានកត់ត្រាក្នុងទម្រង់បែបបទដែលបានបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១១៥ នៃច្បាប់នេះ រួចហើយត្រូវបង្ហាញលទ្ធផលនៃការធ្វើឯងផ្ទាត់នេះ ដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីឲ្យអ្នកទាំងនោះអាចពិនិត្យ តាមដាននិងវាយតម្លៃលទ្ធផលនោះបាន ។

មាត្រា ១២០.-

មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត ត្រូវផ្ទៀងសន្លឹកឆ្នោតដែលមានបោះត្រាខាងខ្នងនៅពីនូកទី ១ ដូចមានចែងក្នុងមាត្រា ១១៩ នៃច្បាប់នេះ រួចហើយត្រូវបំបែកសន្លឹកឆ្នោតទាំងនេះជាសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ។

ត្រូវចាត់ទុកជាបានការ សន្លឹកឆ្នោតណាដែលមានគូសសញ្ញាគាំទ្រគណបក្សនយោបាយតែមួយ នៅលើសន្លឹកឆ្នោតដែលគណៈកម្មការការិយាល័យចែកឲ្យ ។

ត្រូវទុកជាមោឃៈសន្លឹកឆ្នោត ៖

១-ដែលពុំមែនជាសន្លឹកឆ្នោតផ្លូវការ ឬ

២-ដែលគ្មានគំនូស ឬមានគំនូសតែគណៈកម្មការការិយាល័យបោះឆ្នោតមិនអាចសន្និដ្ឋានបានថា បោះឆ្នោតឲ្យគណបក្សនយោបាយណាមួយ ឬ

៣-ដែលមានសញ្ញាដែលនាំឲ្យគេស្គាល់អ្នកបោះឆ្នោត ឬ

៤-ដែលមានរហែក ឬខូច ឬ

៥-ដែលគ្មានត្រាសម្ងាត់ជាផ្លូវការ ។

សន្លឹកឆ្នោតដែលទុកជាមោឃៈក្នុងចំណោចទី ១ ទី ២ ទី ៣ ទី ៤ ទី ៥ ខាងលើនេះត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បន្ទាប់មក មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតត្រូវរាប់សន្លឹកឆ្នោតបានការដែលបានគូសសញ្ញាគាំទ្រគណបក្សនយោបាយនីមួយៗ ។

សន្លឹកឆ្នោតត្រូវរាប់ទៅតាមវិធីមួយដែលអាចមើលឃើញគំនូសនៃការបោះឆ្នោតទាំងអស់ ដោយភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

មាត្រា ១២១.-

នៅពេលមានការជំទាស់ចំពោះសន្លឹកឆ្នោត ដែលបានរាប់តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១២០ នៃច្បាប់នេះ សន្លឹកឆ្នោតដែលមានការជំទាស់នោះ ត្រូវដាក់ដាច់ដោយឡែក ហើយដោះស្រាយទៅតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១២២ នៃច្បាប់នេះ ។

មាត្រា ១២២.-

មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត ត្រូវពិនិត្យមើលគ្រប់សន្លឹកឆ្នោតមិនបានការ និងសន្លឹកឆ្នោតដែលមានការជំទាស់ តាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១២០ និងមាត្រា ១២១ នៃច្បាប់នេះ ។

ការពិនិត្យសន្លឹកឆ្នោតនេះ ត្រូវធ្វើជាចំហចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ និងសុំឲ្យអ្នកទាំងនោះផ្តល់មតិយោបល់ ។

បន្ទាប់ពីបានពិចារណាលើមតិយោបល់ទាំងនេះហើយ ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវសម្រេចបដិសេធចោល និងមិនរាប់សន្លឹកឆ្នោត ដែល ៖

-ពុំមែនជាសន្លឹកឆ្នោតដែលផ្តល់ឲ្យដោយការិយាល័យបោះឆ្នោត

-គ្មានត្រាសម្ងាត់ជាផ្លូវការ

-គូសឲ្យគណបក្សនយោបាយលើសពីមួយ

-គ្មានគំនូស

-មានគំនូស ប៉ុន្តែមិនអាចយកជាការបាន ដោយគំនូសនោះមិនអាចឲ្យមន្ត្រីរាប់សន្លឹកឆ្នោតសម្រេចថា តើគូសឲ្យគណបក្សនយោបាយណាមួយ

-មានសញ្ញាដែលនាំឲ្យគេស្គាល់អ្នកបោះឆ្នោត

-រហែក ឬខូចមិនអាចយកជាការបាន ។

សន្លឹកឆ្នោតដែលបានសម្រេចទទួលយកតាមមាត្រានេះ ត្រូវយកមករាប់បូកជាមួយនឹងសន្លឹកឆ្នោតបានការ ដែលបានរាប់តាមលក្ខខណ្ឌ ដូចមានចែងក្នុងកថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃមាត្រា ១២០ នៃច្បាប់នេះ ទោះបីជាមាន ឬគ្មានការជំទាស់ទៅនឹងការសម្រេចទទួលយកនោះក្តី ។

មាត្រា ១២៣.-

បន្ទាប់ពីបានរាប់សន្លឹកឆ្នោតរួចហើយ គណៈកម្មការការិយាល័យបោះឆ្នោតត្រូវធ្វើកំណត់ហេតុអំពីការរាប់សន្លឹកឆ្នោតនេះ រួចផ្ញើជូនគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតដោយភ្ជាប់ជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ ពុំបានការ សន្លឹកឆ្នោតដែលពុំបានប្រើប្រាស់ ពាក្យបណ្តឹងជំទាស់ ឬតវ៉ាប្រសិនបើមាន និងឯកសារផ្សេងៗ ចំទៅការិយាល័យបោះឆ្នោត និងចែកជូនភ្នាក់ងារគណបក្សនយោបាយ ដែលមានវត្តមាន ។

សន្លឹកឆ្នោតបានការ ពុំបានការ សន្លឹកឆ្នោតដែលពុំបានប្រើប្រាស់ ពាក្យបណ្តឹងជំទាស់ ឬតវ៉ា ឯកសារផ្សេងៗ ត្រូវច្រកដោយឡែកពីគ្នាក្នុងស្រោមសំបុត្រដែលបានចែកឲ្យ ។

កំណត់ហេតុស្តីពីការរាប់សន្លឹកឆ្នោតនេះ ត្រូវចុះហត្ថលេខាដោយប្រធាន និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ។ ភ្នាក់ងារគណបក្សនយោបាយអាចចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនេះបាន ។

មាត្រា ១២៤.-

ការបញ្ជូន ការប្រគល់ និងការទទួលកំណត់ហេតុ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធី ។

មាត្រា ១២៥.-

ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អាចចូលរួមជាសាក្សីក្នុងការប្រគល់ ឬការទទួលកំណត់ហេតុបោះឆ្នោត ។

មាត្រា ១២៦.-

គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវប្រមូលកំណត់ហេតុ និងឯកសារទាំងអស់ពីគ្រប់គណៈកម្មការការិយាល័យបោះឆ្នោត រួចធ្វើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។ កំណត់ហេតុនេះ ត្រូវធ្វើជា ០៤ (បួន) ច្បាប់ ០១ (មួយ) ច្បាប់ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ០១ (មួយ) ច្បាប់ផ្ញើជូនគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ០១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត និង ០១ (មួយ) ច្បាប់ទៀត ទុកជាឯកសារ ។

ក្នុងករណីមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ឬពីភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោតណាមួយ គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវបើកការប្រជុំសម្រេចជាសាធារណៈជាបន្ទាន់ ។

ក្នុងករណីអ្នកប្តឹងតវ៉ាពុំពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត អ្នកប្តឹងតវ៉ា ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការ រាជធានី ខេត្ត រៀបចំការបោះឆ្នោតជាបន្ទាន់ ។

មាត្រា ១២៧.-

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវប្រមូលកំណត់ហេតុទាំងអស់ពីគ្រប់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត រួចធ្វើកំណត់ហេតុសរុបពីលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន ។ កំណត់ហេតុនេះត្រូវធ្វើជា ០៣ (បី) ច្បាប់ ០១ (មួយ) ច្បាប់ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយភ្ជាប់ទៅជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតពុំបានការ សន្លឹកឆ្នោតពុំបានប្រើប្រាស់ ពាក្យបណ្តឹងជំទាស់ ឬតវ៉ាប្រសិនបើមាន ព្រមទាំងឯកសារផ្សេងៗទៀត ០១ (មួយ) ច្បាប់ បិទនៅទីស្នាក់ការគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត និង ០១ (មួយ) ច្បាប់ទៀត ទុកជាឯកសារ ។

មាត្រា ១២៨.-

ក្នុងករណីមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ឬអំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវធ្វើសវនាការជាសាធារណៈ ដើម្បីសម្រេចអំពីបណ្តឹងតវ៉ាទាំងនោះជាបន្ទាន់ រួចហើយត្រូវធ្វើសេចក្តីសម្រេចរបស់ខ្លួន ភ្ជាប់ជាមួយនឹងកំណត់ហេតុបូកសរុបលទ្ធផលបោះឆ្នោត ជូនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីអ្នកប្តឹងតវ៉ាពុំពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត អ្នកប្តឹងតវ៉ា ឬតំណាងត្រូវធ្វើការប្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាបន្ទាន់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការពិនិត្យ និងសម្រេចថា លទ្ធផលនៃការបោះឆ្នោតនេះជាបានការ ឬឲ្យបោះឆ្នោតសាជាថ្មី ។

ការបោះឆ្នោតសាជាថ្មីត្រូវធ្វើឡើងរយៈពេល ០៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ។

មាត្រា ១២៩.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្រមូលលទ្ធផលទាំងអស់មកពិនិត្យ ហើយធ្វើការសម្រេចលើលទ្ធផលបោះឆ្នោត ។

បើភាពមិនប្រក្រតីមិនធ្ងន់ធ្ងរទេ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្រកាសទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ។

ប្រសិនបើភាពមិនប្រក្រតីមានកម្រិតធ្ងន់ធ្ងរ ធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបង្ខិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះ ហើយជូនព័ត៌មានដល់គណបក្សនយោបាយ ។ ក្នុងករណីនេះ ការបោះឆ្នោត សាជាថ្មី នៅការិយាល័យនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះ ត្រូវធ្វើ ០៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ។

មាត្រា ១៣០.-

ក្រោយពីការត្រួតពិនិត្យ និងសម្រេចលើលទ្ធផលនៃការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

លទ្ធផលបណ្តោះអាសន្ននេះ ត្រូវធ្វើ ០១ (មួយ) ច្បាប់ថ្វាយព្រះមហាក្សត្រ និង ០១ (មួយ) ច្បាប់ធ្វើជូនក្រុមប្រឹក្សាធម្មនុញ្ញ ។ គណបក្សនយោបាយដែលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានសិទ្ធិសុំសេចក្តីចម្លងលទ្ធផលបណ្តោះអាសន្ននេះបាន ។

មាត្រា ១៣១.-

បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្នក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ គ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្ទាល់ក៏បាន ដោយបញ្ជាក់ពីភាពមិនប្រក្រតីនៃគណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុសពីកាលបរិច្ឆេទ ដែលធ្វើខុសពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត ។

មាត្រា ១៣២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសម្រេចលើបណ្តឹងតវ៉ា ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីទទួលបានពាក្យបណ្តឹង ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រេចថា បណ្តឹងតវ៉ាពុំអាចទទួលបាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ ។

-ផ្តល់ព័ត៌មានទៅអ្នកប្តឹងតវ៉ា ឬ/និងគណបក្សនយោបាយថា អនុលោមតាមមាត្រា ១៣៤ នៃច្បាប់នេះ សាមីខ្លួន ឬគណបក្សនយោបាយមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីទទួលបានលិខិតជូនដំណឹងបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធ ០១ (មួយ) ច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងក្សាទុក ០១ (មួយ) ច្បាប់ ។

មាត្រា ១៣៣.-

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ថា បណ្តឹងតវ៉ាមានទម្ងន់ករណីសមហេតុ សមផល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈដើម្បីសម្រេច។ ក្នុងករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយកាលបរិច្ឆេទ និងទីកន្លែងនៃសវនាការ ផ្តល់ព័ត៌មានទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ និងជូនព័ត៌មានទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

អ្នកប្តឹងតវ៉ា ឬ/និងគណបក្សនយោបាយ និងសមាជិកគណៈកម្មការរៀបចំការបោះឆ្នោត ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតដែលពាក់ព័ន្ធ ត្រូវមានវត្តមាននៅក្នុងសវនាការនេះ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យល់ព្រមតាមពាក្យបណ្តឹង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ ៖

-បដិសេធលទ្ធផលនៅការិយាល័យបោះឆ្នោតនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះ ហើយរៀបចំឲ្យមានការបោះឆ្នោតសាជាថ្មីនៅកន្លែងនោះ ឬកន្លែងទាំងនោះ ក្នុងរយៈពេល ០៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ។

-បំពេញបែបបទនៃការយល់ព្រមដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការយល់ព្រម ។

-ផ្តល់សេចក្តីចម្លងសេចក្តីយល់ព្រម ០១ (មួយ) ច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ ។

-ផ្តល់សេចក្តីចម្លងសេចក្តីយល់ព្រម ០១ (មួយ) ច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ជាឯកសារ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំយល់ព្រមតាមបណ្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធទៅអ្នកប្តឹងតវ៉ា ឬ/និងគណបក្សនយោបាយ ។

-ផ្តល់ព័ត៌មានដល់អ្នកប្តឹងតវ៉ា ឬ/និងគណបក្សនយោបាយថា អនុលោមតាមមាត្រា ១៣៤ នៃច្បាប់នេះ សាមីខ្លួន ឬគណបក្សនយោបាយមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធ ០១ (មួយ) ច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

មាត្រា ១៣៤.-

ជនណា ឬ/និងគណបក្សនយោបាយណាដែលបណ្តឹងតវ៉ារបស់ខ្លួនត្រូវបានបដិសេធដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះ ឬ/និងគណបក្សនយោបាយនោះមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីការបដិសេធ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបើកសវនាការជាសាធារណៈ សម្រេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេលពី ១០ (ដប់) ថ្ងៃទៅ ២០ (ម្ភៃ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចចុងក្រោយ ។

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថា បណ្តឹងតវ៉ាពុំអាចទទួលបាន ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវ ៖

-បំពេញបែបបទនៃការបដិសេធដែលបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធ ០១ (មួយ) ច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ និងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

-ផ្សព្វផ្សាយសេចក្តីសម្រេច និងទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញយល់ថា បណ្តឹងតវ៉ាមានទម្ងន់ករណីសមហេតុ សមផល ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបើកសវនាការជាសាធារណៈ ដើម្បីពិនិត្យ និងសម្រេចក្នុងរយៈពេល ១០ (ដប់) ថ្ងៃទៅ ២០ (ម្ភៃ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ក.ក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវ ៖

-បំពេញបែបបទនៃការយល់ព្រមដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការយល់ព្រម ។

-ផ្តល់សេចក្តីសម្រេចនៃការយល់ព្រម ០១ (មួយ) ច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ ។

-ចេញសេចក្តីសម្រេចឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះ ហើយឲ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅកន្លែងនោះ ឬនៅកន្លែងទាំងនោះក្នុងរយៈពេល ០៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ។

-ផ្សព្វផ្សាយសេចក្តីសម្រេច និងរក្សាទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

ខ.ក្នុងករណីដែលក្រុមប្រឹក្សាធម្មនុញ្ញពុំយល់ព្រមតាមបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ និងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

-ផ្សព្វផ្សាយសេចក្តីបដិសេធ និងទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

មាត្រា ១៣៥.-

ក.ក្រោយពីបណ្តឹងតវ៉ាត្រូវបានសម្រេចជាស្ថាពរ និងក្រោយពីបានទទួលលទ្ធផលនៃការបោះឆ្នោតទាំងអស់ រួមទាំងលទ្ធផលនៃការបោះឆ្នោតដែលត្រូវធ្វើសាជាថ្មី ប្រសិនបើមាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយជាផ្លូវការលទ្ធផលនៃការបោះឆ្នោត ហើយកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយនីមួយៗតាមមណ្ឌលនីមួយៗ ដោយគិតតាមចំនួនសន្លឹកឆ្នោតបានការ ។

ការបែងចែកអាសនៈតាមរាជធានី ខេត្ត ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដោយផ្អែកលើចំនួនអាសនៈក្នុងរាជធានី ខេត្ត និងលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត តាមជំហានទាំងឡាយដូចខាងក្រោម ៖

ជំហានទី ១ : កំណត់ចំនួនកូតាដែលតម្រូវឲ្យគណបក្សនយោបាយណាមួយទទួលអាសនៈ ០១ (មួយ) ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបនៅក្នុង រាជធានី ខេត្ត មកចែកនឹងចំនួនអាសនៈសរុបក្នុងរាជធានី ឬខេត្ត តាមរូបមន្តដូចខាងក្រោមនេះ និងត្រូវអនុវត្តដាច់ដោយឡែកពីគ្នា សម្រាប់រាជធានី ខេត្តនីមួយៗ ៖

$$កគ = \frac{សស}{អស}$$

ក្នុងនោះ ៖

-$កគ$: តាងឲ្យកូតាជាផលចែក ដោយមិនគិតសំណល់ចែក ។

-$សស$: តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឲ្យគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុង រាជធានី ខេត្ត ។

-$អស$: តាងឲ្យចំនួនអាសនៈសរុបតាមមណ្ឌលរាជធានី ខេត្ត ។

ជំហានទី ២ : កំណត់ចំនួនអាសនៈជាបឋមដែលគណបក្សនយោបាយនីមួយៗបានទទួលនៅក្នុងរាជធានី ខេត្ត ។

រូបមន្តដូចខាងក្រោមត្រូវអនុវត្តដាច់ដោយឡែកពីគ្នា សម្រាប់គណបក្សនយោបាយនីមួយៗដែលបានចូលរួមនៅក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ៖

$$អ_{១} = \frac{សប}{កគ}$$

ក្នុងនោះ ៖

-$អ_{១}$: ជាផលចែកដោយមិនគិតពីសំណល់ចែក តាងឲ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗ មានសិទ្ធិបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី ៣ ។

-$សប$: តាងឲ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឲ្យគណបក្សនយោបាយណាមួយនៅក្នុងរាជធានី ខេត្ត ។

-$កគ$: តាងឲ្យកូតាដែលបានកំណត់ក្នុងជំហានទី ១ ។

បន្ទាប់ពីគណនា គ្រប់គណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងរាជធានី ខេត្ត ក្នុងជំហានទី២ ប្រសិនបើគ្មានអាសនៈនៅសល់ ដើម្បីបែងចែកបន្តទៀតនោះ ចំនួនអាសនៈត្រូវសម្រេចកំណត់យកតែម្តង ។

ក្នុងករណីមានអាសនៈនៅសល់ត្រូវបន្តបែងចែក បន្ទាប់ពីធ្វើការគណនាសម្រាប់គណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត អាសនៈដែលនៅសល់ទាំងនេះត្រូវកំណត់ទៅតាមរបៀបដែលបានកំណត់ក្នុងជំហានទី ៣ ។

ជំហានទី ៣ : អាសនៈដែលនៅសល់ ត្រូវបែងចែកឲ្យគណបក្សនយោបាយនីមួយៗមានសិទ្ធិបានទទួលនៅក្នុងរាជធានី ខេត្ត ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត ។ រូបមន្តដូចខាងក្រោម ត្រូវអនុវត្តដាច់ដោយឡែកពីគ្នាសម្រាប់គណបក្សនយោបាយនីមួយៗ ដែលបានចូលរួមក្នុងការបោះឆ្នោតតាម រាជធានី ខេត្ត ៖

$$\text{ម}_{\text{ធ}} = \frac{\text{ស}_{\text{ប}}}{\text{អ}_{\text{១}} + ១}$$

ក្នុងនោះ ៖

-$\text{ម}_{\text{ធ}}$: តាងឲ្យមធ្យមភាគខ្ពស់បំផុត ។

-$\text{ស}_{\text{ប}}$: តាងឲ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឲ្យគណបក្សនយោបាយមួយ ។

-$\text{អ}_{\text{១}}$: តាងឲ្យចំនួនអាសនៈដែលបានបែងចែកឲ្យទៅគណបក្សនយោបាយមួយ ។

ក្នុងករណីដែលនៅសល់អាសនៈចំនួន ០១ (មួយ) ដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្ត ក្នុងជំហានទី ៣ សម្រាប់គណបក្សនយោបាយដែលមានលក្ខណាសម្បត្តិទាំងអស់ អាសនៈនោះត្រូវបែងចែកទៅឲ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។

ក្នុងករណីដែលនៅសល់អាសនៈច្រើនជាង ០១ (មួយ) ដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុងជំហានទី៣ ហើយអាសនៈចំនួន ០១ (មួយ) ត្រូវបែងចែកទៅឲ្យគណបក្សនយោបាយណាដែលមធ្យមភាគខ្ពស់បំផុត ។ បន្ទាប់មកត្រូវអនុវត្តរូបមន្តនេះម្តងទៀត ដោយបង្កើនតម្លៃ $\text{អ}_{\text{១}}$ ចំនួន ០១ (មួយ) ចំពោះគណបក្សនយោបាយដែលបានទទួលអាសនៈចំនួន ០១ (មួយ) ក្នុងការអនុវត្តរូបមន្តលើកទីមួយ។ ដូច្នេះចំនួនអាសនៈចំនួន ០១ (មួយ) ត្រូវផ្តល់ឲ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ក្នុងការអនុវត្តរូបមន្តលើកទីពីរ ។ ក្នុងករណីនៅសល់អាសនៈ ត្រូវ

បែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកអាសនៈម្តងមួយអាសនៈ ជាបន្តបន្ទាប់ រហូតដល់អស់អាសនៈដែលនៅសល់ ។

ខ.ការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ ត្រូវអនុលោមទៅតាមបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងអនុវត្តតាមលំដាប់លេខរៀង ដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ ។

គ.ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតមានអ្នកជាប់ឆ្នោតទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពតំណាងរាស្ត្រ បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនោះ ត្រូវបានប្រកាសថា ជាប់ឆ្នោតជាតំណាងរាស្ត្ររបស់សាមីគណបក្សនយោបាយ ។

ឃ.ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ មានបេក្ខជនមិនគ្រប់គ្រាន់ដោយមូលហេតុដូចមានចែងក្នុងចំណុច គ នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះ ឲ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ ក្រោយពីបានទទួលសំណើ ។

បែបបទនៃការទទួលពិនិត្យ និងអនុម័តបេក្ខជនដែលស្នើបន្ថែមនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ២៣ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៨ មាត្រា ៣២ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ និងមាត្រា ៣៦ នៃច្បាប់នេះ ។

ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាខាងលើ ឬមិនបានកែលម្អការខ្វះខាតដែលធ្វើឲ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបានត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឲ្យនៅទំនេរ ។

ង.ក្នុងករណីគណបក្សនយោបាយណាមួយបានទទួលអាសនៈ ០១ (មួយ) ឬច្រើននៅក្នុងរដ្ឋសភា ប៉ុន្តែគណបក្សនយោបាយនោះបានប្រកាសបោះបង់ចោលអាសនៈរបស់ខ្លួន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយ តាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងបេក្ខជននៃគណបក្សនយោបាយនោះដែលបានប្រកាសថា ជាប់ឆ្នោតរួចហើយ មិនមានសុពលភាព និងមិនមានគុណសម្បត្តិតទៅទៀតបានឡើយ ។

ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ ទៅឲ្យគណបក្សនយោបាយផ្សេងដែលទទួលបានអាសនៈក្នុងរាជធានី ខេត្តជាមួយ តាមដំហានទាំងឡាយដូចខាងក្រោម ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបោះបង់អាសនៈ ៖

ដំហានទី ១ : កំណត់កូតាដែលតម្រូវឲ្យគណបក្សនយោបាយបានទទួល ០១ (មួយ) អាសនៈ តាមរូបមន្ត ខាងក្រោម ៖

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ប}}$$

ក្នុងនោះ ៖

-$ក'_{ត}$: តាងឲ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក ។

-$ស'_{ស}$: តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឲ្យគណបក្សនយោបាយទាំងអស់ដែលទទួលអាសនៈក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឲ្យគណបក្សនយោបាយដែលបោះបង់អាសនៈនៅក្នុងរាជធានី ខេត្ត ។

-$អ'_{ប}$: តាងឲ្យអាសនៈដែលបានបោះបង់ចោលនៅក្នុងរាជធានី ខេត្ត ។

ជំហានទី ២ : កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួលតាមរូបមន្តខាងក្រោម ៖

$$អ'_{ខ} = \frac{ស_{ប}}{ក'_{ត}}$$

ក្នុងនោះ ៖

-$អ'_{ខ}$: តាងឲ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត បានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទី ៣ ។

-$ស_{ប}$: តាងឲ្យសន្លឹកឆ្នោតបានការសរុប បោះឲ្យគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។

-$ក'_{ត}$: តាងឲ្យចំនួនកូតាដែលបានកំណត់ក្នុងជំហានទី ១ ។

បន្ទាប់ពីបានគណនាក្នុងជំហានទី ២ គ្រប់គណបក្សនយោបាយដែលទទួលបានអាសនៈក្នុងរាជធានី ខេត្ត លើកលែងតែគណបក្សនយោបាយដែលបោះបង់អាសនៈក្នុងរាជធានី ខេត្ត ក្នុងករណីគ្មាននៅសល់អាសនៈដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីគណនាក្នុងជំហានទី ២ រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកទៅទៀត អាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តដែលបានកំណត់ក្នុងជំហានទី ៣ ។

ជំហានទី ៣ : អាសនៈដែលនៅសល់ ត្រូវបែងចែកដោយកំណត់យកមជ្ឈមភាគខ្ពស់បំផុតតាមរូបមន្តខាងក្រោម ៖

$$ម'_{ត} = \frac{ស_{ប}}{អ'_{ខ}+1}$$



ក្នុងនោះ ៖

-$ម'_{ជ}$: តាងឲ្យមជ្ឈមភាគខ្ពស់បំផុត ។

-$ស_{ប}$: តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឲ្យគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។

-$អ'_{ខ}$: តាងឲ្យចំនួនអាសនៈ ដែលបានបែងចែកឲ្យទៅគណបក្សនយោបាយមួយ ។

វិធីសាស្ត្រដូចមានចែងក្នុងកថាខណ្ឌទី ៩ និងកថាខណ្ឌទី ១០ នៃចំណុច ក នៃមាត្រានេះ ត្រូវអនុវត្តចំពោះការគណនាក្នុងជំហានទី ៣ និងការគណនាជាបន្តបន្ទាប់ទៀត ។

ច.ក្នុងករណីគណនាតាមរូបមន្តខាងលើ មានគណបក្សពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នា ដែលមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ទៅឲ្យគណបក្សណាមួយបាន អាសនៈនោះត្រូវផ្តល់ជូនទៅគណបក្សនយោបាយដែលទទួលបានចំនួនសន្លឹកឆ្នោតបានការខ្ពស់ជាងគេ ។ ក្នុងករណីចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយស្មើគ្នាទៀតនោះ អាសនៈដែលនៅសល់នោះត្រូវបែងចែកទៅឲ្យគណបក្សនយោបាយតាមការចាប់ឆ្នោត ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ឆ.ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួនមានបេក្ខជនតិចជាងអាសនៈនោះ ត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងចំណុច ឃ នៃមាត្រានេះ ។

ជ.ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ក នៃមាត្រានេះ គណកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលនីមួយៗ ជាបន្តបន្ទាប់ ។

ឈ.មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើសេចក្តីរាយការណ៍ជូនគ្រប់តំណាងគណបក្សនយោបាយ ដែលចូលរួមបោះឆ្នោត នូវចំនួនសន្លឹកឆ្នោតសរុបដែលបានបោះពុម្ព ចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងចំនួនសន្លឹកឆ្នោតដែលនៅសល់ ។

មាត្រា ១៣៦.-

ការរាប់ចំនួនថ្ងៃតវ៉ា និងការសម្រេចលើបណ្តឹងតវ៉ា ដូចមានចែងក្នុងជំពូកទី ៤ ជំពូកទី ៦ និងជំពូកទី ៨ នៃច្បាប់នេះ ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

មាត្រា ១៣៧.-

ក្នុងអំឡុងពេលបោះឆ្នោត ពេលរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិ ដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀង ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៨៤ នៃច្បាប់នេះ ។

បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវរារាំងដល់ការប្រើប្រាស់សេរីភាពក្នុងការបញ្ចេញមតិដែលស្របតាមច្បាប់ជាធរមាន ។

ជំពូកទី ៩
ការចាត់បង់អាសនៈនៃរដ្ឋសភា និងការជ្រើសតាំងជំនួស

មាត្រា ១៣៨.-

បន្ទាប់ពីដំណើរការនៃការបោះឆ្នោត បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ហើយបន្ទាប់ពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរួច គណបក្សនយោបាយណាមួយដែលទទួលបានអាសនៈមួយ ឬច្រើនក្នុងរដ្ឋសភា ត្រូវចាត់ទុកថា បានបោះបង់ចោលអាសនៈរបស់ខ្លួន ក្នុងករណីណាមួយ ដូចខាងក្រោម ៖

-គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមចូលរួមសម័យប្រជុំដំបូង តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

-គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមចូលរួមប្រជុំរដ្ឋសភាសម្រាប់ការប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ។

-គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមធ្វើសច្ចាប្រណិធានចូលកាន់តំណែង ។

ក្នុងករណីខាងលើនេះ បញ្ជីបេក្ខជន និងបេក្ខជននៃគណបក្សនយោបាយនោះដែលបានប្រកាសថា ជាប់ឆ្នោតរួចហើយ មិនមានសុពលភាព និងមិនមានគុណសម្បត្តិតទៅទៀតបានឡើយ ។

រដ្ឋសភាត្រូវជូនដំណឹងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាបន្ទាន់ ឬក្នុងរយៈពេលយ៉ាងយូរ ២៤ (ម្ភៃបួន) ម៉ោង។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីរដ្ឋសភា ទៅឲ្យគណបក្សនយោបាយផ្សេងដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត

ក្នុងរាជធានី ខេត្ត ជាមួយគ្នា ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបាត់បង់អាសនៈ ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ តាមដំហានទាំងឡាយ ដូចខាងក្រោម ៖

ដំហានទី ១ : កំណត់កូតាដែលតម្រូវឲ្យគណបក្សនយោបាយបានទទួល ០១ (មួយ) អាសនៈ តាមរូបមន្តខាងក្រោម ៖

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ប}}$$

ក្នុងនោះ៖

-$ក'_{ត}$: តាងឲ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក ។

-$ស'_{ស}$:តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឲ្យគណបក្សនយោបាយផ្សេងដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឲ្យគណបក្សនយោបាយដែលបោះបង់អាសនៈនៅក្នុងរាជធានី ខេត្ត ។

-$អ'_{ប}$:តាងឲ្យអាសនៈដែលបានបោះបង់ចោលនៅក្នុងរាជធានី ខេត្ត ។

ដំហានទី ២ : កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួល តាមរូបមន្តខាងក្រោម ៖

$$អ'_{ខ} = \frac{ស_{ប}}{ក'_{ត}}$$

ក្នុងនោះ ៖

-$អ'_{ខ}$: តាងឲ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយក្នុង រាជធានី ខេត្ត បានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងដំហានទី ៣ ។

-$ស_{ប}$: តាងឲ្យសន្លឹកឆ្នោតបានការសរុប បោះឲ្យគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។

-$ក'_{ត}$: តាងឲ្យចំនួនកូតាដែលបានកំណត់ក្នុងដំហានទី ១ ។

បន្ទាប់ពីបានគណនាក្នុងដំហានទី ២ គ្រប់គណបក្សនយោបាយដែលទទួលបានអាសនៈក្នុងរាជធានី ខេត្ត លើកលែងតែគណបក្សនយោបាយដែលបោះបង់អាសនៈក្នុងរាជធានី ខេត្ត ក្នុងករណីគ្មាននៅសល់អាសនៈដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេច ត្រូវកំណត់យកតែម្តង ។

ក្នុងករណីគណនាក្នុងដំហានទី ២ រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកទៅទៀត អាសនៈដែលនៅសល់នោះ ត្រូវបែងចែកតាមរូបមន្តដែលបានកំណត់ក្នុងដំហានទី ៣ ។

ជំហានទី ៣ : អាសនៈដែលនៅសល់ត្រូវបែងចែក ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមរូបមន្តខាងក្រោម ៖

$$\text{ម}'_{\text{ធ}} = \frac{\text{ស}_{\text{ច}}}{\text{អ}'_{\text{ខ}} + 1}$$

ក្នុងនោះ ៖

-ម'$_{\text{ធ}}$: តាងឲ្យមធ្យមភាគខ្ពស់បំផុត។

-ស$_{\text{ច}}$: តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឲ្យគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។

-អ'$_{\text{ខ}}$: តាងឲ្យចំនួនអាសនៈ ដែលបានបែងចែកឲ្យទៅគណបក្សនយោបាយមួយ ។

ក្នុងករណីដែលនៅសល់អាសនៈចំនួន ០១ (មួយ) ដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្ត ក្នុងជំហានទី ៣ សម្រាប់គណបក្សនយោបាយដែលមានលក្ខណសម្បត្តិទាំងអស់ អាសនៈនោះ ត្រូវបែងចែកទៅឲ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។

ក្នុងករណីដែលនៅសល់អាសនៈច្រើនជាង ០១ (មួយ) ដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុង ជំហានទី ៣ ហើយអាសនៈចំនួន ០១ (មួយ) ត្រូវបែងចែកទៅឲ្យគណបក្សនយោបាយណាដែលមធ្យមភាគខ្ពស់បំផុត ។

បន្ទាប់មកត្រូវអនុវត្តរូបមន្តនេះម្តងទៀត ដោយបង្កើនតម្លៃ អ$_{\text{ខ}}$ ចំនួន ០១ (មួយ) ចំពោះគណបក្សនយោបាយដែលបានទទួលអាសនៈចំនួន ០១ (មួយ) ក្នុងការអនុវត្តរូបមន្តលើកទីមួយ ។ ដូច្នេះចំនួនអាសនៈចំនួន ០១ (មួយ) ត្រូវផ្តល់ឲ្យគណបក្សនយោបាយ ដែលមានមធ្យមភាគខ្ពស់បំផុត ក្នុងការអនុវត្តរូបមន្តលើកទីពីរ ។ ក្នុងករណីនៅសល់អាសនៈ ត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកអាសនៈម្តងមួយអាសនៈជាបន្តបន្ទាប់រហូតដល់អស់អាសនៈដែលនៅសល់ ។

ក្នុងករណីគណនាតាមរូបមន្តខាងលើ មានគណបក្សនយោបាយពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នាដែលមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ទៅឲ្យគណបក្សណាមួយបាន ត្រូវអនុវត្តតាមចំណុច ច នៃមាត្រា ១៣៥ នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ មានបេក្ខជនមិនគ្រប់គ្រាន់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្នើជាលាយលក្ខណ៍អក្សរ ទៅគណបក្សនោះឲ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ៤៨ (សែសិបប្រាំបី) ម៉ោង ក្រោយពីបានទទួលសំណើ ។

ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាខាងលើ ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះ បោះបង់ចោលអាសនៈឲ្យនៅទំនេរ ។

មាត្រា ១៣៩.-

សមាជិករដ្ឋសភាត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយដូចខាងក្រោម ៖

-សាមីខ្លួនទទួលមរណភាព ។

-សាមីខ្លួនបាត់បង់សម្បទាជ្ញាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

-សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា ។

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិករដ្ឋសភារូបណាមួយត្រូវបាត់បង់សមាជិកភាពមានរយៈពេល ០៦ (ប្រាំមួយ) ខែយ៉ាងតិច មុនចប់នីតិកាល សាមីគណបក្សនយោបាយនោះអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួសដោយជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានឈ្មោះតាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះមកជំនួស ដោយមិនបាច់បោះឆ្នោតឡើងវិញ ។

ជំពូកទី ១០
ទោសប្បញ្ញត្តិ

មាត្រា ១៤០.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម ៖

-ចេញបង្គាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

-ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់ អាចបោះឆ្នោតបាន ។

មាត្រា ១៤១.-

ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០(ប្រាំលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណពាក់ព័ន្ធនឹងការបោះឆ្នោត ។

មាត្រា ១៤២.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត ៖

-ការពារប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឲ្យទៅចុះឈ្មោះបោះឆ្នោត ឬការពារមិនឲ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

-បង្កការអុកឡុក ឬការពារសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត ។

-ឲ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោត ប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សា ទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។

-ការពារប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឲ្យទៅបោះឆ្នោត ។

-ការពារបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឲ្យឃោសនាបោះឆ្នោត តាមការកំណត់ ។

-ធ្វើឲ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

-ធ្វើឲ្យមានការគាបសង្កត់ឲ្យបាត់ទំនុកចិត្តលើការបោះឆ្នោត ។

-បង្កការរំខានមិនឲ្យដំណើរការបោះឆ្នោតបាន ។

-បង្កការរំខានមិនឲ្យរាប់សន្លឹកឆ្នោតបាន ។

-ធ្វើឲ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។

-ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស ។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ១៤៣.-

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា ១៤២ ខាងលើនេះ ។

មាត្រា ១៤៤.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដោយទុច្ចរិតព្យាយាមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយ លើកលែងតែមានការអនុញ្ញាតដោយច្បាប់នេះ ។

មាត្រា ១៤៥.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំដោយគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះសមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត ។

មាត្រា ១៤៦.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រាប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា៤៨៩ (បទផិលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ចូលក្នុងតំបន់ហាមឃាត់ និងក្នុងអំឡុងពេលដូចបានបញ្ញត្តក្នុងមាត្រា ៥២ និងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោតដូចបានបញ្ញត្តក្នុងមាត្រា ១១២ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិកឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារនិងមិនឲ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

មាត្រា ១៤៧.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឲ្យដាក់វិន័យផ្លូវបាល ចាប់ពីដាក់

ឲ្យនៅទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៨៧ នៃច្បាប់នេះ ។

មាត្រា ១៤៨.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលចំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោល បំពានលើបញ្ញត្តិនៃមាត្រា ៨៤ នៃច្បាប់នេះ ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ ។

មាត្រា ១៤៩.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា តាមបែបបទដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍ ។

មាត្រា ១៥០.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្កាប់ បញ្ជាលួងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឲ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឲ្យចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់)ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌ ទី ១ នៃមាត្រានេះ ។

មាត្រា ១៥១.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំដោយគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដោយចេតនាធ្វើឲ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឲ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឲ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឲ្យសាមីខ្លួនចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌ ទី ១ នៃមាត្រានេះ ។

មាត្រា ១៥២.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឲ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលជនប្រព្រឹត្តអំពើល្មើសនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

មាត្រា ១៥៣.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៥២ ខាងលើនេះ ។

មាត្រា ១៥៤.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៨ ឬកថា-ខណ្ឌទី ២ នៃមាត្រា ៧៩ នៃច្បាប់នេះ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៥៥.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថា-ខណ្ឌទី ១ នៃមាត្រា ៧២ នៃច្បាប់នេះ ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះ-ឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

មាត្រា ១៥៦.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៥៥ ខាងលើនេះ ។

មាត្រា ១៥៧.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី ២ នៃមាត្រា ៧២ នៃច្បាប់នេះ ។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ១៥៨.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារៈ មធ្យោបាយជឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាឲ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៥៩.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៣៧ នៃច្បាប់នេះ ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ ។

មាត្រា ១៦០.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីពាក់សន្លឹកឆ្នោត ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ១៦១.-

តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរមានសមត្ថកិច្ច អាចសម្រេចដាក់ទណ្ឌកម្មវិន័យ ដោយអនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ចំពោះអ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងពេលបំពេញមុខងារ ដែលបានបំពានបទប្បញ្ញត្តិនៃជំពូកនេះ ។

មាត្រា ១៦២.-

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ ។

អង្គការឬអ្នកតំណាងរបស់គណបក្សនយោបាយសំដៅដល់អង្គការឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ ។

មាត្រា ១៦៣.-

បែបបទ និងនីតិវិធី ដើម្បីចេញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៦៤.-

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ ពីសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដូចមានចែងនៅក្នុងជំពូកនេះ អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងអំឡុងពេល ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីកាលបរិច្ឆេទទទួលបានសេចក្តីសម្រេចនេះ ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាខាងលើក្នុងអំឡុងពេល ១០ (ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានពាក្យបណ្តឹងតវ៉ា ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

មាត្រា ១៦៥.-

ដំណើរការនីតិវិធី ដើម្បីចេញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬក្រុមប្រឹក្សាធម្មនុញ្ញ មិនរាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ ក្នុងករណីដែលអំពើបំពានលើបញ្ញត្តិដែលចែងនៅក្នុងជំពូកនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌ ។



មាត្រា ១៦៦.-

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី ១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី ៣ (ការបង្ខំដល់រូបកាយ) នៃគន្លឹះទី ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត ក្នុងករណីដែលសេចក្តីសម្រេចអំពីប្រាក់ពិន័យបានចូលជាស្ថាពរ ។

ជំពូកទី ១១
អន្តរប្បញ្ញត្តិ

មាត្រា ១៦៧.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបញ្ជីបោះឆ្នោតថ្មី សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោតឆ្នាំ ២០១៧ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៦ ។

ក្នុងការរៀបចំបញ្ជីបោះឆ្នោត ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវដំណើរការផ្អែកលើគោលការណ៍ដូចមានចែងក្នុងមាត្រា ៣៩ កថាខណ្ឌទី ១ កថាខណ្ឌទី ២ កថាខណ្ឌទី ៣ កថាខណ្ឌទី ៤ និងកថាខណ្ឌទី ៥ នៃមាត្រា ៤៤ មាត្រា ៤៦ មាត្រា ៤៧ មាត្រា ៤៨ មាត្រា ៤៩ មាត្រា ៥០ និងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃចំណុច ក ចំណុច ខ ចំណុច គ និងកថាខណ្ឌទី ១ នៃចំណុច ឃ នៃមាត្រា ៥១ នៃច្បាប់នេះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចប្រើប្រាស់ទិន្នន័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលរក្សាទុកដោយក្រសួងមហាផ្ទៃ និងអាចប្រើប្រាស់បញ្ជីបោះឆ្នោតចុងក្រោយសម្រាប់ជាមូលដ្ឋាន ក្នុងការរៀបចំបញ្ជីបោះ ឆ្នោតដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

បែបបទ នីតិវិធី កាលបរិច្ឆេទ និងរយៈពេលនៃការរៀបចំបញ្ជីបោះឆ្នោត ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៦៨.-

បែបបទនៃការបដិសេធការចុះឈ្មោះបោះឆ្នោត ការប្តឹងតវ៉ា និងការដោះស្រាយបណ្តឹងតវ៉ាពាក់ព័ន្ធការចុះឈ្មោះបោះឆ្នោត ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង បែបបទនៃការប្តឹងតវ៉ាអំពីការបាត់បង់ឈ្មោះ ឬប្តឹងជំទាស់អំពីការចុះឈ្មោះ ឬការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោត និងការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ក្នុងដំណើរការរៀបចំបញ្ជីបោះឆ្នោតថ្មី ដូចមានចែងក្នុងមាត្រា ១៦៧ ត្រូវផ្អែក

តាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៥៣ មាត្រា ៥៤ មាត្រា ៥៥ មាត្រា ៥៦ មាត្រា ៥៧ មាត្រា ៥៨ មាត្រា ៥៩ មាត្រា ៦០ មាត្រា ៦១ មាត្រា ៦២ មាត្រា ៦៣ មាត្រា ៦៤ និងមាត្រា ៦៥ នៃច្បាប់នេះ ។

មាត្រា ១៦៩.-

ករណីប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ប៉ុន្តែពុំមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដើម្បីបោះឆ្នោត ប្រជាពលរដ្ឋនោះ អាចប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណដើម្បីបោះឆ្នោត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញសេចក្តីណែនាំរួមអំពីបែបបទ និងនីតិវិធី ដើម្បីឲ្យអាជ្ញាធរឃុំ សង្កាត់ និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ ដូចបានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

ជំពូកទី ១២
អនុសាសនប្បញ្ញត្តិ

មាត្រា ១៧០.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

មាត្រា ១៧១.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅ ថ្ងៃទី ២៦ ខែ ម៉ីនា ឆ្នាំ២០១៥
ព្រះហស្តលេខា និងព្រះរាជលញ្ឆកា
នរោត្តម សីហមុនី

នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខ:២៥២ ស.ណ
សំណៅរក្សាទុកជាឯកសារ
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ម៉ីនា ឆ្នាំ២០១៥
អគ្គលេខាធិការដ្ឋានអង្គជំនុំជម្រះវិសាមញ្ញ

សយ សុខា



ព្រះរាជក្រម

យើង



នស/រកម/១០១៧/ ០១០

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សម្ភូហោតាស កម្ពុជឯករាជ្ជូបូរណាសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៩៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៨៩/០២៩/២០១៧ កបធ.ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



ច្បាប់

ស្តីពី

វិសោធនកម្មច្បាប់ស្តីពី

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ



មាត្រា មួយ.-

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

មាត្រា ១៣៨.- សួន

ក្នុងនីតិកាលនៃរដ្ឋសភា ប្រសិនបើមានគណបក្សនយោបាយណាមួយប្រកាសបោះបង់ចោលអាសនៈ ឬត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងតំណាងរាស្ត្រទាំងអស់នៃគណបក្សនយោបាយនោះ លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ ។

ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ ០៧(ប្រាំពីរ)ថ្ងៃ ទៅឱ្យគណបក្សនយោបាយនានាដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងរាជធានី ខេត្តជាមួយ ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងគណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាដែលដឹកនាំរាជរដ្ឋាភិបាល តាមជំហានទាំងឡាយដូចខាងក្រោម ៖

ជំហានទី១ : កំណត់កូតាដែលតម្រូវឱ្យគណបក្សនយោបាយបានទទួល ០១ (មួយ) អាសនៈតាមរូបមន្តខាងក្រោម ៖

$$ក'ត = \frac{ស'ស}{អ'ប}$$

ក្នុងនោះ ៖

-ក'ត : តាងឱ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក

-ស'ស : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឱ្យគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឱ្យគណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាដែលដឹកនាំរាជរដ្ឋាភិបាល

-អ'ប : តាងឱ្យអាសនៈដែលនៅទំនេរ ក្នុងរាជធានី ខេត្ត ។

ជំហានទី២ : កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួលតាមរូបមន្តខាងក្រោម ៖

$$\text{អ}'_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក}'_{\text{គ}}}$$

ក្នុងនោះ៖

-$\text{អ}'_{\text{ទ}}$: តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត បានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទី៣

-$\text{ស}_{\text{ប}}$: តាងឱ្យសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត

-$\text{ក}'_{\text{គ}}$: តាងឱ្យចំនួនកូតាដែលបានកំណត់ក្នុងជំហានទី១ ។

បន្ទាប់ពីបានគណនាក្នុងជំហានទី២ ក្នុងករណីគ្មាននៅសល់អាសនៈដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង។

ក្នុងករណីគណនាក្នុងជំហានទី២រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកតទៅទៀត អាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តដែលបានកំណត់ក្នុងជំហានទី៣ ។

ជំហានទី៣ : អាសនៈដែលនៅសល់ ត្រូវបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមរូបមន្តខាងក្រោម៖

$$\text{ម}'_{\text{ធ}} = \frac{\text{ស}_{\text{ប}}}{\text{អ}'_{\text{ទ}} + ១}$$

ក្នុងនោះ៖

-$\text{ម}'_{\text{ធ}}$: តាងឱ្យមធ្យមភាគខ្ពស់បំផុត

-$\text{ស}_{\text{ប}}$: តាងឱ្យសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត

-$\text{អ}'_{\text{ទ}}$: តាងឱ្យចំនួនអាសនៈ ដែលបានបែងចែកឱ្យទៅគណបក្សនយោបាយមួយ ។

វិធីសាស្ត្រដូចមានចែងក្នុងកថាខណ្ឌទី ៩ និងកថាខណ្ឌទី ១០ នៃចំណុច ក នៃមាត្រា ១៣៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវអនុវត្តចំពោះការគណនាក្នុងជំហានទី៣ និងការគណនាជាបន្តបន្ទាប់ទៀត ។

ក្នុងករណីគណនាតាមរូបមន្តខាងលើ មានគណបក្សពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នា ហើយមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ទៅឱ្យគណបក្សនយោបាយណាមួយបាន អាសនៈនោះត្រូវផ្តល់ជូនទៅគណបក្សនយោបាយដែលទទួលបានចំនួនសន្លឹកឆ្នោត

បានការខ្ពស់ជាងគេ ។ ក្នុងករណីចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយស្មើគ្នា ទៀតនោះ អាសនៈដែលនៅសល់នោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយតាមការចាប់ឆ្នោត ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួនមានបេក្ខជនតិចជាងអាសនៈនោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះ ឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ០៥(ប្រាំ)ថ្ងៃ ក្រោយពីបានទទួលសំណើ ។ បែបបទនៃការទទួលពិនិត្យនិងការអនុម័តបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ២៣ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៨ មាត្រា ៣២ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ និងមាត្រា ៣៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាខាងលើ ឬមិនបានកែលម្អការខ្វះខាត ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។ ករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបែងចែកអាសនៈដែលនៅទំនេរនេះ តាមបទប្បញ្ញត្តិនៃមាត្រានេះ ។

ក្នុងករណីពុំមានគណបក្សនយោបាយទទួលយកអាសនៈដែលនៅទំនេររបស់គណបក្សនយោបាយ ដែលប្រកាសបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបែងចែកអាសនៈដែលនៅទំនេរនោះ ឱ្យទៅគណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភា ។

មាត្រា ពីរ.

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ កុលា ឆ្នាំ២០១៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆនៈ
នរោត្តម សីហមុនី

ស.ព.ប. ១៧៦០.៧៤២
បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្បាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខៈ ៧៤៧ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា



គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
ក្រសួងអប់រំ យុវជន និងកីឡា



មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

បោះពុម្ពផ្សព្វផ្សាយ
ព.ស. ២៥៦៥ គ.ស. ២០២១